ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia

Nation Religion King

Royaume du Cambodge

Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber

Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ

# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"

# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី០៦ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៥៥**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន

លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍

*(Judge Silvia Carwright)*

លោក យ៉ា សុខន

លោក ហ្សង់ម៉ាក ឡាវែន៍

*(Judge Jean-Marc Lavegne)*

លោក ធូ មណី

លោក យូរ ឧត្តរា

លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក លឹម ស៊ុយហុង

កញ្ញា ណាតាចា វិចសែល រីសឺ

*(Ms. Natacha Wexels-Riser)*

លោក ម៉ាតូ គ្រីស្ពារ

*(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង

លោក វីល្លៀម ស្មីត (William SMITH)

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំពែល *(Mr.Zachery LAMPEL)*

**ជនជាប់ចោទ៖**

លោក កាំង ហ្កេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រ៉ូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ីនណា

កញ្ញា ម៉ុច សុវណ្ណារី

លោក គឹមម៉េងឃី

លោក គង់ ពិសី

លោកស្រី ស៊ីលឃី ស្ទូតហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ *(Mr. Alain Werner)*

លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស ណាព្រូស

*(Ms. Fabienne Trusse-Naprous)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សី

### លោក ដេវីដ ឆេនដ៍លំរ

សួរដោយ ប្រធានអង្គជំនុំ ផ្តើមពី ............ទំព័រ ១
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្តើមពី ............ទំព័រ ៥
សួរដោយ ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ............ទំព័រ ២៧
សួរដោយ លោក តាន់ សេណារ៉ុង ផ្តើមពី ............ទំព័រ ៣០
សួរដោយ លោក វីលៀម ស្មីត ផ្តើមពី............ទំព័រ ៣៣
សួរដោយ លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សូណាព្រូស ផ្តើមពី ............ទំព័រ ៤៥
សួរដោយ លោក គីម ម៉េងឃី ផ្តើមពី............ទំព័រ ៤៩
សួរដោយ លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី ផ្តើមពី ............ទំព័រ ៥១
សួរដោយ លោក អាឡាំង វែ៊នណឺ ផ្តើមពី ............ទំព័រ ៥៦
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី............ទំព័រ ៦២
សួរដោយ លោក ស្រ្វង់ស្វ័រ រូ ផ្តើមពី............ទំព័រ ៦៧

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ដាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ដេវីដ ឆេនដ័ល័រ | អង់គ្លេស |
| លោក ការ សាវុត្ថ | ខ្មែរ |
| លោក គឹម ម៉េងឃី | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន៍ | បារាំង |
| លោក ហ្វ្រង់ ស្វ័រ រូ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្គី | អង់គ្លេស |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្ស៊ ណាព្រូស | បារាំង |
| លោក អាឡាំង វែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:០២:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ តាមកាលវិភាគដែលបានគ្រោងទុក ។ នៅថ្ងៃនេះ អង្គជំនុំជម្រះអញ្ជើញអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ អ្នកជំនាញអន្តរជាតិ ដើម្បីមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។

ក្រឡាបញ្ជីឡើងរាយការណ៍ អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលត្រូវអញ្ជើញចូលរួមនៅក្នុងដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ អ្នកជំនាញ ដេវីដ ឆេនដ៍ល័រ មានវត្តមាន រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីតុលាការអញ្ជើញអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ចូលមកកាន់បន្ទប់សវនាការ ។

*[សាក្សីជំនាញចូលមកកាន់បន្ទប់សវនាការ]*

**ការតាំងសំណួរដោយចៅក្រម៖**

**សួរដោយប្រធានអង្គជំនុំ៖**

អរុណសួស្តីលោក ដេវីដ ឆេនដ៍ល័រ!

ដូចអត់មានឧបករណ៍អីឲ្យគាត់ស្តាប់ទេ?

មន្ត្រីតុលាការសម្របសម្រួលឲ្យផ្តល់ នូវឧបករណ៍ស្តាប់ភាសាបកប្រែ ។

អររុណសួស្តីលោក ដេវីដ ឆេនដ៍ល័រ!

**ស៖** លោក ដេវីដ ឆេនដ៍ល័រ តើឈ្មោះលោកពេញលេញ គឺឈ្មោះអ្វីទៅ?

[០៩:០៥:២៧]

**លោក ដេវីដ ឆេនដ៍ល័រ៖**

ឈ្មោះពេញរបស់ខ្ញុំគឺ ដេវីដ ហ្វរិច ឆេនដ៍ល័រ ។

**ស៖** លោកមានអាយុប៉ុន្មានហើយ?

**ឆ៖** ខ្ញុំមានអាយុ ៧៦ឆ្នាំ ។

**ស៖** ហើយសព្វថ្ងៃនេះលោកមានទីលំនៅអចិន្ត្រៃយ៍នៅទីណាដែរ?

**ឆ៖** នៅទីក្រុងមែលប៊ន ប្រទេសអូស្ត្រាលី ។

**ស៖** លោកប្រកបមុខរបរអ្វីដែរ?

**ឆ៖** ខ្ញុំសាស្ត្រាចារ្យដែលចូលនិវត្តន៍ហើយ ខ្ញុំជាសាស្ត្រាចារ្យប្រវត្តិសាស្ត្រ ។

**ស៖** ដោយផ្អែកតាមវិធាន៣១.២ នៃវិធានផ្ទៃក្នុង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក ដេវីដ ឆេតដ៏ល័រ ក្នុងនាមលោកជាអ្នកជំនាញអង្គជំនុំជម្រះតម្រូវឲ្យលោកធ្វើសម្បថជាមុន មុននឹងផ្តល់សក្ខីកម្ម តើលោកយល់ព្រមដែរឬទេ?

**ឆ៖** ខ្ញុំយល់ព្រម ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីអន្តរជាតិ ណាតាចា វីស៊ែល សូមរៀបចំនីតិវិធី ដើម្បីណែនាំដល់លោក ដេវីដ ឆេល័រ ក្នុងការធ្វើសម្បថ ។

**កញ្ញា ណាតាចា វីស៊ែល វីសឺ៖**

សូមឲ្យលោកថាតាមខ្ញុំ ខ្ញុំសូមប្រកាសជាឱឡារិក ខ្ញុំនឹងផ្តល់ជំនួញដល់អង្គជំនុំជម្រះដំបូងដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពរបស់ខ្ញុំ ។

[០៩:០៧:២៣]

**លោក ដេវីដ ឆេនដ៏ល័រ៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងផ្តល់ជំនួយដល់អង្គជំនុំជម្រះសាលាដំបូងដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាពរបស់ខ្ញុំ ។

**សួរដោយប្រធានអង្គជំនុំ៖**

អរគុណ ។ ឥឡូវនេះ លោកបានធ្វើសម្បថរួចហើយ ហើយអង្គជំនុំជម្រះសាលាដំបូងនឹងមានសំណួរមួយចំនួនពាក់ព័ន្ធដល់លោក ក្នុងនាមលោកជាអ្នកជំនាញ ។

**ស៖** លោក ដាវីដ ឆេនដ៏ល័រ តើលោកប្រកបវិជ្ជាជីវៈជាសាស្ត្រាចារ្យនៃសាកលវិទ្យាល័យមុននឹងលោកចូលនិវត្តន៍អស់រយៈពេលប៉ុន្មានឆ្នាំដែរ?

**ឆ៖** ខ្ញុំធ្វើការនៅសកលវិទ្យាល័យរបស់ខ្ញុំចាប់ពីឆ្នាំ៧២ ដល់ ៧៧ គឺមហាវិទ្យាម៉ូណាស់ ប៉ុន្តែខ្ញុំនៅតែបំពេញការងារនៅទីនេះនៅឡើយទេ ទោះបីជាខ្ញុំចូលនិវត្តន៍ហើយក៏ដោយ ។

**ស៖** តើលោកបានចេះសរសេរនិងចេះនិយាយភាសាខ្មែរដែរឬទេ?

**ឆ៖** ខ្ញុំអាចនិយាយ ហើយអានបាន ហើយចំពោះការសរសេររបស់ខ្ញុំនោះ គឺពិបាកបន្តិចនៅពេលដែលខ្ញុំទៅពិបាកមើលបន្តិច ។

**ស៖** តើលោកធ្លាប់បានសិក្សាអំពីប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ជាពិសេសទាក់ទងនឹងប្រវត្តិ- សាស្ត្រក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** បាទ, បានជាច្រើនឆ្នាំ។ គឺចាប់ពីឆ្នាំ១៩៧៦ ដល់ ៨៨ ហើយខ្ញុំផ្តោតសំខាន់ទៅលើរបបនិងព្រឹត្តការណ៍នៅកម្ពុជានៅក្នុងសំណេរ និងឯកសារស្រាវជ្រាវរបស់ខ្ញុំ ។

[០៩:០៩:៣៧]

**ស៖** តើលោកធ្លាប់បានសរសេរសៀវភៅដែលនិយាយអំពីរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ឆ៖** បាទ, ខ្ញុំមាន ។ ខ្ញុំបានសរសេរសៀវភៅពីរក្បាល ដែលវាទាក់ទងទៅនឹងកម្ពុជាប្រជាធិបតេយ្យ ។ ទីមួយ គឺប្រវត្តិរូបរបស់ ប៉ុល ពត, ប៉ុល ពត បងធំ ហើយសៀវភៅទីពីរ គឺទាក់ទងទៅនឹងមន្ទីរស-២១ ដែលមានចំណងជើងថា "សំឡេងពីស-២១" ។ ហើយក៏ខ្ញុំមានជំពូកស្តីអំពីប្រវត្តិសាស្ត្រវែងនៅក្នុងសៀវភៅនោះដែរ ។

**ស៖** អរគុណ ។

តើហេតុអ្វីបានជាលោកមានការចាប់អារម្មណ៍លើការសិក្សាអំពីប្រទេសកម្ពុជា ជាពិសេសលើរបបកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** វាជាសំណួរមួយដ៏ល្អ ។ ខ្ញុំចាប់អារម្មណ៍នៅក្នុងប្រទេសកម្ពុជា នៅពេលដែលខ្ញុំមកធ្វើការនៅទីនេះដំបូង ជាអ្នកការទូតនៅក្នុងកម្ពុជាចាប់ពីឆ្នាំ៦០ ទៅដល់ ៦២ ។ ហើយខ្ញុំចាប់អារម្មណ៍ទៅលើប្រទេសនេះ និងប្រជាជន ហើយខ្ញុំតាមដានទៅលើព្រឹត្តការណ៍នៅទីនេះជាច្រើនឆ្នាំ ។ នៅពេលដែលខ្មែរក្រហមកាន់កាប់អំណាចនៅក្នុងឆ្នាំ៧៥ មានប្រជាជនខ្មែរមួយចំនួនដែលខ្ញុំមើលទៅមានការភ្ញាក់ផ្អើល ហើយមានការអាក់អន់ស្រពន់ចិត្តនឹងអ្វីដែលកើតឡើង ។ ដូច្នេះហើយ ខ្ញុំចង់សិក្សារបបនេះថា តើវាយ៉ាងម៉េចដែរ? ហើយវាពាក់ព័ន្ធទៅនឹងប្រជាជនកម្ពុជាយ៉ាងម៉េចដែរ? ដូច្នេះហើយវាជាប្រវត្តិសាស្ត្រមួយដែលគួរឲ្យចាប់អារម្មណ៍ ។

[០៩:១១:៤២]

**ស៖** អរគុណ ។ នៅក្នុងសៀវភៅរបស់លោកដែលមានចំណងជើងថា "សំឡេងពីស-២១" តើលោកបានធ្វើការស្រាវជ្រាវទៅលើអ្វីខ្លះ? ហើយតើនៅពេលណាដែលលោកបានធ្វើការស្រាវជ្រាវ ដើម្បីសរសេរសៀវភៅដែលមានចំណងជើង "សំឡេងពីស-២១"?

**ឆ៖** ខ្ញុំចាប់ផ្តើមប្រើអត្ថបទពីស-២១ ពីដើមទសវត្សរ៍៩០ ហើយនៅក្នុងសៀវភៅរបស់ខ្ញុំទាក់ទងទៅនឹង ប៉ុល ពត មានឯកសារមួយចំនួនពីស-២១ ។ ហើយខ្ញុំសិក្សាទៅលើមន្ទីរស-២១ ពេញម៉ោងតែម្តងនៅក្នុងឆ្នាំ១៩៩៤ ។ ហើយសៀវភៅបានបញ្ជូនទៅអ្នកបោះពុម្ពនៅក្នុងឆ្នាំ១៩៩៨ ហើយបោះពុម្ពចេញនៅឆ្នាំ៩៩ ។ ដូច្នេះហើយខ្ញុំចំណាយពេលបួនឆ្នាំ ផ្តោតទៅលើមន្ទីរស-២១ ដើម្បីធ្វើការសរសេរចេញនូវសៀវភៅមួយក្បាលនេះ ។

**ស៖** ក្នុងអំឡុងពេលស្រាវជ្រាវ តើលោកធ្វើការវិភាគនូវបណ្ណសារទាំងអស់នៅមន្ទីរស-២១ រួមទាំងចម្លើយសារភាពជាងបួនពាន់ នៅមន្ទីរស-២១ "ទួលស្លែង" តើពិតមែនដែរឬទេ?

**ឆ៖** បាទ, ខ្ញុំបានមែន ។ ខ្ញុំបានសិក្សាទៅលើបណ្ណសារនោះយ៉ាងប្រុងប្រយ័ត្ន ហើយមាន *ម៉ៃក្រូហ្វីម* ផងដែរ ។ ហើយខ្ញុំធ្វើការស្រាវជ្រាវនៅកម្ពុជា ខ្ញុំធ្វើការនៅបណ្ណសារនៅស-២១ ដែលបណ្ណសារហ្នឹងនៅដែលទេនៅស-២១ នៅសារមន្ទីរនោះ ហើយក៏មានបណ្ណសារនៅ *ឌីស៊ីខេម* ផងដែរ ។ ហើយខ្ញុំធ្វើការនៅមន្ទីរបណ្ណសារនោះ ហើយខ្ញុំបានសិក្សាទៅលើឯកសារជាច្រើន ហើយខ្ញុំគិតថាវាមានឯកសារគ្រប់គ្រាន់ ដែលបានជួយទៅដល់ការសរសេរសៀវភៅរបស់ខ្ញុំ និងការស្រាវជ្រាវរបស់ខ្ញុំ ។

[០៩:១៣:៥១]

**ស៖** អរគុណ ។ តើលោកធ្លាប់បានធ្វើ ជួបសម្ភាសន៍ជាបុគ្គលិកអ្នករស់រានមានជីវិត អ្នករក្សាបណ្ណសារនៅមន្ទីរស-២១ និងអ្នកផ្សេងទៀតដែលដឹងច្បាស់ អំពីរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេក្នុងអំឡុងពេលដែលលោកសិក្សាស្រាវជ្រាវនោះ?

**ឆ៖** ខ្ញុំធ្វើការសម្ភាសន៍ វ៉ាន់ ណាត ពីរបីដង ហើយខ្ញុំក៏សម្ភាសអតីតអ្នកយាមពីរនាក់ដែរ គឺ គក ស្រស់ និង ហ៊ឹម ហ៊ុយ ។ ហើយអ្នកទាំងអស់នោះ-- ហើយខ្ញុំក៏ធ្វើការសម្ភាសន៍ ញ៉ែម អេន ផងដែរ ។ ហើយខ្ញុំមិនបាននិយាយជាមួយនឹងបុគ្គលិកផ្សេងទៀតទេនៅស-២១ ដោយសារតែនៅពេលនោះគឺពួកគេមិនមានលទ្ធភាពមកផ្តល់ការសម្ភាសន៍ដល់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អរគុណ ។ តើអស់លោក លោកស្រីចៅក្រម មានសំណួរអ្វីត្រូវសួរដល់អ្នកជំនាញរូបនេះដែរឬទេ? សូមអញ្ជើញលោកស្រីចៅក្រម ខាតវ៉ាយច៍ ។

[០៩:១៥:00]

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណច្រើនលោកប្រធាន ។ ជាដំបូងលោកសាស្ត្រាចារ្យ ឆេនដ័ល័រ អង្គជំនុំជម្រះនិងភាគីសូមថ្លែងអំណរគុណចំពោះលោកដែលធ្វើដំណើរពីចម្ងាយ ពីឆ្ងាយមកដើម្បីមកផ្តល់ជួយយើងខ្ញុំក្នុងការលាតត្រដាងនិងស្វែងរកការពិត ។

**ស៖** បញ្ហាតូចមួយដំបូងនៅពេលដែលលោកឆ្លើយសំណួររបស់លោកប្រធាន ថាតើលោកបានធ្វើការវិភាគឯកសារណាខ្លះនៅក្នុងសៀវភៅរបស់លោក?

ការបកប្រែនោះ គឺបានលើកឡើងថាលោកបានពិចារណាឯកសារជាងមួយពាន់។ ប៉ុន្តែនៅពេលដែលខ្ញុំស្រាវជ្រាវទៅ គឺលោកបានធ្វើឯកសារច្រើនជាងមួយពាន់ហ្នឹងទៀត តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ? ខ្ញុំបានមើលទៅ តួលេខហ្នឹង គឺបួនពាន់ជាង ។ សូមចាំបន្តិច លោក ឆេនដ័ល័រ គឺប្រព័ន្ធដែលយើងអនុវត្តនៅទីនោះ គឺឲ្យលោករង់ចាំនូវពណ៌ភ្លើងក្រហមសិន ហើយសូមឲ្យលោកធ្វើការបន្ថយល្បឿននៃការនិយាយ ដោយសារតែយើងត្រូវការការបកប្រែចេញជាពីរភាសា ។

**ឆ៖** សូមអរគុណចំពោះការសួររបស់លោកចៅក្រម។ ឲ្យខ្ញុំធ្វើការសន្និដ្ឋានថា ខ្ញុំមិនដឹងថាខ្ញុំធ្វើការពិនិត្យឯកសារប៉ុន្មាននោះទេ ។ ហើយឯកសារដែលចាប់អារម្មណ៍នោះ គឺខ្ញុំមើលឯកសារខ្លះ និងឯកសារដែលជាន់គ្នា គឺខ្ញុំទុកវាចោល ហើយខ្ញុំមិនច្បាស់នោះទេ ។ ប៉ុន្តែ ការដកស្រង់នៅក្នុងសៀវភៅរបស់ខ្ញុំហ្នឹងគឺប្រហែលជាបីរយទៅបួនរយ ។ ហើយគឺអ្វីដែលខ្ញុំសន្និដ្ឋាននោះ គឺប្រហែលជាចម្លើយសារភាព ខ្ញុំបានមើលជាង១000 ។

**ស៖** ជាដំបូងខ្ញុំចង់ដាក់សៀវភៅរបស់លោកជាផ្លូវការនៅមុខអង្គសវនាការរបស់យើង ចំណងជើងសៀវភៅរបស់លោកនោះគឺ "សំឡេងពីមន្ទីរស-២១" "ការព្រឺខ្លាចនិងប្រវត្តិក្នុងគុកសម្ងាត់ស-២១" គឺលេខ ERN00192667 ដល់លេខ 192932 ខ្មែរគឺមានលេខ 00191816 ដល់លេខ 00192089 បារាំងគឺមានលេខ 00357247 ដល់ 00357451 ។

លោកសាស្ត្រាចារ្យ ឆេនដ័ល័រ តើលោកបានឆ្លើយតប-- ការឆ្លើយតបទៅនឹងសៀវភៅរបស់

លោក ដែលរៀបចំដោយ កាំង ហ្គេកអ៊ាវ ដែលជាជនជាប់ចោទដែរឬទេ? ERN គឺមានលេខ 00270554 ដល់លេខ 00270562 ហ្នឹងជាភាសាអង់គ្លេស ។ ហើយខ្មែរនោះគឺ 00188744 ដល់លេខ 00188754 បារាំងគឺមានលេខ 00188755 ដល់លេខ 00188768 ប្រហែលជាលោកភ្លេចសំណួររបស់ខ្ញុំហើយ ។ ខ្ញុំចង់សួរថា តើលោកបានឆ្លើយ បានមើលការឆ្លើយតបទៅនឹងសៀវភៅរបស់លោក ដែលរៀបចំឡើង ដោយលោក កាំង ហ្គេកអ៊ាវ ដែលជាជនជាប់ចោទដែរឬទេ?

**ឆ៖** បាទ, ខ្ញុំបានអាន ។

**ស៖** ចំពោះការស្រាវជ្រាវរបស់លោក តើលោកមានយោបល់យ៉ាងណាចំពោះចម្លើយរបស់ជនជាប់ចោទ ជាពិសេសចំពោះភាពត្រឹមត្រូវនៃការឆ្លើយតបរបស់គាត់?

**ឆ៖** ខ្ញុំគិតថាចម្លើយនោះ គួរឲ្យចាប់អារម្មណ៍ណាស់ ហើយគឺខ្ញុំមិនឃើញថា វាមិនមានភាពមិនត្រឹមត្រូវច្រើននោះទេ ដូច្នេះហើយ ខ្ញុំមិនមានភាពលំបាកទេក្នុងការយល់ទៅលើឯកសារទាំងអស់នោះ ឯកសារឆ្លើយតបនោះ ។

**ស៖** ចាប់ពីពេលនេះទៅ ខ្ញុំនឹងយោងទៅលើសៀវភៅមួយចំនួនរបស់លោកដោយប្រើប្រាស់ឯកសារអង់គ្លេសដើម្បីធ្វើឲ្យលោក ជួយឲ្យលោកពិនិត្យមើលបើសិនបើលោកចង់ពិនិត្យនិងអានឯកសារនិងចំណុចដែលខ្ញុំដកស្រង់នោះ ។

ក្នុងសៀវភៅរបស់លោកៗលើកឡើងថា ជនជាប់ចោទ គឺជាអ្នកបង្កើតផែនការចុងក្រោយ ។ បានន័យថា ផែនការរួមចុងក្រោយ លោកបានលើកឡើងនៅក្នុងសៀវភៅរបស់លោកជាច្រើនកន្លែង នៅក្នុងទំព័រ១២ និងទំព័រផ្សេងទៀត ។ ថាតើលោកសន្និដ្ឋានលើអ្វី ដែលថា លោកជនជាប់ចោទនោះ គឺជាអ្នកសរសេរចំពោះឯកសារផែនការរួមចុងក្រោយនោះ?

**ឆ៖** ខ្ញុំមិនអាចឆ្លើយតបទៅនឹងឯកសារនេះដោយពេញលេញទេ ។ ប៉ុន្តែ តាមអ្វីដែលខ្ញុំចងចាំនោះ គឺខ្ញុំឃើញទៅលើ នៅក្នុងឯកសារនោះ គឺមានការសរសេររបស់ជនជាប់ចោទនៅទីនោះ ។

**ស៖** សូមអរគុណ ។ ចំណាងជើងរបស់សៀវភៅរបស់លោក ឬចំណាងជើងតូចនោះ គឺបានសរសេរថា “ការព្រឺខ្លាចនិងប្រវត្តិក្នុងគុកសម្ងាត់របស់ ប៉ុល ពត” នៅក្នុងទំព័រ៨ នៅនៃសៀវភៅរបស់លោក លោកបានដកស្រង់ថា ប៉ុល ពត គាត់បដិសេធមិនដឹងអំពីវត្តមានទួលស្លែង ។ ដោយលើក ឡើងថា គាត់ធ្វើតែសេចក្តីសម្រេចធំៗលើបញ្ហាធំៗ ។ ហើយគាត់បានអះអាងថាទួលស្លែង មន្ទីរទួលស្លែងគឺជាកន្លែងតាំងពិព័ណ៌របស់វៀតណាម ។ ដោយផ្អែកទៅលើចម្លើយនោះថា ហេតុអ្វីជាលោកដាក់ចំណាង

ជើងតូចទៀតនៅក្នុងសៀវភៅរបស់លោកថា “គុកសម្ងាត់របស់ ប៉ុល ពត” នោះ?

[០៩:២២:១៩]

**ឆ៖** គឺជាសំណួរល្អបំផុត ។ គឺថាគ្មានវិធីណាមួយដែលថា គុកនេះអាចមានឡើងដោយមិនមានការយល់ស្របនឹងសេចក្ដីសម្រេចរបស់អ្នកខាងលើនោះទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ខ្ញុំគិតថា ចម្លើយរបស់ខ្ញុំនោះ គឺវាទាក់ទងទៅនឹងមន្ទីរស-២១ ដោយសារតែនៅពេលនោះ នៅរបបកម្ពុជាប្រជាធិបតេយ្យគេមិនហៅថា “ទួលស្លែង” នោះទេ ហើយខ្ញុំហៅថាជា“មន្ទីរសម្ងាត់” ដោយសារតែខ្ញុំយល់ថាវានោះតែម្ដង ដោយសារតែគុកសម្ងាត់នោះ គឺខ្ញុំគិតថាវាជាគុកដែលដឹកនាំ ដោយ ប៉ុល ពត ហើយចំពោះបញ្ហាថា វាជាការងាររបស់ទីប្រឹក្សាវៀតណាម ដោយមានអ្នកជួយពីខ្មែរនោះ គុក ស-២១ គឺគុកពី៧៦ទៅដល់៧៩ ។ ដូច្នេះហើយ ខ្ញុំយល់ថាវាមិនមែនជាការបង្កើតឡើងរបស់ខាងវៀត-ណាមនោះទេ ។

[០៩:២៣:២២]

**ស៖** នៅក្នុងសៀវភៅទំព័រ១៤ លោកបានពិពណ៌នាអំពីស-២១ ដែលថាវាជាស្ថាប័នស្វយ័ត តើលោកអាចពន្យល់ដោយសង្ខេបទេ ថាលោកមានន័យថាយ៉ាងម៉េច នៅពេលដែលលោកនិយាយថា វាជាស្ថាប័នស្វយ័តនោះ?

**ឆ៖** ចំណុចនេះ គឺជាឃ្លាដែលខ្ញុំដកស្រង់ចេញមកពីសង្គមមកពីសង្គមវិជ្ជាវិទូ គឺ*ស្កត់ម៉ែន* គាត់និយាយអំពីស្ថាប័នស្វយ័ត ថាវាជាកន្លែងដែលជាសាលាហើយមកធ្វើគុក ឬក៏កន្លែងផ្សេងៗដែលថាវាជាកន្លែងមួយបិទជិតពីសង្គម និងពិភពលោក មិនមានការទាក់ទងទៅនឹងប្រភពខាងក្រៅ ។

ដូច្នេះហើយស-២១ ខ្ញុំគិតថា វាជាស្ថាប័នស្វយ័ត ហើយចាំថាគាត់បានធ្វើការការពារទៅលើចម្លើយរបស់គាត់ នៅក្នុងនោះដែលគាត់ឆ្លើយតបនឹងសៀវភៅរបស់ខ្ញុំ ។ ហើយគាត់ក៏យល់ស្របថាវាជាស្ថាប័នស្វយ័តផងដែរ ចំពោះជនជាប់ចោទ ។

**ស៖** ថាតើវាមានលក្ខណៈយ៉ាងម៉េច? ដែលយើងហៅថា ស្ថាប័នស្វយ័តនោះ ដែលលោកបានលើកឡើង ឧទាហរណ៍ថាមួយនៅក្នុងទំព័រដប់ប្រាំសៀវភៅរបស់លោកបានលើកឡើងថា “ភាពសម្ងាត់ទាំងឡាយគឺជាអាទិភាពនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅក្នុងជួរដឹកនាំ” ថានេះជាលក្ខណៈនៃស្ថាប័នស្វយ័តដែរឬទេ នៅក្នុងការវាយតម្លៃរបស់លោកនៅក្នុងសៀវភៅនោះ?

**ឆ៖** វាត្រូវមួយចំនួននិងមិនត្រូវមួយចំនួន ។ ហើយគឺមិនមានព័ត៌មានបញ្ចេញទៅខាងក្រៅទេ លើកលែងតែបញ្ជូនទៅលើ ដូច្នេះហើយ គឺខ្ញុំបញ្ជាក់ថា វាជាស្ថាប័នស្វយ័ត ។ ហើយការគ្រប់គ្រងនោះគឺវាជាការងារមួយផ្សេងទៀត គឺមានមន្ទីរពេទ្យអីផ្សេងៗដែលគេអាចឲ្យដឹងទៅខាងក្រៅ ហើយនៅក្នុងមន្ទីរស្វយ័តនេះក៏មានក្រឹតក្រមដែលគេធ្វើឡើង ។ ហើយការសម្លាប់នោះគឺជាការពិតទៅគឺវាជាចំណុចកណ្តាលដាច់ខាតចំពោះកម្ពុជាប្រជាធិបតេយ្យ ។ ហើយ នួន ជា គាត់បានបញ្ជាក់យ៉ាងច្បាស់នៅពេលដែលប្រតិភូដាណឺម៉ាក បានមកនៅក្នុងឆ្នាំ៧៨ នោះគាត់បានលើកឡើងថា ការសម្លាប់នោះគឺជាចំណុចស្នូលនិងជាបេះដូងរបស់មន្ទីរនេះ ។

[០៩:២៦:១១]

**សៈ** លោកដឹងអំពីលក្ខណៈនៃស-២១ ជាពិសេសគឺលក្ខណៈឋានានុក្រម ហើយនិងការអនុវត្តទៅលើវិន័យដ៏តឹងតែងដែលអនុវត្តដោយជនជាប់ចោទ ។ តើលោកនៅតែប្រកាន់ជំហរទៅលើការវាយតម្លៃដូច្នេះដែរឬទេ?

**ឆ៖** បាទ,ជាការពិត ខ្ញុំគឺដប់ឆ្នាំមក គឺសៀវភៅនេះបានផលិតចេញហើយបានបោះពុម្ពផ្សាយដូច្នេះ ខ្ញុំគ្មានអ្វីផ្លាស់ប្តូរទៅនឹងជំហររបស់ខ្ញុំក្នុងការវាយតម្លៃទៅលើចំណុចនេះទេ ។

**សៈ** ខ្ញុំសូមអរគុណដែលថាលោកមិនផ្តោតអារម្មណ៍ ផ្តោតការយកចិត្តទុកដាក់ស្រាវជ្រាវលើ ស-២៤ និង ព្រៃស ។ ក្រៅពីស-២១ នៅក្នុងសៀវភៅរបស់លោក ។ ប៉ុន្តែ នៅក្នុងការស្រាវជ្រាវរបស់លោកថា តើលោកចាត់ទុកថាព្រៃស វាមានលក្ខណៈសម្បត្តិដូចនឹងស-២១ ដែរឬទេ?

**ឆ៖** គឺមានមួយចំនួន ។ ប៉ុន្តែ គឺនៅទីនោះ មន្ទីរស-២៤ គឺមានមនុស្សដែលត្រូវគេដោះលែង ។ ហើយនៅព្រៃសមិនមែនជាមន្ទីរសម្លាប់នោះទេ ហើយមានការដោះលែងមនុស្សចេញចូលនៅទីនោះ ។ ហើយវាជាកន្លែងអប់រំតែប៉ុណ្ណោះ ។ ហើយវាមានលក្ខណៈសម្បត្តិមួយចំនួនតូចប៉ុណ្ណោះ ដែលវាស្រដៀង ទៅនឹងស-២១ ។

**សៈ** នៅក្នុងទំព័រ២២ ក្នុងសៀវភៅរបស់លោក លោកបានផ្តោត ឬក៏បានផ្តោត ឬក៏បានលោកបានលើកឡើងអំពីអត្តចរិតរបស់ជនជាប់ចោទ និងការទទួលខុសត្រូវជនជាប់ចោទ ។ តើលោកធ្លាប់ជួបនិងសម្ភាសន៍ជនជាប់ចោទនៅពេលណាមួយដែរឬទេ?

**ឆ៖** គឺខ្ញុំមិនដែលទេ ។

[០៩:២៨:១២]

**ស៖** លោកបានពិព័ណ៌នាថា គាត់គឺជាបុគ្គលមួយរូបទទួលខុសត្រូវស-២១ ឌុច ធ្វើការងារយ៉ាងហ្មត់ចត់នៅក្នុងការដឹកនាំប្រតិបត្តិការស-២១ ។ បទពិសោធន៍ពីការបង្រៀនរបស់គាត់មានសារៈសំខាន់ គាត់អាចធ្វើការរក្សារឯកសារ ហើយគាត់អាចដោះស្រាយបញ្ហាផ្សេងៗ ហើយគាត់ទទួលការគោរព និងធ្វើការដាក់វិន័យទៅលើបុគ្គលិករបស់គាត់ ។ គាត់ខ្លាំងក្លា ហើយគាត់ច្បាស់លាស់ ហើយគាត់ធ្វើអ្វីដែលគាត់និយាយ ហ៊ីម ហ៊ុយ ដែលជាអតីតអ្នកយាមបានលើកឡើង ។ ឌុច គឺនៅពេលដែល ឌុច គឺជាមនុស្សមួយគាត់ខ្លាំងក្លា ។ ហើយនៅពេលដែលសួរថា គាត់យ៉ាងម៉េចដែរ គឺគាត់ហ្មត់ចត់ ហើយគាត់គឺមានហេតុផលគ្រប់គ្រាន់ ។ ហើយនៅក្នុងទំព័រ២២ នោះផងដែរ លោកបានលើកឡើងថា គឺគាត់មានគំរូមួយសម្រាប់បុគ្គលិក ហើយមានការលើកឡើងអំពីផែនការរួមផងដែរ ។ ថាតើខ្ញុំនិយាយ នេះត្រឹមត្រូវដែរឬទេ? ក្នុងការយោងទៅលើការសន្និដ្ឋានរបស់លោកទាក់ទងទៅនឹងអត្តចរិតរបស់ជនចាប់ចោទ ដោយធ្វើការដកស្រង់ចេញពីការសម្ភាសន៍របស់លោក និងការស្រាវជ្រាវរបស់លោកចេញពីមន្ទីរឯកសារ ផ្សេងៗនៅបណ្ណសារ?

**ឆ៖** គឺខ្ញុំអ៊ីចឹងមែន ខ្ញុំបញ្ជាក់អ៊ីចឹងមែន ។

**ស៖** នៅក្នុងរយៈពេលដប់ឆ្នាំ ថាតើមានឯកសារសៀវភៅណាផ្សេងដែលលោកបានអាន ហើយវាអាចធ្វើឲ្យផ្លាស់ប្តូរនៅការយល់ឃើញរបស់លោក ចំពោះអត្តចរិករបស់ជនជាប់ចោទដែរឬទេ?

**ឆ៖** គឺអត់ទេ ។

**ស៖** សូមអរគុណ ។ នៅក្នុងទំព័រ៤០ លោកបានលើកឡើងអំពីស-២១ ថាវាជាបន្ទប់រង់ចាំស្លាប់ គឺជាចម្លើយមួយដែលជនជាប់ចោទគាត់យល់ស្របដែរ ។ តើលោកអាចពិពណ៌នាបន្ថែមទៅលើចំណុចនេះដែរឬទេ ដោយពិពណ៌នាខ្លីៗ?

**ឆ៖** បន្ទប់រង់ចាំ គឺជាកន្លែងរង់ចាំ ហើយខ្ញុំប្រើពាក្យថា “*វេតធីង រូម*” ដោយសារតែអ្នកដែលរង់ចាំនោះនៅស-២១នោះ គឺយើងឃើញថាវាមានអ្នករស់រានជីវិតតិចប៉ុណ្ណោះ ហើយវាមានការស្លាប់ច្រើន ហើយអ្នកដែលខ្លះដែលគាត់បានដឹង ហើយអ្នកខ្លះទៀតគាត់មិនបានដឹងទៅលើករណីនេះ ។ ប៉ុន្តែជនជាប់ចោទដែលជាអ្នកគ្រប់គ្រងស-២១ នេះគាត់ដឹងច្បាស់លាស់ណាស់ ហើយគាត់យល់អំពីការពិពណ៌នារបស់ខ្ញុំទៅលើចំណុចនេះ ។ ដូច្នេះហើយ គឺអ្វីដែលគាត់ឡើងក៏ត្រឹមត្រូវដែរ ។

**ស៖** សូមអរគុណ នៅក្នុងជំពូកមួយលោកបានវិភាគពីទ្រឹស្តីរបស់របបនោះទាក់ទងអំពីខ្នាំងទំព័រ៤១ ទៅដល់៧៦ នៅចំណុចផ្តើមលោកបានរៀបរាប់ពីស-២១ ថាជាស្ថាប័នស្វយ័ត ដែលមានបេសកកម្ម

គឺថាដោះស្រាយបញ្ហា និងកម្ទេចខ្មាំងរបស់មជ្ឈិមបក្ស ។ តើក្នុងន័យអ្វីដែលលោកនិយាយថា កំណត់ខ្មាំងនោះ? តើលោកមានបំណងចង់បញ្ជាក់ថាតើជាអំពើ ឬក៏តួនាទីសំខាន់របស់ស-២១ ក្នុងការតាមរកហើយនិងចាប់ពួកខ្មាំង ឬក៏លោកប្រើពាក្យហ្នឹងដើម្បីរៀបរាប់ពីតួនាទីរបស់ជនជាប់ចោទអំពីបុគ្គលិកលក្ខណៈ និងការងាររបស់គាត់ដើម្បីកំណត់អំពីខ្សែខ្មាំង និងខ្សែក្បត់នោះ ឬអ្វី?

**ឆ៖** តាមពិតនោះខ្ញុំមិនចង់មានន័យថាស-២១ មានតួនាទីអ្វីនៅក្នុងការចាប់នោះទេ ប៉ុន្តែខ្ញុំបានការកំណត់ខ្មាំងនោះ គឺនិយាយឲ្យចំទៅ គឺការសង្ស័យទៅលើមនុស្សដែលបានគេនាំយកមកស-២១ គឺជាការងាររបស់អ្នកសួរចម្លើយ ហើយដែលគេធ្វើការនៅក្រោមការដឹកនាំរបស់ជនជាប់ចោទ ។ នេះហើយគឺជាការកំណត់ថាខ្មាំងជាក់លាក់នោះ គឺវាចេញមកពីអត្ថបទ ឬក៏ឯកសារផ្សេងដែលមិនសូវមានសារប្រយោជន៍ក្នុងពេលនេះទេ ប៉ុន្តែការកំណត់នោះ គឺក្រដាសស្នាមត្រូវបានបញ្ជូនទៅថ្នាក់លើដោយមានភស្តុតាង ហើយនិងមានការសង្ស័យអំពីជនដែលគេសង្ស័យថាជាខ្មាំង ។

**ស៖** សូមអរគុណ លោកបានសរុបអំពីអ្វីមួយចំនួនដែលនៅទំព័រ៤១នោះថា “ស-២១ ប្រហែលគឺជា១ស្ថាប័នដ៏មានឥទ្ធិពលបំផុតក្នុងប្រទេស ។ នៅក្នុងមជ្ឈិមបក្សបានយល់ថា អ្នកណាជាខ្មាំងនោះ គឺគេកំណត់ឲ្យស-២១ ក៏ជាស្ថាប័នដ៏សំខាន់មួយដែរ” ។ តើនេះនៅតែជាសេចក្តីសន្និដ្ឋានរបស់លោកដែលទាក់ទងទៅនឹង ថាតើមានសន្តិបាលផ្សេងទៀតក្រៅពីស-២១ ដែរឬទេ?

សូមអភ័យទោសលោកសាស្ត្រាចារ្យ នេះគឺជាប្រព័ន្ធសំឡេងចម្លែកបន្តិច សូមលោករង់ចាំដល់ភ្លើងក្រហម ។

[០៩:៣៤:១៨]

**ឆ៖** គឺថាមិនឆ្លើយភ្លាមៗទេ ដោយសារថាលោកស្រីនិយាយអង់គ្លេសជាមួយខ្ញុំ សូមអភ័យទោសដោយសារខ្ញុំមានកំហុស ប៉ុន្តែដើម្បីឆ្លើយខ្ញុំសូមគិតឡើងវិញបន្តិច ។ បាទ គឺព័ត៌មានផ្សេងៗដែលថាមានគុកផ្សេងៗទៀតនៅក្នុងប្រទេស គឺមិនមានទំហំឯកសារដូចគ្នានេះទេ ហើយមិនបាន១សួរចម្លើយអ្នកទោសកម្រិតដូចគ្នាស-២១ ទេ ហើយគុកទាំងនោះ គឺមិនមានជាលក្ខណៈសកម្ម ។ ដូចថាអ្នកទោសហ្នឹងសុទ្ធតែជាកម្មាភិបាលរបស់ខ្មែរក្រហមនោះទេ ។ ប៉ុន្តែ គុកផ្សេងៗនៅក្នុងផ្នែកផ្សេងទៀតមិនដឹកនាំផ្ទាល់ដោយមេដឹកនាំកំពូលដូចដែលស-២១ ដែលដឹកនាំដោយ សុន សេន ឬប្រហែលដោយ នួន ជា ដែលធ្វើការនៅខាងលើជនជាប់ចោទនោះ ។ អ៊ីចឹងហើយប្រសិទ្ធភាពនៃគុកផ្សេងៗទៀតនោះ យើងអាចប្រាប់ថាវាមានប្រសិទ្ធភាពដូចម្តេចបានឲ្យច្បាស់ទេ ពីព្រោះមិនមានឯកសារនៅសេសសល់ច្រើន

ប៉ុន្តែ បើតាមយន្តការនោះគឺថា វាអាចនឹងមានប្រសិទ្ធភាព ។ បើនិយាយពីទួលស្លែងវិញ គឺយើងមានទូរស័ព្ទ មានអង្គុលីលេខ ហើយតាមពិតគេមិនតម្រូវឲ្យមានការយកចិត្តទុកដាក់ជាប្រចាំថ្ងៃ ដូចដែល ស-២១ ទទួលមានទេ ចំពោះទទួលបានទេ ចំពោះគុកផ្សេងៗទៀតនោះ ។

**ស៖** លោកក៏បានបញ្ជាក់ដែលថា មជ្ឈិមបក្សក៏បានបញ្ជាក់ថាមានខ្មាំងនៅគ្រប់ទីកន្លែង ហើយក៏មានការព្រួបារម្ភខ្លាំងចំពោះផ្ទៃក្នុងជាជាងខ្មាំងពីខាងក្រៅ ក្នុងពេលដែលបដិវត្តន៍ចេះតែវិវឌ្ឍន៍ទៅមុខនោះ ។ តើត្រឹមត្រូវទេ លោកផ្តល់ការសង្កេតថា ខ្មាំងផ្ទៃក្នុងហ្នឹង គឺវានាំឲ្យមានដំណាក់កាលពីរធំៗនៃការបោសសម្អាតនោះ?

**ឆ៖** បាទ, ខ្ញុំគិតដូច្នោះ ។ ចំណុចទីមួយនោះ នៅខែកញ្ញា ឆ្នាំ១៩៧៥ រហូតទៅដល់ខែកញ្ញា ឆ្នាំ ១៩៧៦ ហើយសង្កត់ធ្ងន់ទៅលើពួកអ្នកដែលមានការពាក់ព័ន្ធទៅនឹងរបបចាស់ ហើយការបោសសម្អាតទីពីរនៅខែតុលា ឆ្នាំ១៩៧៧ រហូតដល់ចុងបញ្ចប់នៃរបបនោះ ។

**ស៖** តើដែលដាក់បញ្ចូលនូវអ្នកដែលគេសង្ស័យថា ជាអ្នកប្រឆាំងនឹងបក្ស ។ តើហ្នឹងជាសេចក្តីសន្និដ្ឋានត្រឹមត្រូវឬទេ?

**ឆ៖** ការបោសសម្អាត ទីមួយនៅក្នុងផ្ទៃក្នុងរបបនោះកើតឡើងចុងឆ្នាំ១៩៧៦ ហើយស-២១ ទួលស្លែងនោះ ។ ដំណាក់កាលទីពីរនៃការបោសសម្អាតនោះ គឺទាក់ទងទៅការបោសសម្អាតនៅកម្មាភិ-បាលនៅភូមិភាគផ្សេង និងភូមិភាគពាយព្យ ហើយភូមិភាគពូព៌ា ហើយនិងអ្នកក្រោមបង្គាប់របស់គេផងដែរ ដើម្បីបោសសម្អាតទាំងអស់ គឺថាបោសសម្អាតឲ្យអស់ គេប្រើពាក្យខ្មែរចំពោះអ្នកណាដែលសង្ស័យដែលជាប់និន្នាការ ឬខ្សែនោះ ហើយថាគេយល់ថាជាខ្មាំងរបស់បដិវត្តន៍ ។

[០៩:៣៧:៥០]

**ស៖** ខ្ញុំនឹងសួរអំពីការសង្ស័យរបស់លោក អំពីថាការបោសសម្អាតទាំងអស់នោះ គឺពាក់ព័ន្ធទៅនឹងការសង្ស័យត្រឹមត្រូវអំពីផែនការផ្តួលរំលំរបបហ្នឹង គឺទាក់ទងទៅការចូលរួម ចូលដៃជាមួយវៀតណាម ដើម្បីធ្វើនោះ ។ តើនៅក្នុងទំព័រ៥៧ ដែលលោកបានសរសេរពីរឿងហ្នឹង?

**ឆ៖** បាទ, ខ្ញុំពិនិត្យឃើញថាវាមិនអាចទៅរួចទេ ដែលថាមិនមានអ្នកណាម្នាក់នៅក្នុងកម្ពុជាប្រជាធិបតេយ្យ ដែលថាគ្មានអ្នកណាម្នាក់អាចនឹងផ្តួលរបបនោះបានទេ ប៉ុន្តែមិនអាចគិតដល់បាន គឺថាគ្មានអ្នកណាម្នាក់អាចចូលរបស់កម្ពុជាប្រជាធិបតេយ្យ ដែលថាពេញចិត្តឲ្យកម្ពុជាដំណើរការមួយដែលគេជឿថាវៀតណាម គឺជាអាចដឹកនាំក្រោយពីគេទទួលបានជោគជ័យក្នុងកុម្មុយនីស្ត ។ ប៉ុន្តែ ខ្ញុំមិន

ប្រកាន់ជំហរថាអំពីការឃោសនាចំពោះការគំនិតដែលគេចោទប្រកាន់នោះវាត្រូវតែមាន ប៉ុន្តែវាពិបាកនឹងជឿបានក្នុងសម័យនោះ ។

**ស៖** តាមពិតនៅចាប់ពី១៩៧៦មក លោកបានកត់សម្គាល់ថាមានការកែប្រែនៅក្នុងសមាសភាពនៃអ្នកទោសនៅស-២១ ហើយលោកបានកត់សម្គាល់ថាមានការកែប្រែអំពីការចោទប្រកាន់ដែលទាក់ទងទៅនឹងការពាក់ព័ន្ធនិន្នាការពាក់ព័ន្ធនឹងខាងវៀតណាម ដែលថា មានការចោទប្រកាន់ឲ្យវាមានការបោសសម្អាតខ្មាំងស៊ីរូងផ្ទៃក្នុងដែលថាជាទិសដៅទីពីរនោះ ។

**ឆ៖** បាទ, ខ្ញុំគិតថានៅក្នុងដំណាក់កាលទីពីរនេះ ដើម្បីហៅអ្នកណាម្នាក់ថាជាយួន ជាវៀតណាមនៅក្នុងរបបនោះ មិនមែនថាអ្នកហ្នឹងជាវៀតណាមទេ ទាល់អ្នកណាជំទាស់ ឬក៏ប្រឆាំងនឹងរបបនោះ ដែលគេហៅថា *សេអ៊ីអា* ឬក៏ថាយួននោះ ។ ប៉ុន្តែបន្ទាប់ពីខែកញ្ញា ឆ្នាំ១៩៧៦ ដែលថាវាមានការលំបាកនៅក្នុងបដ្ឋិមបក្សនៅក្នុងរដូវក្តៅឆ្នាំ១៩៧៦ គឺមានកម្មាភិបាលជាន់ខ្ពស់ពីភូមិភាគបូព៌ានោះក៏ត្រូវបានបញ្ជូនមកស-២១ គឺថាអ្នកដែលជាន់ខ្ពស់នោះ ដែលមានការពាក់ព័ន្ធពីមជ្ឈិមបក្សផងដែរ ដែលទាក់ទងថា ការបំផុសបំផុលប្រឆាំងបក្សដែលថា ក្រោយមកមានជម្លោះព្រំដែនជាមួយវៀតណាម មានកម្មាភិបាលជាន់ខ្ពស់មួយចំនួនត្រូវបានបង្កសង្គ្រាមជាមួយវៀតណាម ហើយនិងសង្គ្រាមស៊ីវិលជាមួយដោយមានការដឹកនាំពីវៀតណាម ហើយអ្នកទាំងនោះគឺមានការសង្ស័យពីមជ្ឈិមបក្សថា អ្នកទាំងហ្នឹងអាចជាប់ខ្សែ គេសង្ស័យថាជាអ្នកជួយវៀតណាម ពេញចិត្តទៅខាងវៀតណាមជាងកម្ពុជា ។

[០៩:៤១:២៩]

**ស៖** ហើយការកំណត់ទិសដៅអ្នកទាំងអស់នោះដែលគេយល់ថាអ្នកហ្នឹងមានជាប់និន្នាការវៀតណាម គឺថាអាចនឹងជាការញុះញង់ឲ្យមានជម្លោះប្រដាប់អាវុធនៅតាមព្រំដែនជាមួយវៀតណាម ។ ខ្ញុំដកស្រង់ទំព័រ៦១ គឺថាជនស៊ីវិលរាប់រយ គឺថាត្រូវបានស្លាប់ដោយសារការប៉ះទង្គិចចម្បាំងនោះ ហើយមិនបានផ្សព្វផ្សាយទូទាំងប្រទេសទេ ។ តើត្រឹមត្រូវទេ ការប៉ះទង្គិចគ្នាផ្លូវយោធាហ្នឹង គឺថាបង្កើតឲ្យមានការសង្ស័យអំពីទំនាក់ទំនងនៃអ្នកនៅភូមិភាគនោះជាមួយវៀតណាមនោះ?

**ឆ៖** បាទ, ពិតហើយ ។

**ស៖** តើលោកអាចជួយពន្យល់យើងខ្ញុំថាហេតុអ្វីបានមានការប៉ះទង្គិចផ្លូវយោធានោះមិនត្រូវបានផ្សព្វផ្សាយ ថាហេតុអីមិនផ្សព្វផ្សាយនោះ?

**ឆ៖** ពួកវៀតណាម ទទួលការជោគជ័យគឺថា តិចជាងពីរឆ្នាំ គេមិនមាននយោបាយដើម្បីធ្វើសង្គ្រាមជាមួយវៀតណាមទេ ។ អ៊ីចឹងហើយ ខ្ញុំមិនដឹងច្បាស់អំពីការដឹកនាំរបស់វៀតណាមគេគិតម៉េចទេ ប៉ុន្តែការចំណុចនេះ គឺជាគំនិតមេដឹកនាំក្មេងៗដែលថា អាចនឹងចេញមកអំពីការយល់ជ្រុល ហើយគឺថាបើកម្ពុជាមិនបានផ្សព្វផ្សាយអំពីការវាយប្រហារនេះទេ ពីព្រោះគិតថាការវាយប្រហារនៅព្រំដែនមានការឈ្លានពានជាច្រើន គេមិនចង់ផ្សាយនោះទេ ឮគេថាការវាយប្រហារទៅលើវៀតណាម ប៉ុន្តែគេមានចំនួនច្រើននៅក្នុងខ្មែរនៅក្នុងនោះដែរ ហើយគេអាចនឹងធ្វើឲ្យមានការភាន់ច្រឡំ ប៉ុន្តែខ្មែរភាគតិចនឹងអាចនឹងចូលមកកម្ពុជាប្រជាធិបតេយ្យ និងគាំទ្រ ហើយអាចនឹងគេទាញយកកម្លាំងទៅយកឈ្នះលើវៀត-ណាមខាងត្បូង ។ នេះហើយជាចំណុចមួយ គឺពូជសាសន៍ខ្លួនឯង ។ ហ្នឹងគឺខ្ញុំបានយល់តាមសម្ភាសន៍នោះគឺថា ការវាយប្រហារហ្នឹងគឺធ្វើឡើងពេលយប់ មិនដឹងថាអ្នកណាសម្លាប់ទេ ។ ក្នុងករណីភាគច្រើនហ្នឹង គេមានសម្លាប់ជនជាតិខ្មែរដែលនៅក្នុងភូមិដែលថា មាននិគមជនវៀតណាម ដែលបានរត់គេចខ្លួនទៅក្នុងទីក្រុងហ្នឹង គឺជាសោកនាដកម្មមួយនៅក្នុងការវាយប្រហារហ្នឹង ប៉ុន្តែគ្មានភាគីណាមួយទទួលស្គាល់ថាមានការវាយប្រហារនោះទេ ប៉ុន្តែវៀតណាមក៏គេលាក់ ហើយកម្ពុជាក៏គេសង្ឃឹមថានឹងលាក់កំបាំងហ្នឹងបាន ។

[០៩:៤៥:៣៨]

**ស៖** នៅក្នុងដំណាក់កាលនោះដែរ លោកបានរៀបរាប់អំពីការកម្ទេច ឬបោសសម្អាតទៅពួកអ្នកការទូត ហើយនិងពួកបញ្ញវន្តនៅក្នុងឆ្នាំ១៩៧៦ ក្នុងចំណុចមួយលោករៀបរាប់ពីការបោសសម្អាតវណ្ណៈទាំងអស់ហ្នឹង ហើយនិងអ្នកទាំងអស់នោះ តើលោកអាចនិយាយបានដូចម្តេច?

**ឆ៖** អ្នកការទូតទាំងអស់នោះ គឺអ្នកដែលជាអ្នកបានរស់នៅក្នុង-- នៅខាងក្រៅស្ថាប័នស្វយ័ត ហើយគេអាចបង្កើតកិច្ចព្រមព្រៀងជាមួយបរទេស ។ ប៉ុន្តែពួកបញ្ញវន្តនោះ គឺមិនមែនគេតាមចាប់ដោយសារតែគេជាបញ្ញវន្តនោះទេ ។ ប៉ុន្តែសមាជិកជាន់ខ្ពស់របស់បក្សនោះ ដូចជា កុយ ធួន គឺក៏គេចាប់ផ្តើមសង្ស័យគាត់ជាអ្នកមានការអប់រំខ្ពស់ ហើយមានមិត្តភក្តិមួយចំនួន ។ ហើយគាត់បានចូលបក្ស ហើយភាគច្រើនសុទ្ធតែជាអ្នកមានការអប់រំខ្ពស់ដែលគេហៅថា ជាបញ្ញាជនខ្មែរដែលៗទទួលការអប់រំនៅក្នុងប្រទេសបារាំងជាដើមហ្នឹង ។ អ៊ីចឹងហើយព័ត៌មាន គឺវាចាប់សាយភាយចេញអំពី កុយ ធួន ហើយកត្តាផ្សេងៗដែលគេហៅថាបញ្ញវន្តជាកម្មាភិបាលដែលមានអប់រំខ្ពស់ហ្នឹង គឺត្រូវបញ្ជូនភូមិភាគពាយព្យដើម្បីគ្រប់គ្រងតំបន់នុ៎ងដែលជាតំបន់ដែលមានប្រជាជនថ្មី ពួក១៧ មេសា ដែលមិនមានបទពិសោធន៍ និង

លទ្ធភាពក្នុងធ្វើការងារកសិកម្មនោះ គឺថាវាមានការ-- អ៊ីចឹងគឺថាវាមានអំពើសោកនាដកម្មច្រើននៅកន្លែងហ្នឹង ។ ហើយខ្ញុំសឹងតែមិនអាចជឿបានថា ដែលអាចមានអំពើបែបហ្នឹងគឺការពន្លឿនឲ្យមានអំពើឃោរឃៅបែបនោះ ។

[០៩:៤៦:៤៨]

បន្ទាប់ពីគំរូនៅរុស្ស៊ីនៅឆ្នាំ១៩៣០ នោះៗគឺជាមេដឹកនាំដែលត្រូវតែជាកម្មាភិបាល ។ ហើយនៅភូមិភាគពាយព្យ គឺត្រូវតែចាត់ការទៅលើពួកបញ្ញវន្តដែលជា ១៧ មេសា នោះ ។

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ័ល័រ សូមលោកនិយាយឲ្យបានយឺតជាងនេះបន្តិច ។ ដើម្បីពន្យល់លោកអំពីបញ្ហាបច្ចេកទេសនៅទីនេះ លោក ដេវីដ ឆេនដ័ល័រ ចម្លើយរបស់លោកត្រូវបានបកទៅខ្មែរហើយនិងបកទៅជាបារាំង នឹងត្រូវប្រើពេលបន្តិចដើម្បី-- ដូច្នេះលោកត្រូវមានប្រសាសន៍ឲ្យយឺតដូចដែលខ្ញុំនិយាយឥឡូវនេះឯង ឬក៏លោកអាចផ្អាកបន្តិច ដោយសារលោកមានការលំបាកដោយសារលោកគិតហើយនិយាយ ។ ប៉ុន្តែ សក្ខីភាពរបស់លោកមានតម្លៃណាស់សម្រាប់អង្គជំនុំជម្រះនេះ ។ នៅទំព័រ៧៤ នៃសៀវភៅរបស់លោក លោកបាននិយាយអំពីការបោសសម្អាតជាចុងក្រោយ នៅពេលដែលថា ឈ្លើយសឹកវៀតណាមជិតមួយរយនាក់នោះ ត្រូវបានគេបោសសម្អាត ឬក៏សម្លាប់នៅក្នុងឆ្នាំ១៩៧៨ ហើយនៅពេលនោះ គឺឧបនាយករដ្ឋមន្ត្រី ហើយនិង ចេង អន ជាឧបនាយករដ្ឋមន្ត្រីខាងឧស្សាហកម្មត្រូវបានបោសសម្អាតដែរ ដោយសង្ស័យថា គាត់បានកៀងគរប្រមូលនូវកម្មកររោងចក្រពីមុនៗមក ។ ថាតើលោកផ្អែកលើអ្វីដើម្បីនឹងបញ្ជាក់ការសន្និដ្ឋានដែលថា ការចាប់ខ្លួន វន វ៉េត ហើយនិង ចេង អន នេះគឺពាក់ព័ន្ធទៅនឹងការបោសសម្អាតបុគ្គលិកកម្មករមួយចំនួនភាគច្រើនពីមុននោះ?

[០៩:៤៩:២៨]

**ឆ៖** ហើយខ្ញុំទទួលបានព័ត៌មានពីឯកសារការបោសសម្អាតនៅក្នុងឆ្នាំ១៩៧៨ នោះ គឺត្រូវបានថយល្បឿនទៅវិញនៅស-២១ ប៉ុន្តែក្រុមមួយទៀតត្រូវបានតម្រង់ជាគោលដៅនោះ ដែលថាក្រុមដែលគេបានប្រមូលនូវបុគ្គលដែលមានកម្លាំងធ្វើការ ដូចជា កម្មកររទេះភ្លើង ហើយនិងកម្មករខាងឧស្សាហកម្មដែលគេៗបោសសម្អាតក្រោយមក ។ នេះជារបៀបមួយដែលជាការផ្អាកមួយដែលថា របបនោះគិតថាវាជាអាចនឹងជាលទ្ធភាពមួយការកៀងគរប្រមូលអ្នកទាំងអស់នោះ គឺដើម្បីៗផ្តួលរំលំនៅរបបហ្នឹង។

**ស៖** ដោយមានការៗយល់ព្រមនោះ សូមឲ្យខាង *អេវី(AV)* គឺបញ្ចាំងឯកសារ003310130 ។ សូមអរគុណ ។

លោកបានឃើញនៅក្នុងគំនូសនេះដែលបានដាក់ជាសំណុំរឿងក្នុងរឿងក្តី នៅក្នុងឆ្នាំ១៩៧៦ចេញពីឯកសារដែលយើងប្រមូលនោះ គឺមានមួយពាន់ប្រាំបួនរយហុកសិបបីនាក់ត្រូវបានចាប់ខ្លួន ហើយបានកើនរហ័សនៅក្នុងឆ្នាំ១៩៧៧ រហូតទៅដល់ ប្រាំពាន់ប្រាំពីរយកៅសិបនាក់ដែលគេចាប់ខ្លួន ។ ហើយចុះមកវិញ គឺមិនចុះដល់កម្រិតក្នុងឆ្នាំ៧៦ ទេ ប៉ុន្តែចុះមកដល់ ពីពាន់ប្រាំបីរយចិតសិបប្រាំបួន នៅក្នុងឆ្នាំ១៩៧៨ តើក្រាហ្វិកនេះស្របទៅតាមអ្វីដែលលោកធ្វើការវាយតម្លៃអំពីការបោសសម្អាតនៅក្នុងដំណាក់កាលបីឆ្នាំហ្នឹងដែរឬទេ?

**ឆៈ** បាទ, ពិតអ៊ីចឹងមែន ។

**សៈ** សូមអរគុណ សូមដកឯកសារហ្នឹងចេញវិញ។

លោកបានរកឃើញឯកសារភស្តុតាងមួយចំនួននៅក្នុងចុងឆ្នាំ១៩៧៨ ព្រោះថាអាចនឹងជាការពង្រឹងការបោសសម្អាតដើម្បីបញ្ចប់កាលហ្នឹង ។ ប៉ុន្តែនៅទំព័រ៧៥ នៅក្នុងសៀវភៅរបស់លោកៗបានធ្វើការសន្និដ្ឋានថា អំពើនៃការភ័យខ្លាចសាយភាយទូទាំងកម្ពុជាប្រជាធិបតេយ្យ គឺជាបាតុភូតមួយហើយត្រូវឲ្យមានការចាប់នូវខ្មាំងជាបន្តបន្ទាប់ ។ កាលណាខ្មាំងទាំងអស់នេះបានបង្កប់នៅក្នុងៗបក្សតូចៗ សាខាងបក្សដែលមិនសូវមានជំនាញ ហើយនៅក្នុងប្រជាជន ។ ហើយការប៉ុនប៉ងដើម្បីបោសសម្អាតខ្មាំងទាំងអស់ គឺអាចនឹងមានផលអាក្រក់បំផុត ហើយ ឌុច ហើយនិងអ្នករួមការងាររបស់ខ្លួនត្រូវបានគេប្រាប់ថា គេ-- ហើយព្យាយាមបន្ថយនូវអំណាចប្រសិទ្ធភាពយោធា ហើយនិងរចនាសម្ព័ន្ធសង្គមនៅកម្ពុជា ហើយបំផ្លាញដល់បក្ស ។ ម៉ាស៊ីនសម្លាប់នៅស-២១ មិនបានឈប់សម្រាកអ្វីនោះទេពីព្រោះថាមានការភ័យខ្លាចរបស់មជ្ឈិមបក្សនោះវាគ្មានកម្រិតព្រំដែន ។ នេះជាការដកស្រង់មួយក្នុងសៀវភៅរបស់លោក ។

តើខ្ញុំនិយាយត្រូវទេ ផ្អែកទៅលើសេចក្តីដកស្រង់នេះ ថាលោកបានចាត់ទុកថា ប្រតិបត្តិការនៅស-២១ ដើម្បីឲ្យស្របទៅតាមការបំពេញនូវគោលដៅរបស់មជ្ឈិមបក្សក្នុងការត្រួតត្រាគ្រប់គ្រងទៅលើខ្មាំងរបស់ខ្លួននោះ?

[០៩:៥៤:២៩]

**ឆៈ** បាទ, ខ្ញុំគិតអ៊ីចឹង ។

**សៈ** លោកបានពិភាក្សាយ៉ាងលម្អិតនៅក្នុងអ្វីដែលលោកផ្អែកថា អ្វីជាបណ្ណសារនៅស-២១ នៅទំព័រ៤១ ។ បណ្ណសារទាំងអស់នោះ គឺវាមិនមែនជាលក្ខណៈពិសេសនោះទេ ។ លោកបានរៀបរាប់ថា

ជាផ្នែកមួយ ជាឯកសារដ៏ទូលំទូលាយនៃកម្ពុជាប្រជាធិបតេយ្យ ។ តាមទស្សនៈរបស់លោក តើបណ្ណសារទាំងអស់នៅស-២១ វាមាន១លក្ខណៈលម្អិតជាងអ្វី១ដែលជាឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ ឬក៏លោកមិនអាចវាយតម្លៃបានដោយហេតុថា មិនមានលទ្ធភាពនឹងប្រមូលរកឯកសារផ្សេងទៀតនៃមន្ទីរសន្តិបាលរបស់កម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ចម្លើយខ្ញុំច្បាស់ថា បណ្ណសារនៅស-២១ គឺវាមានលក្ខណៈពិស្តារច្រើនជាងមន្ទីរផ្សេងៗទៀត គឺវាបណ្ណសារមួយចំនួនច្រើនមកពីក្រសួងការពារប្រទេសហ្នឹង គឺជាឯកសារដ៏ទូលំទូលាយដ៏ច្រើនហើយជាបណ្ណសារដែលនិយាយអំពីកិច្ចការបរទេស ពាណិជ្ជកម្មបរទេសផងដែរ ។ ហើយមានបណ្ណសារផ្សេងដែលបានបាត់បង់ យើងមិនអាចរកបាន ឬក៏លាក់ទុកនៅកន្លែងផ្សេង ឬក៏យើងមិនអាចរកបាន ដូច្នេះខ្ញុំមិនមានគំនិតថា ទំហំឯកសារនោះមានប៉ុនណានោះទេ ។ ប៉ុន្តែខ្ញុំគិតថា បណ្ណសារទាំងអស់នេះដូចជារបស់មជ្ឈិមបក្សនោះ គឺថាមិនមានលក្ខណៈពិស្តារទូលំទូលាយដូចដែលមាននៅក្នុងបណ្ណសារដែលមាននៅក្នុងបណ្ណសាររបស់ទួលស្លែងទេ ។ អ៊ីចឹងឯកសារដែលយើងមាន យើងធ្វើការនោះ គឺជាឯកសារដែលមានលក្ខណៈរសើប គឺវា-- គិតថាវាមានរាប់ពាន់១ទំព័រ រាប់រយទំព័រដែលគេបានចងក្រងនៅក្នុងស-២១ ។

[០៩:៥៦:៤៨]

**ស៖** តើខ្ញុំត្រូវទេ ដែលខ្ញុំយល់ថាទៅតាម ក្រោយដឹកនាំរបស់ជនជាប់ចោទ គឺថាបណ្ណសារទាំងឡាយនៅស-២១ ត្រូវបានរក្សាទុកតាមរបៀបមួយត្រឹមត្រូវតាមវិជ្ជាជីវៈ ហើយវាលក្ខណៈលម្អិតពិស្តារយ៉ាងគ្រប់គ្រាន់នោះ?

**ឆ៖** បាទ, លោកស្រីអាចនឹងនិយាយបែបនោះបាន ។

**ស៖** លោកបានសន្និដ្ឋាននៅទំព័រ៤៩នៃសៀវភៅនោះ គឺថាបណ្ណសាររបស់ស-២១ ខ្លឹមសាររបស់វានោះគឺជាការសម្ងាត់ ប៉ុន្តែខ្លឹមសារភាគច្រើននៃចម្លើយសារភាពប្រហែលជាមិនពិតទេ ។ ហើយអ្នកទោសទាំងអស់ត្រូវបានគេសម្លាប់ តើលោកអាចសន្និដ្ឋានបន្ទាប់ទៅទៀត ថាតើគោលបំណងរបស់ស-២១ ដែលគេធ្វើបណ្ណសារនោះ គឺដើម្បីអ្វី?

**ឆ៖** នេះគឺជាឯកសារ ចម្លើយដែលខ្ញុំបានគិតនោះ គឺជាសំណួរដែលពិបាកនឹងអាចនឹងឆ្លើយ ។ ប្រហែលជាជនជាប់ចោទ គាត់អាចគិតថាតើគោលបំណងនេះការផលិតឯកសារទាំងហ្នឹងដើម្បីគោលបំណងអ្វី? ដូច្នេះចំណុចមួយជាគោលបំណងដែលក្នុងការចងក្រងឯកសារទាំងអស់នោះ គឺដើម្បីបង្ហាញ

ឲ្យមេដឹកនាំថា ស-២១គឺជាទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់ហ្មត់ចត់នូវឯកសារ ហើយជាស្ថាប័នមួយដ៏សំខាន់របស់រដ្ឋាភិបាលនៅក្នុងប្រទេសដែលលក្ខខណ្ឌនៅក្នុងកន្លែងផ្សេងទៀតដែលថា មិនមានឯកសារត្រឹមត្រូវដូចស-២១ ដើម្បីបង្ហាញពីលក្ខណៈវិជ្ជាជីវៈរបស់ជនជាប់ចោទ ហើយនិងអ្នកក្រោមបង្គាប់ ។ ហើយម្យ៉ាងទៀត គឺដើម្បីជាការបង្ហាញមេដឹកនាំជាន់ខ្ពស់ឲ្យបានលម្អិតបំផុតតាមដែលអាចធ្វើបាន តាមរបៀបណាមួយដែលថា ការសង្ស័យមានមូលហេតុដែរឬទេ? ចំពោះអ្នកទោសមួយចំនោះ ហើយដើម្បីនឹងលាក់កំបាំងលាតត្រដាងនូវខ្សែខ្មាំង គឺគិញយួនត្រូវបានផ្តល់ព័ត៌មាន ។ នៅក្នុងឯកសារទាំងអស់នោះជូនទៅមេដឹកនាំ អ៊ីចឹងហើយនេះជាគោលបំណងមួយ ។

នៅទីបំផុតនេះ គឺជាការគិតឃើញរបស់យើងទេ ប៉ុន្តែជាគំនិតមួយដោយការចងក្រងនូវឯកសារបណ្ណសាររបៀបនេះអាចនឹងបម្រើជាគោលបំណងមួយ ជាប្រភពសម្រាប់នៃការជោគជ័យមួយរបស់ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ហើយដូចជាឯកសារខ្លួនឯងហ្នឹងជាភស្តុតាងសំខាន់មួយដូចជា នៅក្នុងរបបកុម្មុយនីស្តសូវៀតដែលគេបានរៀបរាប់ថា បក្សកុម្មុយនីស្តវាសំខាន់ ថាគេបានកម្ទេចខ្មាំងទាំងអស់របស់គេហើយ ។ នេះគឺជាការអះអាងរបស់ខ្ញុំ គឺថាបញ្ជាក់ថា ចំណុចមួយទៀតបញ្ជាក់ថា គេខំប្រឹងប្រែងធ្វើការងារគេខ្លាំងណាស់ ដោយមិនធ្វេសប្រហែស ។

អ៊ីចឹងហើយចំណុចទីពីរ ជាចំណុចជាក់ស្តែងដែរ គឺថាធ្វើការយ៉ាងម៉ឺងម៉ាត់ជាទៀងទាត់ ដើម្បីបម្រើសេចក្តីត្រូវការរបស់មេដឹកនាំរបស់គេ ដែលថា-- ដូចបញ្ជាក់ខាងដើមពីឆ្នាំទៅមួយឆ្នាំ ពីមួយខែទៅមួយខែ ឬមួយថ្ងៃទៅមួយថ្ងៃជាដើមហ្នឹង ឬក៏មានគោលបំណងច្រើនបន្ថែមលើហ្នឹងទៀត ដើម្បីការចងក្រងឯកសារជាបណ្ណសារដូចដែលយើងបានឃើញនេះ ។

[១០:០១:០៩]

**ស៖** សូមអរគុណច្រើន ។ លោកបានសម្គាល់ហើយនៅក្នុងចម្លើយរបស់ជនជាប់ចោទចំពោះសៀវភៅរបស់លោក ។ គាត់បានផ្តោតនិងសង្កត់ធ្ងន់ទៅលើចំណុចមួយចំនួននៅក្នុងថ្ងៃ៣០ ខែមីនា ឆ្នាំ១៩៧៦ ទាក់ទងទៅនឹងសេចក្តីសម្រេចរបស់មជ្ឈិមបក្សលើបញ្ហាមួយចំនួនលេខ ERN ជាភាសាអង់គ្លេសគឺ 00182809 ដល់លេខ 00182814 ខ្មែរERN នោះគឺ0000758 ដល់លេខ 0000764 បារាំង គឺ00224363 ដល់លេខ 00224367 តើលោកធ្លាប់ឃើញឯកសារនេះដែរឬទេ ទាក់ទងទៅនឹងសេចក្តីសម្រេចរបស់មជ្ឈិមបក្សលើបញ្ហាមួយចំនួន ដែលលោកបានយោងបន្តិចបន្តួចនៅក្នុងសៀវភៅរបស់លោកទំព័រ៥១ ? យើងអាចធ្វើការបញ្ចាំងឯកសារនេះនៅក្នុងអេក្រង់របស់យើងបាន ។

យើងអាចឲ្យធ្វើការដាក់នៅក្នុងអេក្រង់របស់យើងដើម្បីឲ្យភាគីគាត់ចងចាំបានដែរ ។ ប៉ុន្តែយ៉ាងណាក៏ដោយយើងធ្លាប់បានបញ្ចាំងហើយចំពោះ ឯកសារនោះ ហើយយើងចង់ឲ្យលោក ដេវីដ ឆេនដ៍ល័រ បានឃើញផង ។ សូមឲ្យសោតទស្សន៍ធ្វើការ បង្ហាញឯកសារនេះជាភាសាអង់គ្លេស ។ លោកមាន ERN ទេ? 00182809 ។

សូមអរគុណ នេះជាផ្នែកទីមួយនៃចំណុចមួយសំខាន់នៅក្នុងការយល់ឃើញរបស់ជនជាប់ចោទ ខ្ញុំចង់សួរលោក ដេវីដ ឆេនដ៍ល័រ ថាតើលោកបានផ្តោតចំណុចសំខាន់យ៉ាងម៉េចទៅលើឯកសារមួយនេះ?

**ឆ៖** ខ្ញុំគិតថា អ្វីដែលយើងយល់គឺ វាទាក់ទងទៅនឹងឯកសារដែលវាកំណត់ឲ្យធ្វើការកម្ទេចទៅលើខ្មាំងកម្ពុជាប្រជាធិបតេយ្យ។ ឯកសារនេះគឺបានប្រកាន់ខ្ជាប់ជានិច្ចហើយយើងឃើញមានធ្វើការចែកជូនឯកសារនេះ ហើយឯកសារមួយច្បាប់វានៅសល់ ហើយយើងរកឃើញនៅក្នុងឆ្នា១៩៨០ នៅក្នុងផ្ទះរបស់បុគ្គលមួយ ។ ហើយយើងឃើញថាឯកសារត្រូវបានប្រមូលឡើង ។ ហើយយើងបានយល់អំពីប្រវត្តិសាស្ត្ររបស់កម្ពុជាប្រជាធិបតេយ្យ ។ នេះជាឯកសារមួយសំខាន់ដែលវាចេញពីលើ ហើយអនុញ្ញាតឲ្យធ្វើការកម្ទេចខ្មាំងនៅក្នុងជួរ និងក្រៅជួរ ទាក់ទងទៅនឹងជួរបក្សកុម្មុយនីស្តកម្ពុជាប្រជាធិបតេយ្យ ។

[១០:០៥:១៩]

**ស៖** សូមអរគុណ ។ ខាងផ្នែកសោតទស្សន៍អាចធ្វើការបញ្ចាំងរូបភាពធម្មតាឡើងវិញ ។

នៅក្នុងចំណុចសំខាន់ក្នុងសៀវភៅរបស់លោក លោកបានវិភាគ និងរៀបរាប់អំពីការធ្វើទារុណកម្មនៅស-២១ លោកបាននិយាយអំពីថា អ្នកជាប់ឃុំគឺមិនបានធ្វើការចោទប្រកាន់ដោយសារពួកគេចោទប្រកាន់ថាមានទោស ។ ហើយនៅក្នុងការយល់ឃើញរបស់លោកតួនាទីអ្នកសួរចម្លើយនោះគឺ លោកបានលើកឡើងថា គឺចេញជាសាលក្រមមួយដើម្បីធ្វើយ៉ាងណាទាញយកចម្លើយ ។ នៅក្នុងការឆ្លើយតបរបស់លោក របស់ជនជាប់ចោទ ចំពោះសៀវភៅរបស់លោក កថាខណ្ឌទីបីERN ភាសាអង់គ្លេសគឺ 0027055 ជនជាប់ចោទគាត់បានបញ្ជាក់ថា បញ្ជាក់ទៅលើការវាយតម្លៃរបស់លោកដោយគាត់បញ្ជាក់ថា "ស៊ូចាប់ដប់នាក់ឲ្យខុស ប៉ុន្តែកុំឲ្យដោះលែងមួយឲ្យច្រឡំ" នេះគឺជាការចោទប្រកាន់មួយដ៏ត្រឹមត្រូវរបស់ប្រជាជនខ្មែរដែលគាត់ទទួលការរងឈឺចាប់ពីការចាប់ខ្លួនដ៏ឈឺចាប់ ។ សុន សេន ឬក៏មេដឹកនាំខ្មែរក្រហមគាត់ប្រើប្រាស់ឃ្លាថា "ទុកក៏គ្មានចំណេញ ដកចេញក៏ខាត" ។ ខ្ញុំគិតថា លោកនៅតែរក្សាជំហរការយល់ឃើញរបស់លោកដដែលទេ ដែលថា វិធីសាស្ត្រទាក់ទងទៅនឹងតួនាទីរបស់អ្នកសួរចម្លើយ ឬអ្នកធ្វើទារុណកម្មទាក់ទងទៅនឹងចំណុចទាំងអស់នេះ ។

**ឆ៖** គឺខ្ញុំនៅតែប្រកាន់ជំហររបស់ខ្ញុំដដែល ។

**ស៖** លោកក៏បានលើកឡើងដែរនៅទំព័រទី៨០ សៀវភៅរបស់លោក "ភាគច្រើន អ្នកទោសភាគច្រើននោះ អ្នកទោសស-២១ ភាគច្រើន ត្រូវបានគេសម្លាប់ដោយសារតែកំហុសរបស់គាត់ ហើយក៏ដោយសារតែអទិភាពនៃមន្ទីរនោះផងដែរ ។ ទីតាំងរបស់វា ហើយនិងគោលបំណងរបស់មន្ទីរនោះដែលថាត្រូវតែរក្សាការសម្ងាត់" ។ គឺខ្ញុំលើកឡើងថា ខ្ញុំសូមសន្និដ្ឋានថា លក្ខខណ្ឌក្នុងការរក្សាការសម្ងាត់ចំពោះគុកនោះ គឺជាគោលបំណងនិងវត្ថុបំណងរបស់ថ្នាក់លើ ហើយវាក៏ជា-- ដើម្បី-- ហើយវាក៏ជាការកំណត់នឹងរក្សាជំហរនោះផងដែររបស់ជនជាប់ចោទ កាំង ហ្គេកអ៊ាវ ។

[១០:០៨:២៦]

**ឆ៖** គឺពិតជាត្រឹមត្រូវ វាមិនមែនជាសំណួរនោះទេ ។ គឺចាប់ដប់នាក់ច្រឡំ ជាជាងដោះលែង ១ ខុសនោះ គឺវាមិនមែនខុសនោះទេ ។ យើងឃើញថា មន្ទីរស-២១ នេះជាវត្ថុបំណងហើយវាមានហេតុផលចំពោះចំណុចនេះ ហើយជាជាងចាប់មនុស្ស ឬក៏សម្លាប់មនុស្សខុស ជាជាងការដោះលែងទៅច្រឡំវិញ ។ ដូច្នេះហើយវាជាចំណុចមួយដែលមានឲ្យយើងមានការព្រួយបារម្ភនូវអ្វីដែលយើងបានសិក្សា ។

**ស៖** លោកបានលើកឡើងនៅក្នុងសេចក្តីសន្និដ្ឋានរបស់លោកមួយចំនួន ហើយខ្ញុំចាប់អារម្មណ៍ទៅលើចំណុចមួយចំនួន ហើយលោកក៏បាននិយាយខ្លីៗដែលទៅលើចំណុចនេះ ។ ខ្ញុំចាប់អារម្មណ៍ទៅលើចំណុចយោងរបស់លោកដែលលើកឡើងអំពី *ការហ្សេបេ, ស៊ីអាយអេ* និងវៀតណាមដែលលោកបានលើកឡើង នៅក្នុងទំព័រ៨១, ៨២ និង ៩៤ ។ ពីការវិភាគរបស់លោក ពីចម្លើយសារភាពតើលោកអាចសន្និដ្ឋាន លោកទាញការសន្និដ្ឋានថា នៅពេលមួយចំនួននោះការពាក់ព័ន្ធជាមួយនឹង *ស៊ីអាយអេ* ហើយនិង *ការហ្សេបេ* គឺវា អាចការសន្និដ្ឋានមួយជាក់ស្តែងចេញពីអ្នកសួរចម្លើយ អ៊ីចឹងមែនដែរឬទេ?

**ឆ៖** វាជាសំណួរល្អ អ្នកសួរចម្លើយនោះគាត់មិនដឹងថា គាត់សន្និដ្ឋានជាក់ស្តែងយ៉ាងម៉េចនោះទេ ដូច្នេះខ្ញុំធ្វើការសន្និដ្ឋាននៅក្នុងសៀវភៅរបស់ខ្ញុំចំពោះចម្លើយគេមិនបានដឹងថាតើ *ស៊ីអាយអេ* ឬក៏ *ការហ្សេបេ* នោះជាអ្វីនោះទេ គ្រាន់តែគេធ្វើការចោទប្រកាន់ថាពួកគេនោះ គឺជាក្រុមនោះ ។ ហើយវាជាឃ្លាមួយសម្រាប់ប្រើប្រាស់ចំពោះខ្មាំង ។ ហើយ *ការហ្សេបេ* គឺវាបានលើកឡើង ហើយបន្ទាប់មកមានការលើកឡើងអំពីវៀតណាមផ្សេងៗ ។ គោលបំណង ឬក៏គំនិតនោះដែលថាបុគ្គលទាំងឡាយគាត់ត្រូវបានគេចោទថាមានការពាក់ព័ន្ធទៅលើបុគ្គលផ្សេងៗ គឺជាការពាក់ព័ន្ធមួយដែលគេចោទប្រកាន់។ហើយខ្ញុំគិតថា វាអាចមានលទ្ធភាពដែលថាជនជាប់ចោទគាត់បានដឹងទៅលើបញ្ហាទាំងអស់នេះ ហើយគាត់

បានអនុវត្តបញ្ហាពីលើមក ហើយអ្នកសួរចម្លើយនោះប្រហែលជាគាត់មិនបានដឹងថាតើការចោទប្រកាន់បែបនោះត្រឹមត្រូវ ឬក៏អត់នោះទេ? គ្រាន់តែពួកគេនោះតម្រូវឲ្យធ្វើការកំណត់និងដាក់ដូច្នោះ ទៅតាមអ្វីដែលបានណែនាំ ។

**ស៖** សូមអរគុណ ។ លោកបានបែងចែកវិធីពីរយ៉ាងដែលគេទាញយកចម្លើយ "ទីមួយ គឺធ្វើនយោបាយ មួយទៀត គឺធ្វើទារុណកម្ម" ។ តើលោកអាចរៀបរាប់ឲ្យបានពិស្តារទេ ទៅលើវិធីសាស្ត្រពីរបែបដែលលោកបានបែងចែកនោះ?

[១០:១១:៤៦]

**ឆ៖** ខ្ញុំអាចបញ្ជាក់បាន។ ការធ្វើទារុណកម្មបានន័យថាចាប់ផ្តើមសកម្មភាពមួយចំនួនចំពោះទៅលើរាងកាយរបស់អ្នកទោស ។ បានន័យថា យើងអាចមើលឃើញនៅក្នុងកតិកាសញ្ញា អនុសញ្ញាមួយចំនួនស្តីពីទារុណកម្ម ។ ចំណុចនេះ គឺជាការងារដែលគេធ្វើឡើងគឺការធ្វើទារុណកម្ម ការញុះញង់ ឬក៏ជំរុញឲ្យគេនិយាយ ហើយធ្វើការនិយាយផ្ទុយទៅនឹងចម្លើយរបស់អ្នកទោស ។ ដូច្នេះហើយ ទារុណកម្មមួយចំនួន គឺគាត់មានលក្ខណៈចេះធ្វើការងាររបស់គាត់ តាមវិធីរបស់គាត់ ជាវិធីដែលគាត់ទាញយកចម្លើយផ្សេងៗ ។ ដូច្នេះ ខ្ញុំគិតថា វាពិបាកណាស់ដែលថាយើងអាចដឹងគេប្រើទារុណកម្មធ្ងន់ប៉ុនណាប្រហែលទៅតាមការសន្និដ្ឋាននោះ នៅក្នុងចម្លើយសារភាពមួយចំនួន គឺវាបានបំពេញទៅតាមចម្លើយហើយពេញចិត្តចំពោះជនជាប់ចោទនិងសហសេវិករបស់គាត់ ។ ហើយវាបានធ្វើទារុណកម្មមួយចំនួនដើម្បីទាញយកចម្លើយទាំងអស់នោះ ។ ដូច្នេះហើយ នៅក្នុងករណីមួយចំនួនខ្ញុំមិនដឹងថាករណីណានោះទេគឺចម្លើយសារភាពទាំងឡាយ គឺគេទទួលបានតាមការពេញចិត្ត គឺអ្នកទោសនោះគាត់ឆ្លើយសារភាពដោយមិនចាំបាច់ធ្វើទារុណកម្មដល់គាត់ ។

**ស៖** ខ្ញុំសូមធ្វើការបង្អាក់នៅទីនេះសិន តើមីក្រូហ្វូន របស់លោក ដេវីដ ឆេនដ៍ល័រ នោះ មានបញ្ហាឬក៏យ៉ាងម៉េច ដោយសារមានការលំបាកចំពោះអ្នកបកប្រែ វាឮសំឡេងភឹបៗ ។ ថាតើអ្នកបកប្រែនៅតែស្តាប់បានដែរឬទេ?

បើសិនអ៊ីចឹងទេយើងមិនអាចធ្វើការកត់ត្រានៅក្នុងកំណត់ហេតុរបស់យើងទេ។

**អ្នកបកប្រែ៖**

លោកចៅក្រមប្រធាន! តាមពិតទៅ គឺយើងអ្នកបកប្រែបានសង្កេតឃើញថា លោក ដេវីដ ឆេនដ៍ល័រ លោកនិយាយកៀកនឹងមីក្រូហ្វូនពេកទាន ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

មិនមែនជាកំហុសរបស់លោកទេ គឺវាទាក់ទងនឹងប្រព័ន្ធមីក្រូហ្វូន ។

**ស៖** នៅក្នុងបរិបទទាក់ទងទៅនឹងការធ្វើទារុណកម្ម លោកបានធ្វើការដកស្រង់ចេញពីកំណត់ត្រារបស់អ្នកសួរចម្លើយម្នាក់នៅក្នុងទំព័រ ១៣៥ ហើយខ្ញុំដឹងថា លោកប្រាកដជាសិក្សាសៀវភៅកំណត់នោះហើយ ។ ហើយលោកបានទាញទៅលើការធ្វើទារុណកម្ម និងវិធីផ្សេងៗទាក់ទងទៅនឹងការធ្វើទារុណកម្ម តើខ្ញុំនិយាយនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** គឺត្រឹមត្រូវហើយ ។ ខ្ញុំបានជួបប្រទះឯកសារកំណត់ត្រានោះ ដូច្នេះហើយខ្ញុំធ្វើការសិក្សាវាមានព័ត៌មានពិស្តារ ហើយវាមានភាពចាំបាច់ណាស់ ។ ហើយបុគ្គលនៅក្នុងសៀវភៅនោះ បាននិយាយច្បាស់លាស់ និងស្មោះត្រង់ ដែលវាទាក់ទងទៅនឹងបញ្ហាការងារនៅក្នុងគុក ។

**ស៖** សូមអរគុណ ។ លោកក៏បានបញ្ជាក់អំពីការអនុវត្តរៀបចំប្រវត្តិរូបផ្សេង ។ នៅក្នុងការយល់ឃើញរបស់លោក ថាតើនេះជាវិធីសាស្ត្រមួយថ្មីដែលវិវឌ្ឍន៍នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? ហើយថាតើរបៀបនេះ គេកំណត់ថា វាជាការអនុវត្តដែរឬទេចំពោះអ្នកសួរចម្លើយ? ឬក៏គេអនុវត្តការធ្វើដូច្នេះជាលក្ខណៈទូលាយតែម្តង?

**ឆ៖** ការសរសេរប្រវត្តិរូបនោះគឺជាបញ្ហាមួយចម្បងរបស់កម្ពុជាប្រជាធិបតេយ្យ ។ អ្នកនៅក្នុងបក្សត្រូវតែសរសេរប្រវត្តិរូបឲ្យបានពិស្តាររបស់ខ្លួន ដែលយកទៅដាក់ចូលនៅក្នុងសំណុំឯកសារបុគ្គលិក ស-២១ សរសេរប្រវត្តិរូប ហើយវាជានីតិវិធី និងដំណើរការមួយសំខាន់នៅទីនោះ ។ ហើយបន្ទាប់មកគេធ្វើការពិនិត្យឡើងវិញថា តើវាមានចំណុចណាមួយទាក់ទងនឹងការវិវឌ្ឍនៃប្រវត្តិរូប? ហើយអ្នកទោសនោះ ក៏បានឲ្យសរសេរប្រវត្តិរូបដូចគ្នាផងដែរ ដូចដែលសមាជិកបក្ស ឬក៏បុគ្គលិកគាត់សរសេរដូចគ្នា ។ ហើយថា គេឲ្យសរសេរថា តើគេបានធ្វើអីគេខ្លះនៅក្នុងជីវិតរបស់គេ? ហើយគេធ្វើការងារណាមួយចំនួននៅក្នុងពេលណា ។ ដូច្នេះ ប្រវត្តិរូបទាំងអស់នោះគេបានធ្វើឡើង រៀបចំឡើង។ អ្នកទោស គឺគាត់មិនបានសរសេរកំហុសរបស់គាត់ ឬចន្លោះប្រហោងរបស់គាត់នោះទេ ។ ប៉ុន្តែ គេគ្រាន់តែចង់ឲ្យសរសេរអំពីសកម្មភាពក្បត់របស់ខ្លួន ។

**ស៖** ថាតើការសរសេរប្រវត្តិរូបនោះ គឺវាជាទម្លាប់នៅក្នុងប្រទេសកម្ពុជាមុនសម័យកម្ពុជាប្រជាធិបតេយ្យ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំមិនគិតថាអ៊ីចឹងទេ ។ វាមិនមែនជាទម្លាប់ទេតាំងពីមុខសម័យនោះ គឺយើងឃើញមានគេសរសេរប្រវត្តិរូបតិចតួចតែប៉ុណ្ណោះ ចំពោះមនុស្សមួយចំនួន ។ ហើយខ្ញុំគិតថា នីតិវិធីដែលគេធ្វើនៅស-២១ គឺវាកើតចេញពីការអនុវត្តរបស់ប៉ូលិសសម័យមុន នៅក្នុងរបបអាណានិគមនិងរបបមុននោះ។ មុនពេលដែលគេសួរចម្លើយ ឬក៏ក្រោយពេលចាប់ខ្លួននោះអ្នកទាំងអស់នោះ ត្រូវតែបង្ហាញ និងផ្តល់នូវប្រវត្តិរូបខ្លីៗរបស់ខ្លួន អំពីទីកន្លែងរស់នៅ ឪពុកម្តាយរបស់ខ្លួន ការងាររបស់ពួកគេ ។ ល ។

ដូច្នេះ ហើយនេះគឺជាចំណុចអភិវឌ្ឍន៍ដែលសល់ពីមុននៅក្នុងប្រព័ន្ធចាស់ វាមិនមែនជាទម្លាប់និងវប្បធម៌ជារួមនោះទេ ។

[១០:១៨:១៦]

**ស៖** តើខ្ញុំលើកឡើងត្រឹមត្រូវទេនៅពេលដែលខ្ញុំទាញការសន្និដ្ឋានថា ប្រវត្តិរូបរបស់កម្មាភិបាលសាមញ្ញនៅស-២១ ក្លាយទៅជាប្រភពព័ត៌មានសម្រាប់របបក្នុងការកំណត់សត្រូវរបស់ខ្លួន ឬក៏វាគ្រាន់តែជាគោលបំណងអាក្រក់តែប៉ុណ្ណោះ?

**ឆ៖** ខ្ញុំមិនគិតថា វាជាចំណុចអាក្រក់ ដែលតម្រូវឲ្យសមាជិកកម្មាភិបាល បុគ្គលិករៀបចំប្រវត្តិរូបរបស់ខ្លួននោះទេ ហើយគឺគេត្រូវតែធ្វើពីពេលមួយទៅពេលមួយ ចំពោះអ្នកទាំងអស់ជាកម្មាភិបាល និងបុគ្គលិក ។ ខ្ញុំគិតថា វាមិនមែនជាគោលបំណងអាក្រក់ទេ វាគ្រាន់តែជាការអនុវត្តនៅទីនោះ ។ ជាទូទៅ ហើយអ្នកទាំងអស់នោះ គឺគាត់មិនធ្វើការជំទាស់ទេ ប៉ុន្តែប្រហែលជាអ្នកខ្លះជំទាស់ ។ ប៉ុន្តែយ៉ាងណាក៏ដោយវាជាជីវិតសាមញ្ញទេ ដែលគេធ្វើទៅលើប្រវត្តិរូបទាំងអស់នោះនៅមន្ទីរនោះ ។ ហើយចំពោះមន្ទីរផ្សេងៗ ឯកសារប្រវត្តិរូបនោះ យើងមិនឃើញសល់នោះទេ ហើយគ្រាន់តែឯកសារទាំងអស់ទាក់ទងប្រវត្តិរូបរបស់បុគ្គលិកផ្សេងៗ និងកម្មាភិបាលសល់នៅស-២១ ។

**ស៖** នៅក្នុងការវិភាគរបស់លោកចំពោះចម្លើយសារភាព លោកបានធ្វើការទាញការសន្និដ្ឋានចាប់អារម្មណ៍មួយចំនួន ។ មួយនោះ គឺការចាប់អារម្មណ៍ ការសន្និដ្ឋានមួយនោះ គឺថា ព័ត៌មានតិចតួចវាបានលេចចេញពីចម្លើយសារភាពទាំងអស់នោះ ស្តីអំពីប្រវត្តិនិងជីវិតប្រចាំថ្ងៃរបស់ពួកគេ ។ ប៉ុន្តែលោកមិនអាចទាញការសន្និដ្ឋានអំពីអាហារមិនគ្រប់គ្រាន់ និងមានអនាម័យរបស់អ្នកទាំងអស់នោះ ។ ថាតើចំណុចទាំងអស់នេះ ព័ត៌មានតូចនេះវាធ្វើឲ្យលោកភ្ញាក់ផ្អើលដែរឬទេ នៅពេលដែលលោកទាញការសន្និដ្ឋាននោះ?

**ឆ៖** ខ្ញុំមិនមានការភ្ញាក់ផ្អើលទេចំពោះការសន្និដ្ឋានដូច្នោះ ។ បុគ្គលដែលធ្វើការនៅស-២១ គាត់មិនខ្វល់ទេ អំពីជីវិតផ្ទាល់ខ្លួនរបស់បុគ្គលទាំងឡាយដែលនាំមកសួរចម្លើយនោះ ។ ពួកគេគ្រាន់តែចង់បញ្ជាក់ និងចង់ដឹងច្បាស់ថា តើអ្នកទាំងអស់នោះពិតជាមានទោសអស់នោះដែរឬទេ នៅពេលដែលគេបញ្ជូនមកនោះ? ហើយការកើតឡើងចំពោះជីវិតរាល់ថ្ងៃនោះ គឺវាមិនមានការចាប់អារម្មណ៍ចំពោះពួកគេនោះទេ ។ ចម្លើយសារភាពទាំងឡាយ គឺវាមានព័ត៌មានជាច្រើនថា តើមានអ្វីកើតឡើង? ហើយហេតុអ្វីបានជាអ្នកទាំងអស់នោះ គាត់មិនពេញចិត្តនឹងរបបសម័យនោះ?

[១០:២១:០១]

ហើយចំពោះទាហានថ្នាក់ទាបៗនោះ គឺគាត់និយាយដោយស្មោះត្រង់ថា គាត់ហេតុអ្វីគាត់មិនពេញចិត្ត? គាត់មិនមានសេរីភាព? មិនមានអាហារ? មិនអាចទៅផ្ទះ? ដូច្នេះ ហើយនេះជាព័ត៌មានទាក់ទងជីវិតប្រចាំថ្ងៃរបស់គេ ដែលបានឆ្លើយនៅក្នុងចម្លើយសារភាព ។ ហើយអ្នកទោសភាគច្រើន គឺគាត់មិនបានសរសេរព័ត៌មានជាក់លាក់ចំពោះជីវិតប្រចាំថ្ងៃ ដូច្នេះនោះទេ ។

**ស៖** សូមអរគុណ។ នៅក្នុងទំព័រ១២០ ក្នុងសៀវភៅរបស់លោកៗបានធ្វើការអះអាងជាក់លាក់មួយចំនួន ទាក់ទងនឹងប្រព័ន្ធតុលាការនៅក្នុងប្រទេសកម្ពុជាបន្ទាប់ពីរបបជ័យជម្នះរបស់ខ្មែរក្រហម នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ តើលោកអាចធ្វើការសង្ខេបទៅលើការសន្និដ្ឋានរបស់លោកដូច្នោះដែរឬទេ?

**ឆ៖** គឺខ្ញុំអាចធ្វើទៅបាន គឺមិនមានច្បាប់ មិនមានចៅក្រម មិនមានមេធាវី មិនមានតុលាការនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ យើងឃើញមានថា តុលាការថែងនៅក្នុងរដ្ឋធម្មនុញ្ញ ប៉ុន្តែចៅក្រមក៏បានគេសម្លាប់ផងដែរ ។ ប៉ុន្តែ អត់មានការជំនុំជម្រះផ្សេងទេ ហើយនេះគឺជាអ្វីដែលយើងឃើញនៅក្នុងបក្សមនុស្សកម្ពុជា ហើយយើងមិនឃើញការថែងច្បាស់ ហើយមិនមានការជំនុំជម្រះចំពោះប្រជាជនផ្សេងៗ ។ ហើយក៏ដូចជានៅប្រទេសមួយចំនួនដែរ ដូច្នេះប្រព័ន្ធតុលាការនៅសម័យនោះ គឺវាមានអត់មានទេ ហើយអ្វីដែលវានៅសល់ចំពោះប្រព័ន្ធតុលាការនោះ គឺនៅសល់តែសមត្ថភាពរបស់ស្ថាប័នក្នុងការសួរចម្លើយអ្នកទោសដើម្បីយកព័ត៌មាន ។ ហើយប្រហែលនៅក្នុងសង្គមមួយចំនួននោះ គឺយើងឃើញ មានការចោទប្រកាន់តាមផ្លូវតុលាការ ប៉ុន្តែដូចដែលយើងបានលើកឡើងហើយ ប្រព័ន្ធតុលាការរបស់កម្ពុជាប្រជាធិបតេយ្យ គឺមិនមានលក្ខណៈពេញលេញ ។ បានន័យថា វាមិនមានស្ថាប័នផ្សេងៗដែលត្រូវដោះស្រាយ និងវិនិច្ឆ័យទៅលើព័ត៌មានទាំងឡាយប្រមូលបានពីមន្ទីរស-២១ ។ នេះគឺជាធាតុផ្សំ

មួយនៃប្រព័ន្ធតុលាការដែលនៅសល់នៅសម័យនោះ គឺមានតែការសួរចម្លើយតែប៉ុណ្ណោះ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមនិយាយត្រឡប់ទៅដល់ប្រធានបទទាក់ទងទៅនឹងការធ្វើទារុណកម្ម លោកបានលើកឡើងថា វាជាការអនុវត្តនៅស-២១ ។ នៅក្នុងទំព័រ១៣០ លោកបានលើកឡើង និងសរសេរនៅករណី និងឧទាហរណ៍ធ្វើទារុណកម្មមួយចំនួនដែលលោកបានរកឃើញថា បានលើកឡើងនៅក្នុងបណ្ណសារ និងឯកសារផ្សេងៗ ហើយនិងអ្នករស់នៅ អ្នកនៅរស់ ។ ថាតើលោកយល់ថាយ៉ាងម៉េចដែរ ទាក់ទងទៅនឹងវិធីសាស្ត្រនៃការធ្វើទារុណកម្មនៅស-២១?

[១០:២៤:៣៣]

**ឆ៖** គឺមានវិធីសាស្ត្រដែលគេប្រើប្រាស់នូវការធ្វើទារុណកម្ម ហើយខ្ញុំឃើញថា វិធីសាស្ត្រធ្វើទារុណកម្មលើកឡើងដោយអ្នករស់រានមានជីវិតនិងនៅក្នុងឯកសារផ្សេងៗ ។ ប៉ុន្តែ ខ្ញុំមិនបានពិនិត្យពិច័យឱ្យបានច្បាស់លាស់នោះទេ ។ យើងឃើញថា ប្រហែលមានទារុណកម្មដែលធ្វើចំពោះអ្នកទោស ប៉ុន្តែខ្ញុំមិនអាចរកឃើញភស្តុតាងបញ្ជាក់ទៅលើចំណុចទាំងអស់នោះទេ ។

**ស៖** ដើម្បីជាកំណត់ហេតុតុលាការ ខ្ញុំនឹងលើកឡើងអំពីបញ្ជីដែលលោកបានដាក់នៅក្នុង១៣០ ដែលនិយាយអំពីការវាយដោយដៃ ការដុតនឹងកន្ទុយបារី ឱ្យស៊ីអាចម៍ ឱ្យផឹកទឹកនោម ហើយបង្ខំឱ្យស៊ី ហើយព្យួរពីក្បាលចុះក្រោម ហើយចងដៃពេញមួយថ្ងៃ ហើយយកម្ជុលចាក់ ឱ្យគោរពរូបភ្លែ ។ ចាប់ពីឆ្នាំ១៩៧៨ ហើយឱ្យគោរពជញ្ជាំង តុ កៅអី ហើយដកក្រចកដៃ ធ្វើការខ្វៅ ហើយជ្រលក់ចូលទឹក នឹងធ្វើការឱ្យថប់ដង្ហើម ហើយនិងវិធីសាស្ត្រធ្វើទារុណកម្មទាក់ទងទៅនឹងការប្រើទឹកផ្សេងៗ ។ នៅក្នុងការរៀបរាប់នៅក្នុងទំព័រ១៣០ នៃសៀវភៅរបស់លោក វាមានករណីហិង្សានិងទារុណកម្មដ៏ធ្ងន់ធ្ងរ ដែលយើងអាចកំណត់ចុងក្រោយថាវាជាអំពីទារុណកម្ម ។ ប៉ុន្តែ ខ្ញុំនៅឆ្ងល់ ការខ្វៅ ហើយនិងជ្រលក់ ចូលទឹកនេះ ថាតើលោកនៅចាំទេ? តើលោកប្រើប្រាស់ពាក្យនេះយ៉ាងម៉េចដែរ? ហើយថា យល់ឃើញថា វាធ្ងន់ធ្ងរយ៉ាងម៉េចដែរ ដែលវាទារុណកម្មនោះ? នៅពេលដែលលោកប្រើពាក្យ ឆ្កួត ឬខ្វៅ ឬជ្រលក់ទឹកអីផ្សេង?

**ឆ៖** ខ្ញុំយល់ចំណុចរបស់លោកចៅក្រម ហើយយើងអាច-- ប្រសិនបើយើងព្យាយាមពិនិត្យទៅលើពាក្យទាំងអស់នេះ ទាក់ទងទៅនឹងវិធាន ហើយនិងអនុសញ្ញាទារុណកម្មនោះ គឺវាមិនចូលនោះទេ ។ ប៉ុន្តែ ខ្ញុំគិតនិងមើលឃើញថា អ្នកធ្វើទារុណកម្ម ឬក៏អ្នកសួរចម្លើយ គាត់ប្រព្រឹត្តចំពោះអ្នកទោស ហើយគឺការប៉ះពាល់ដល់រាងកាយរបស់អ្នកទោស ។ ខ្ញុំដឹងថា លោកស្រីបានអាននូវចំណុចវិធីទារុណកម្មទាំង

អស់នេះ ប៉ុន្តែចំណុចពីរដែលលោកស្រីបានលើកឡើង ទាក់ទងទៅនឹង ឆ្មូត ឬគូស ឬជ្រលក់ទឹកនោះ យើងអាចដកចេញពីសៀវភៅនោះ ។ ហើយពីរចំណុចហ្នឹង ធាតុទាំងពីរហ្នឹង គឺវាមិនស៊ីទៅទារុណកម្មនេះទេ ។

**ស៖** លោកបាននិយាយថា នៅក្នុងបញ្ជីនេះ គឺមិនមានការធ្វើទារុណកម្ម ហើយមានការផ្ទុះបញ្ចាំងនៅក្នុងរូបភាពរបស់ វ៉ាន់ ណាត ។ ហើយខ្ញុំគិតថា ប្រហែលជាលោកដឹងអំពីវិធីសាស្ត្រទារុណ-កម្មនេះបន្ទាប់ពីលោកធ្វើការសិក្សាទៅលើឯកសារផ្សេងៗតែប៉ុណ្ណោះ ។

[១០:២៧:៥៩]

**ឆ៖** ខ្ញុំបានសម្ភាសន៍ វ៉ាន់ ណាត ហើយខ្ញុំសរសើរគាត់ជាច្រើនឆ្នាំ ហើយខ្ញុំគ្រាន់តែចង់បញ្ជាក់ឲ្យបានច្បាស់ថា តើទារុណកម្មដែលមាននៅក្នុងរូបភាពរបស់គាត់នោះ គឺពិតជាអ្វីដែលគាត់បានឃើញដែរឬទេ? ឬក៏មិនមែនអ្វីដែលគាត់ឮប៉ុណ្ណោះនោះទេ? ហើយ គឺខ្ញុំគ្រាន់តែចង់បញ្ជាក់ថា តើគាត់បានឮពីគេ ហើយគាត់យកមកគូរ ឬយ៉ាងម៉េច? ហើយខ្ញុំធ្វើដូច្នោះ ទៅសម្ភាសន៍គាត់ដើម្បីបញ្ជាក់ឲ្យបានច្បាស់លាស់អំពីការធ្វើទារុណកម្មផ្សេងៗ ដែលវាបានកើតឡើងនៅទួលស្លែង ។

**ស៖** ថ្មីៗនេះ សាស្ត្រាចារ្យ ឆេនដ័ល័រ! អង្គសវនាការយើងបានស្ដាប់ចម្លើយ គក ស្រស់ ដែលជាអតីតបុគ្គលនៅស-២១ ។ លោកបានធ្វើការសម្ភាសន៍គាត់ ហើយបានដកស្រង់សម្ដីគាត់ដាក់ចូលសៀវភៅរបស់លោកយ៉ាងច្រើន នៅក្នុងចម្លើយរបស់ គក ស្រស់ ដប់ឆ្នាំក្រោយមកគឺគាត់មិនបានចងចាំឲ្យបានត្រឹមត្រូវទៅលើចម្លើយរបស់គាត់ ដែលលោកបានសរសេរក្នុងសៀវភៅរបស់លោក ។ តើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេ? ថាតើលោកបានកត់ត្រាចម្លើយរបស់ គក ស្រស់ នោះតាមរបៀបណាដែរ? ហើយថា តើបើសិនជាអាចចាំបាច់នោះ យើងអង្គសវនាការនោះថា ចង់បានពិនិត្យលើឯកសារលោកបានកត់ត្រាយ៉ាងម៉េចខ្លះទៅលើចម្លើយរបស់គាត់?

**ឆ៖** ខ្ញុំបានសម្ភាសន៍ជាភាសាខ្មែរ ដោយមានបុគ្គលម្នាក់ទៀត ដែលអាចជួយពន្យល់ខ្ញុំដើម្បីឲ្យខ្ញុំយល់បានច្បាស់ ។ ខ្ញុំគិតថា មានកាសែតថតសំឡេងតូចមួយ ដែលថាប្រតិចារឹកហ្នឹងគឺខ្ញុំមិនមានទៀតទេ ។ ខ្ញុំមិនមានឯកសារ ក្នុងទម្រង់ណាមួយដើម្បីផ្ដល់ជូនតុលាការក្នុងពេលនេះទេ ។

**ស៖** សូមអរគុណ។ នៅទីបំផុត នៅក្នុងចុងខាងក្រោយនៃសៀវភៅរបស់លោកនោះ លោកបានដកស្រង់សម្ដីរបស់ជនជាប់ចោទ ហើយលោកនិយាយថា នៅក្នុងកិច្ចប្រជុំ ការប្រជុំជីវភាព ដែលកោះហៅដោយ ចាន់ ដែលជាការប្រជុំរបស់បុគ្គលិកស-២១ក្នុងឆ្នាំ១៩៧៦ ។ ហើយបានដកស្រង់សម្ដី

ឌុច ថា យើងត្រូវតែពិនិត្យលើទស្សនៈខ្លួនឯង គឺថា "ត្រូវកំចាត់នូវទស្សនៈថា វាយអ្នកទោស គឺឃោរឃៅ ។ ករណីនេះមិនត្រូវធ្វើចិត្តល្អ ត្រូវវាយវាដោយមូលហេតុជាតិ មូលហេតុវណ្ណៈ និងមូលហេតុអន្តរជាតិ" ។ ហ្នឹងជាសេចក្តីដកស្រង់ក្នុងសៀវភៅរបស់លោកទំព័រ១៥១ ប៉ុន្តែជនជាប់ចោទ មិនបានបញ្ជាក់ថា គាត់ពិតជាបាននិយាយអ៊ីចឹងទេនៅពេលនោះ ឬក៏នៅក្នុងបរិបទនោះទេ ។ តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះដើម្បីផ្តល់នូវព័ត៌មានបន្ថែមទៀតអំពីខ្លឹមសារនៅក្នុងទំព័រ២០៦ នៅក្នុងលេខយោង ៤៥ ដែលលោកយោងទៅរកឯកសារដែលមិនបានធ្វើ*កាតាឡុក* នៅក្នុងបណ្ណសារស-២១ នៅថ្ងៃទី១៨ មេសា ឆ្នាំ១៩៧៦ ។

**ឆៈ** មុននឹងខ្ញុំឆ្លើយទៅសំណួរលោកស្រីចៅក្រមនោះ ខ្ញុំចង់បញ្ជាក់ចម្លើយទាក់ទងពីរឿងលោក គក ស្រស់ ដែលខ្ញុំនិយាយខាងដើមនោះ ។ ជាអកុសលនោះ ការសម្ភាសន៍របស់ខ្ញុំជាមួយគាត់នោះ ក្នុងឆ្នាំ១៩៩៥ ហ្នឹងជាការសម្ភាសន៍លើកទីមួយ គឺមិនធ្លាប់មានអ្នកណាសម្ភាសន៍គាត់ទេពីមុនមក ។ ហើយយើងបានជួបគាត់ ហើយយកគាត់មកភ្នំពេញជួបគ្នានៅភ្នំពេញ ដើម្បីជជែកជាមួយគាត់ អ្វីដែលគាត់និយាយនោះ ខ្ញុំទទួលបានព័ត៌មានថ្មីបំផុតពីគាត់ ដែលគាត់មិនធ្លាប់បាននិយាយប្រាប់អ្នកណាពីមុន ។ ហើយខ្ញុំអាចទុកចិត្តទៅលើភាពត្រឹមត្រូវអ្វីដែលគាត់និយាយនៅពេលនោះ ។ នៅក្នុងចំណុចនេះ នៅក្នុងចុងឆ្នាំទសវត្សរ៍ឆ្នាំ១៩៩០ គឺថាមានឯកសាររាប់ពាន់ទំព័រ ដែលស្ថិតនៅក្នុងបណ្ណសារស-២១ ត្រូវបានផ្ទេរជូនមក *ឌីស៊ីខេម* ប៉ុន្តែមិនទាន់បានធ្វើ *កាតាឡុក*បញ្ជីនៅឡើយទេ នៅពេលនោះ ។ ប៉ុន្តែ ឥឡូវនេះដោយបានដឹងថា គឺមានប្រសិទ្ធិភាពច្រើនណាស់នៅក្នុងការកត់ត្រាការងាររបស់ស្ថាប័ននោះ ជាពិសេសតាមការបរិច្ឆេទ ឬក៏តាមវិធីណាមួយដែលយើងអាចដកមើលចេញពីបណ្ណសារនោះបាន ។ ប៉ុន្តែ នៅពេលនោះ ខ្ញុំមិនមានលទ្ធភាពនឹងស្រង់ទាញយកបានទេ ពេលដែលខ្ញុំសរសេរសៀវភៅនោះ ។

**សៈ** សូមអរគុណលោកសាស្ត្រាចារ្យ ឆេនដ័ល័រ ។ នេះគឺជាការពន្យល់បន្ថែម ប៉ុន្តែខ្ញុំមានសំណួរបន្ថែមទៀតត្រូវសួរ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

ប៉ុន្តែលោកប្រធាន តើយើងគប្បីសម្រាកនៅពេលនេះសិន ឬក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ ដល់ម៉ោងត្រូវសម្រាក ចាប់ពីពេលនេះទៅរហូតដល់ម៉ោងដប់មួយខ្ទះដប់នាទី សូមអញ្ជើញចូលវិញ ។

មន្ត្រីតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យសម្រាប់ដល់អ្នកជំនាញរូបនេះ ក្នុងអំឡុងពេលសម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់សាលសវនាការមុនម៉ោងកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពី១០:៣៥នាទី ដល់ម៉ោង ១០:៥៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការពិភាក្សាដេញដោលស្តាប់សក្ខីកម្មអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ជាបន្ត ។ បន្តនេះសួរថា តើអស់លោកចៅក្រមមានសំណួរអ្វីត្រូវសួរដល់អ្នកជំនាញរូបនេះដែរឬទេ?

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** សូមជម្រាបសួរលោកសាស្ត្រាចារ្យ ឆេនដ៍ល័រ សូមអរគុណ ដែលលោកបានអញ្ជើញមកផ្តល់សក្ខីកម្មថ្ងៃនេះ ។ ខ្ញុំមានសំណួរមួយចំនួនតូចសួរទៅលោក ។ ជាបឋម លោកបានជម្រាបយើងអំពីមនុស្សម្នាក់ឈ្មោះ គក ស្រស់ ដែលលោកបានសម្ភាសន៍គាត់ ។ លោកនិយាយថា គាត់នោះមិនធ្លាប់បានគេសួរសម្ភាសន៍ពីមុនទេ ។ តើលោកនៅចាំទេ? ថាតើនៅក្នុងកាលៈទេសៈណាមួយដែលលោកបានមានទំនាក់ទំនងជួបជាមួយ គក ស្រស់? តើមានអ្នកណាណែនាំឲ្យលោកស្គាល់ ឬក៏របៀបម៉េច?

**ឆ៖** តាមដែលខ្ញុំចាំ គាត់ គឺជាមនុស្សម្នាក់ អ្នកជួយសម្រួល ជាមនុស្សមានសមត្ថភាព ។ គាត់ជាអ្នកបើកបរ ហើយគាត់បានជួយអ្នកសារព័ត៌មានច្រើននៅកម្ពុជា ។ គាត់ដឹងថា ខ្ញុំស្វែងរកមនុស្សដែលធ្លាប់ឆ្លងកាត់នូវស-២១ ដើម្បីផ្តល់នូវបទសម្ភាសន៍ឲ្យខ្ញុំ ដូចជា ហ៊ឹម ហ៊ុយ ជាដើម ។ គាត់បានរកឃើញតាមការរយៈទំនាក់ទំនង ហើយគាត់បានប្រាប់ ហ៊ុយ គាត់បានប្រាប់ទៅថា មានមនុស្សម្នាក់ទៀតដែលអាចគាត់នឹងចង់មកជួបខ្ញុំ ហើយនេះជារបៀប ដែលយើងបានរៀបចំការជួប ។

**ស៖** ម្យ៉ាងវិញទៀត ប៉ុន្តែបើយើងនិយាយពីបណ្ណសារ ដែលថាជាឯកសារដែលមានចំនួនច្រើនច្បាស់លាស់ ហើយលោកបានដឹងថា ក្រៅពីបណ្ណសារទាំងអស់នេះ តើលោកមានអ្វីទៀតបន្ថែមទេ? គឺ

អង្គហេតុមួយចំនួនដែលបញ្ជាក់ថា ឯកសារខ្លះមិនមាននៅក្នុងបណ្ណសារ ។ ថាតើមានកត្តាអ្វីដែលមានឥទ្ធិពលទៅលើឯកសារ ដែលយើងបានទទួល? តើមានផលវិបាកអ្វី ប្រសិនបើយើងចង់បញ្ជាក់ពីចំនួនលើអ្នកទោស ដែលបានឃុំនៅស-២១? តើយើងអាចធ្វើម៉េចបាន?

**ឆ៖** គឺថាវាអាចនឹងប៉ះពាល់ទៅនឹងសេចក្តីសន្និដ្ឋានរបស់ខ្ញុំដែរ ដោយសារយើងមិនដឹងលក្ខណៈនៃឯកសារដែលបាត់នោះទេ ។ យើងមានការលំបាកក្នុង-- និយាយថា ធ្វើម៉េចបានបើយើងមិនមានព័ត៌-មានជាក់ស្តែងនោះ ។ ចម្លើយសារភាពខ្លះមើលទៅហាក់ដូចជាខ្លី ចំពោះអ្នកទោសមួយចំនួនដែលថាសំខាន់ ឬមិនសូវសំខាន់នោះ ហើយត្រូវបានដកចេញដោយជនមួយចំនួន ដោយមូលហេតុចំនួនក្នុងរយៈកាលកន្លងទៅនោះ ។ ឯកសារដែលត្រូវបានមុនខែមីនា ១៩៧៦ នោះ យើងបានឯកសារច្បាប់ដើម ដែលថាមានឯកសារ*ក្ងពីកាប៊ូន*ចម្លងដែរ គឺឯកសារនោះ គឺថាយើងបាន*ក្ងពី*នៅក្នុងកិច្ចប្រជុំនោះ គឺថាមានប្រាំមួយ ឬប្រាំពីរនៃឯកសារបែបហ្នឹងដែលថា យើងយកពីក្នុងឆ្នាំ១៩៧៦ នោះឯង ឯកសារដែលផលិតហ្នឹង ។ ប៉ុន្តែ ឯកសារហ្នឹងត្រូវតែបានរក្សាទុក ហើយបានបន្តពីឆ្នាំ១៩៧៦, ១៩៧៧ និង៧៨ គឺជាឯក-សារ ដែលមានរក្សាការសម្ងាត់ខ្ពស់ ដែលចេញដោយមេដឹកនាំបក្សនៅថ្នាក់កំពូល ។ ហ្នឹងហើយ គឺថាអាចមានលទ្ធភាពដែលថា ព័ត៌មានដែលយើងបានទទួលពីកម្ពុជាប្រជាធិបតេយ្យ អាចមានការប្រែប្រួលដែលថា យើងអាចនឹងមានព័ត៌មានបន្ថែមពីរដ្ឋាភិបាលដែលបានរក្សាទុក ។ អ៊ីចឹងហើយ ចំពោះឯកសារខ្លះ ខ្ញុំមិនបានរកឃើញទេមកដល់ពេលនេះ ។

[១០:៥៩:៤៩]

**ស៖** ជាញឹកញយនៅក្នុងសៀវភៅរបស់លោកៗបានរៀបរាប់ស-២១ ថាជាស្ថាប័ន ឬមន្ទីរមួយដែលមិនមានភាពមនុស្សធម៌ ។ តើបើនិយាយប៉ុន្មានពាក្យជាសង្ខេបទៅ ថាតើលោកអាចជម្រាបយើងដែរឬទេ? ថាតើវាមានលក្ខណៈកំណត់ជារូបវន្ត ជាសារវន្តយ៉ាងម៉េចខ្លះ ដែលលោកកំណត់ថា វាជាកន្លែងអមនុស្សធម៌នោះ?

**ឆ៖** នេះគឺជាសំណួរមួយដ៏ល្អបំផុត ហើយខ្ញុំនឹងព្យាយាមឆ្លើយឲ្យបានល្អបំផុតតាមលទ្ធភាពរបស់ខ្ញុំ ។ អមនុស្សធម៌ជាការពិតទៅ គឺវាបានប៉ះពាល់មួយផ្នែកទៅលើប្រជាជន ដែលជីវិតអ្នកដែលធ្វើការនៅស-២១ ដោយសារតែអ្នកទាំងអស់នោះ គាត់មិនបានមានពេលឈប់សម្រាក ចេញទៅដើរលេងនៅក្នុងក្រុង ឬក៏គាត់មានសេរីភាពផ្សេងៗ ។ ហើយនៅក្នុងចម្លើយសារភាពមួយចំនួននោះ គឺបានលើកឡើងអំពីការដាក់លក្ខខណ្ឌកម្រិតដូច្នោះ ។ ហើយអមនុស្សធម៌ជាក់ស្តែង គឺបានប៉ះពាល់ទៅដល់អ្នកទោស

នៅពេល-- ប្រហែលជាប៉ះពាល់ដល់-- ចាប់ពីពេលអ្នកទោសនោះចូលមកដល់ស-២១ តែម្តង ។

មានតែអ្នកដែលមានឋានៈខ្ពស់តែប៉ុណ្ណោះនៅក្នុងជួរបក្ស ដែលគាត់ត្រូវបានគេប្រព្រឹត្តលក្ខណៈ ត្រូវបានគេប្រព្រឹត្តក្នុងលក្ខណៈគោរព ហើយមិនត្រូវបានគេប្រព្រឹត្តធ្វើបាបផ្នែកចិត្តសាស្ត្រ ផ្នែករូបកាយទេ នៅពេលដែលគេចូលមកដល់ ។ អ៊ីចឹងបានន័យថា នៅពេលដែលអ្នកទោសចូលមកដល់ស-២១ គឺពួកគេត្រូវបានដកចេញពីប្រភពមួយដែលមានមនុស្សធម៌ ហើយចូលមកដល់ទីកន្លែងដែលប្រព្រឹត្តឧក្រិដ្ឋកម្ម ។

[១១:០២:០៣]

**ស៖** ជនជាប់ចោទ នៅក្នុងដំណើរការក្តីរបស់យើង គាត់បានជម្រាបយើងជាញឹកញយថា គាត់មិនបានជឿទៅលើភាពត្រឹមត្រូវនៃចម្លើយសារភាពដែលប្រមូលបាននៅស-២១ នោះទេ ។ គាត់មិនពិចារណាថា ចម្លើយសារភាពទាំងអស់នោះ គឺជាការឆ្លុះបញ្ចាំងអំពីការពិតនោះទេ ។ ដូច្នេះ ថាតើលោកអាចជម្រាបយើងខ្ញុំបានដែរឬទេថា-- ខ្ញុំមិនដឹងថាតើយើងកំណត់វាយ៉ាងម៉េចទេ? ថាតើអ្នកទោសទាំងឡាយនោះ ត្រូវបានគេចងមុខ ហើយត្រូវបានគេធ្វើឲ្យមានការភ័យខ្លាច? ថាតើមានលក្ខណៈនិងធាតុផ្សំមួយចំនួនដូចនេះដែរឬទេ នៅពេលដែលស-២១ នោះ គឺគាត់បានគ្រប់គ្រងទៅកន្លែងនោះ?

**ឆ៖** ជាថ្មីម្តង គឺជាសំណួរដែលមានលក្ខណៈទូលាយ ខ្ញុំនឹងព្យាយាមឆ្លើយទៅតាមលទ្ធភាពដ៏ល្អបំផុតរបស់ខ្ញុំ ។ ខ្ញុំបានរកឃើញនៅក្នុងបណ្ណសារឯកសារមួយចំនួន ប៉ុន្តែឯកសារនោះ ក៏វាមិននៅដែរនៅពេលបច្ចុប្បន្ន ។ បុគ្គលទាំងឡាយដែលធ្វើការនៅបណ្ណសារ អ្នកយាម ឬក៏អ្នកសួរចម្លើយ ឬអ្នករដ្ឋបាលធ្វើការងារនៅស-២១ គឺគាត់តែងលើកឡើងនូវក្នុងកំណត់ហេតុថា ចម្លើយសារភាព គឺវាមិនត្រឹមត្រូវនោះទេ ហើយជនជាប់ចោទនោះ គឺគាត់ត្រឹមត្រូវក្នុងការលើកចំណុចដូច្នេះ ។ នៅពេលមួយចំនួននោះ គាត់បានដឹង គឺគាត់បានប្រកាសថា វាជាករណីអ៊ីចឹងមែន ។ ចម្លើយទាំងឡាយដែលបានទទួលបានពីចម្លើយសារភាពនោះ គឺបានបញ្ជូនទៅថ្នាក់លើ ។

ដូច្នេះហើយ ចម្លើយសារភាព ឬក៏យន្តការក្នុងការបង្កើតចម្លើយសារភាពនោះ គឺគ្រាន់តែគេធ្វើឲ្យវាដំណើរការជាដរាប ហើយគឺគេក៏ចង់បានព័ត៌មានពិតប្រាកដដែរ វាជាចំណុចល្អ ហើយវាជាភស្តុតាងចំពោះបុគ្គលទាំងឡាយ ទោះបីជាខ្ញុំក៏ដោយ ។ នៅពេលដែលខ្ញុំអានចម្លើយសារភាពនោះ គឺខ្ញុំត្រូវតែគិតដែរ ។ នៅក្នុងឆ្នាំ១៩៧៨ ខ្ញុំឃើញមានការលើកឡើងនៅក្នុងចម្លើយសារភាពថា គេបានដឹកប្រឡាយនៅក្នុងប្រទេសកម្ពុជានៅក្នុងទីក្រុងភ្នំពេញ ។ នៅក្នុងប្រឡាយនោះ គឺមានទាហានវៀតណាមដែលលាក់ខ្លួន

ហើយថាតើវាត្រឹមប៉ុនណាចំពោះការចោទប្រកាន់ចំពោះការលើកឡើងដូច្នេះ ដែលគេទៅរកទ័ពវៀតណាម ដែលលាក់ខ្លួន ហើយចុងក្រោយគេមិនអាចរកឃើញ ។

ដូច្នេះហើយ ចម្លើយសារភាពទាំងអស់នោះ គ្រាន់តែវាជាលក្ខណៈមួយធ្វើឲ្យដំណើរនេះអាចទៅមុខបាន ហើយវាជាយន្តការក្នុងការបំពេញចិត្តទៅភាពចាំបាច់ និងត្រូវការរបស់សមាជិកថ្នាក់លើរបស់របបនេះ ។ ដូច្នេះហើយទើបគេមានយន្តការធ្វើដូច្នេះ ។

[១១:០៥:៣៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណច្រើនលោកសាស្ត្រាចារ្យ ឆេនដ័ល័រ ខ្ញុំពុំមានសំណួរសួរទៅកាន់អ្នកជំនាញទៀតទេ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះប្រគល់វេទិការទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរសួរដល់អ្នកជំនាញរូបនេះ ប្រសិនបើមាន ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា៖**

**សួរដោយលោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ និងសូមស្វាគមន៍លោក ប្រូហ្វេស័រ ដេវីដ ឆេនដ័ល័រ ។ ក្រោយពីលោកបានសិក្សាស្រាវជ្រាវនូវប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ក៏ដូចជាប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យកន្លងមក ជាពិសេសនៅក្នុងសៀវភៅរបស់លោកៗបានផ្តោតអារម្មណ៍ទៅលើស្ថាប័នមន្ទីរស-២១ ដែលជាគោលដៅរបស់លោកនោះ ។

**ស៖** សំណួរសួរជូនលោកថា ថាតើលោកអាចពន្យល់ជូនអង្គជំនុំជម្រះពីរបបកម្ពុជាប្រជាធិប-តេយ្យនេះបានទេ? ថាតើរបបនេះមានគោលដៅ និងគោលបំណងចម្បងអ្វីខ្លះ ដែលជាមូលហេតុបង្កើតបាននូវមន្ទីរស-២១ នេះ?

**ឆ៖** សូមអរគុណលោកតំណាងសហព្រះរាជអាជ្ញាជាច្រើន ។ ជាការពិត គឺយើងមិនមានឯក-សារណាមួយដែលបានចែង និងបញ្ជាក់អំពីហេតុផលក្នុងការបង្កើតមន្ទីរស-២១ នោះទេ ។ ខ្ញុំបានរកឃើញឯកសារនៅក្នុងមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានលើកឡើងថា អ្នកធ្វើការទាំងឡាយត្រូវទៅវិទ្យាល័យពញាយ៉ាតធ្វើការដកស្មៅ និងរៀបចំតុកៅអី ។ ប៉ុន្តែយ៉ាងណាក៏ដោយ គឺមិនមានឯកសារពីថ្នាក់លើនោះទេ ឯកសារទាំងអស់នោះបានបាត់អស់ហើយ ។

ដូច្នេះហើយ គឺវាមិនត្រឹមតែស-២១ ទេ ដែលត្រូវតែមានអនុភាព និងបន្តមានអនុភាពចាប់ពីឆ្នាំ ១៩៧៥ ថ្ងៃទី១៧ ខែមេសា នោះ គឺយើងត្រូវ-- គឺគេបានផ្លាស់ប្តូរទីតាំងទៅកន្លែងស-២១ ហើយមានរក្សាការសម្ងាត់ផ្សេងៗដែលមិនឲ្យបុគ្គលទាំងឡាយណាធ្វើការផ្សព្វផ្សាយព័ត៌មាន ឬលេចចេញព័ត៌មាននោះទេ ។

[១១:០៨:៤៨]

ដូច្នេះ យើងបានឃើញយ៉ាងច្បាស់ថា យើងអាចសន្និដ្ឋានចេញពីចំណុចនេះ មូលហេតុដែលរបបនេះបានបង្កើតស-២១ គឺដោយសារតែ ដូចដែលលោកចៅក្រម ខាតរាយចំ បានលើកឡើងនៅពាក់កណ្តាលឆ្នាំ១៩៧៦ ថ្នាក់ដឹកនាំបានធ្វើការកោះប្រជុំថា មានខ្សែខ្មាំង មាននៅក្នុងជួរបក្ស ។ ហើយមានបុគ្គលមានកំហុសមួយចំនួនដែលគាត់មានសមត្ថភាព ហើយបុគ្គលទាំងឡាយ គឺគាត់មាននៅក្នុងជួរបក្ស ហើយគាត់ធ្វើការនៅក្នុងការងារបក្សរបស់យើង ។ ដូច្នេះហើយ គឺគេត្រូវការបង្កើតស្ថាប័នមួយដើម្បីបន្តធ្វើការងារ គិតគូរ ស្រាវជ្រាវទៅលើការសង្ស័យនោះ ធ្វើយ៉ាងណាស្វែងរកព័ត៌មានឲ្យបានច្បាស់លាស់ផ្តល់ទៅដល់ថ្នាក់លើ ។ ដូច្នេះហើយ នេះគឺជាអ្វីដែលគេបានបង្កើតស្ថាប័នហ្នឹងឡើង ។

**ស៖** បាទ, អរគុណ សាស្ត្រាចារ្យ ឆេនដ៍ល័រ ។ សំណួរបន្ទាប់ជូនលោក ថាតើក្រោយពីបានលោកបានសិក្សាស្រាវជ្រាវនូវឯកសារដ៏ច្រើនដែលលោកបានអះអាងនៅក្នុងសៀវភៅរបស់លោកថា លោកបានត្រួតពិនិត្យ មុនដំបូងបានតិចតួចទេ ។ ទាល់តែក្រោយមក ក្រោយពីមានសាលកវិទ្យាល័យ *ខនណែល* ហ្នឹង បានធ្វើការកូពីជា*ម៉ៃក្រូហ្វីម* លោកបានចូលជ្រៅទៅក្នុងប្រវត្តិរបស់ការបង្កើតស្ថាប័នស-២១ នេះ ។

សំណួរសួរលោកថា ក្នុងនោះលោកក៏បានបញ្ជាក់ដែរថា លោកប្រហែលជាអាចឆ្លើយនឹងសំណួរដ៏ច្រើននៅក្នុងការបង្កើតមន្ទីរស-២១ នេះ បាន ។ សំណួរចំពោះលោក ថាតើស្ថាប័នមន្ទីរស-២១ នេះ វាអាចចរិកលក្ខណៈជាកុម្មុយនីស្ត ឬវាអាចមានចរិកលក្ខណៈជាខ្មែរ? ក្នុងនោះដែរ ថាតើស្ថាប័នស-២១ នេះវាអាចមានគំរូពីបរទេស ដែលមានប្រទេសសង្គមដទៃទៀតដែរឬទេ? អរគុណ ។

**ឆ៖** សូមអរគុណលោកច្រើន។ គុកប្រភេទនេះគឺវាមិនមានការកើតឡើងតាំងមុននៅក្នុងប្រទេសកម្ពុជា ដែលខ្ញុំធ្លាប់ដឹងនោះទេ ។ ទាក់ទងទៅនឹងអង្គភាពសួរចម្លើយ ឬស្ថាប័នសួរចម្លើយ ដែលមជ្ឈមណ្ឌល ឬក៏អង្គភាពមន្ទីរនេះ បានបង្កើតនូវឯកសារចម្លើយសារភាពជាច្រើននៅក្នុងប្រទេសកម្ពុជា ។ នៅពេលដែលយើងធ្វើការស្វែងរកគំរូច្បាស់លាស់ណាមួយនោះ វាជាចំណុចមួយដែលគួរឲ្យចាប់អារម្មណ៍

ប៉ុន្តែវាហាក់ដូចជាមិនអាចឲ្យយើងធ្វើឲ្យរកឃើញគំរូដ៏មានលក្ខណៈល្អបំផុតនោះទេ ។ ហើយយើងមិនដឹងថាតើជួរដឹកនាំហ្នឹង គាត់យល់អំពីគំរូយ៉ាងម៉េច? ហើយអនុវត្តទៅតាមគំរូយ៉ាងម៉េច ។

នៅចិន គឺគេបានបង្កើតអំពីមន្ទីរស្រដៀងមួយ ប៉ុន្តែវាមានលក្ខណៈតូចជាងច្រើន ហើយប្រជាជនទាំងឡាយត្រូវបានគេឃុំនៅទីនោះ ប៉ុន្តែមិនសម្លាប់ទេ ។ ហើយយើងក៏មានការកាត់ក្តីមួយដែរនៅរុស្ស៊ី ដែលវាជាការប្រឌិត-- ជាការគ្រាន់តែចង់បង្ហាញ ហើយគេមានការកាត់ក្តីទៅលើការប្រព្រឹត្តិនៃអំពើសម្លាប់មួយ ។ ហើយយើងក៏មានសញ្ញាណ និងគំរូ នៃមន្ទីរអប់រំ ដែលរបបបក្សកុម្មុយនីស្តនោះ គឺក៏គេបានយកគំរូនោះមកអនុវត្ត ។ បានន័យថា បុគ្គលទាំងឡាយត្រូវយកទៅអប់រំ ហើយអាចឲ្យត្រលប់មកវិញ ។ ហើយវាស៊ីគ្នាទៅនឹងទស្សនទាននៃសាសនាគ្រិស្ត ដែលទាក់ទងទៅនឹងការអត់ឱនទោស និងការលើកលែងចំពោះអំពើ ដែលគេបានធ្វើ ។ ដូច្នេះ ហាក់ដូចជានៅក្នុងនេះ វាមិនមានជាលក្ខណៈកម្ពុជា ដោយសារតែវាមិនមានលក្ខណៈ ដែលសល់ចេញពីរបបចាស់ ។ យើងឃើញមានទិដ្ឋភាពពីរ៖ ទីមួយ គឺមន្ទីរនេះសម្ងាត់ ។ ហើយទីពីរ គឺយើងឃើញមានអ្នកទោសផ្សេងៗ នៅក្នុងនុ៎ង ។

ដូច្នេះ ប្រសិនបើយើងនិយាយតាមរយៈចម្លើយសារភាពរបស់អ្នកទោស អ៊ីចឹង គឺអ្នកទោសនោះគាត់ស្ថិតនៅក្នុងស្ថានភាព និងដំណាក់កាលកសាងខ្លួន ដើម្បីឲ្យក្លាយទៅជាប្រជាជនល្អឡើងវិញចំពោះអំពើដែលគាត់បានធ្វើនៅក្នុងការងារ និងជីវិតរបស់គាត់ ។ ដូច្នេះហើយគឺជាការអប់រំឡើងវិញ ហើយវាជាចំណុចមួយសំខាន់ចំពោះរបបនេះ ហើយគេមិនទទួលស្គាល់ថា មានស្ថាប័ន ឬក៏មន្ទីរនេះទេ ទោះបីជាវាមានក៏ដោយ ។ ហើយ គឺគេមិនបានលើកឡើងបញ្ជាក់ ថាតើអ្នកទោសទាំងអស់នោះ គាត់បានអប់រំខ្លួនឯង ឬក៏ទទួលបាននូវយន្តការបែបនោះ នោះទេ?

ដូច្នេះ ចំពោះខ្ញុំៗមិនអាចនិយាយបានទេ ថាតើយកគំរូជាក់លាក់ណាមួយពីប្រទេសណា? ឬពីរបបណានោះ? គឺមន្ទីរនេះ គឺមិនបានយកគំរូជាក់លាក់ច្បាស់លាស់ពីគំរូណាមួយឡើយ ។

[១១:១៥:១៦]

**ស៖** អរគុណលោកសាស្ត្រាចារ្យ ។ សំណួរបន្ទាប់ជូនលោក វាហាក់ដូចជាត្រឡប់ក្រោយបន្តិចតាមការពិនិត្យនៅក្នុងសៀវភៅរបស់លោក ដែលមានចំណងជើងថា “សំឡេងចេញពីមន្ទីរស-២១”នោះនៅត្រង់ទំព័រលេខ ដែល ERN លេខ 00191854 ជាភាសាខ្មែរ ត្រង់ទំព័រទី២៥ បន្ទាត់ទី១៥ ។ ខ្ញុំលើកឡើងពីសៀវភៅរបស់លោកនេះ គឺយោងនៅក្នុងសៀវភៅលោកដែលបានបោះពុម្ពនៅក្នុងឆ្នាំ២០០១ ។ ក្នុងនោះលោកបានបញ្ជាក់ថា មន្ទីរសន្តិបាលនៅតាខ្មៅឈ្មោះថា ស-២១ “ខ” ទីតាំងនៅក្នុងបរិវេណ

គឺជាទីតាំងនៅក្នុងបរិវេណមន្ទីរពេទ្យវិកលចរិត ពេទ្យឆ្កួត ។ សំណួរសូមសួរជូនលោកសាស្ត្រាចារ្យថា តើតាមការស្រាវជ្រាវរបស់លោកនុ៎ង តើមន្ទីរនេះ មានឈ្មោះផ្សេងក្រៅពីនេះទៀត ដែរឬទេ?

**ឆ៖** ខ្ញុំមិនបានពិនិត្យ ទទួលបានឯកសារផ្សេងជាជាងសៀវភៅរបស់ខ្ញុំ ទាក់ទងទៅនឹងការលើកឡើងរបស់លោក ថាមន្ទីរ ស-២១ “ខ” នោះ គឺខ្ញុំដូចជារកអត់ឃើញទេ ។ ខ្ញុំមិនមានព័ត៌មានណាមួយដែលខ្ញុំអាចមើលឃើញ ហើយឆ្លើយតបទៅនឹងសំណួររបស់លោក ដែលបានសួរអំពីមន្ទីរស-២១ “ខ” នោះទេ ។

**ស៖** អរគុណ លោកសាស្ត្រាចារ្យ ដោយពេលវេលារបស់ខ្ញុំនោះ វាមានកំណត់ ។ ខ្ញុំវាមានឯកសារដែរ ប៉ុន្តែបើសិនជាពេលវេលាខាងខ្ញុំ នៅមានពេលវេលាគ្រប់គ្រាន់ ខ្ញុំនឹងអាចបន្តសំណួរហ្នឹង ហើយនិងបង្ហាញជូនឯកសារខ្លះៗ ដែលលោកសាស្ត្រាចារ្យហ្នឹងបានយោង ។ អ៊ីចឹង ខ្ញុំសូមផ្អាកសំណួររបស់ខ្ញុំត្រឹមហ្នឹង ហើយចាំពេលឱកាស បើសិនជាខ្ញុំមានពេលវេលាបន្តទៀតខ្ញុំនឹងបង្ហាញលោកសាស្ត្រា-ចារ្យនូវអ្វីដែលលោកសាស្ត្រាចារ្យបានយោង នៅក្នុងសំណួររបស់ខ្ញុំ ដែលខ្ញុំបានសួរជូនលោកសាស្ត្រា-ចារ្យហ្នឹង ។

**លោក តាន់ សេណារ៉ុង៖**

អ៊ីចឹង ខ្ញុំសូមអស់សំណួរប៉ុណ្ណឹង ហើយសូមជូននាទីបន្ទាប់ទៅសហការីរបស់ខ្ញុំ ។ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីនឹងសួរបន្ត ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** អារុណសួស្តីលោកសាស្ត្រាចារ្យ! ខ្ញុំចង់សួរសំណួរលោកមួយចំនួន ទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទ គឺលោក ឌុច ។ ពីកំណត់ហេតុ ឬក៏ចម្លើយផ្សេងៗ ការសម្ភាសន៍ទាំងឡាយដែលលោកបានទទួលនោះ ថាតើគាត់នោះឧស្សាហ៍ប៉ុន្មានណា? ហើយមានបំណងមហិច្ឆតាប៉ុន្មានណា? ហើយគាត់ធ្វើការងាររបស់គាត់ត្រឹមកម្រិតណា?

ប៉ុន្តែ មុនពេលដែលលោកឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំៗសូមលើកឡើងទំព័រមួយនៅក្នុងសៀវភៅរបស់លោក គឺទំព័រ២២ ។ លោកបានលើកឡើងថា នៅពេលដែលលោក ក្រោយពីលោកពិនិត្យឯកសារផ្សេងៗ លោកឃើញថាសំណេរ ការសរសេរដោយផ្ទាល់ដៃរបស់លោក ឌុច នោះ ឃើញមាននៅក្នុងចម្លើយសារភាពជាច្រើន ។ ហើយគាត់បានធ្វើចំណារជាទូទៅ គឺព័ណក្រហម ហើយមាននៅក្នុងឯកសាររាប់រយ ។ ហើយបន្ទាប់មកគាត់ធ្វើការកែប្រែ ហើយបានបញ្ជាក់ថា តើគេសារភាពអ្វីខ្លះ

ចំពោះអ្នកទោស? គាត់ស្នើសុំឲ្យមានការធ្វើទារុណកម្ម ហើយគាត់ធ្វើឲ្យធ្វើការជីកកាយកន្លែងដែលថា មានខ្មាំងលាក់ខ្លួន ហើយ ឌុច ក៏បានធ្វើការសង្ខេបទៅលើចម្លើយសារភាព ដែលចង្អុលបញ្ជាក់អំពីខ្សែៗស្រឡាយជាប់ទៅនឹងអ្នកទោសទាំងអស់នោះ ដើម្បីធ្វើការរកខ្សែថ្មី ។

ដូច្នេះ នេះ គឺចំណុចទាំងឡាយដែលលោកបានលើកឡើងនោះថា មានចំណារផ្សេងៗរបស់ ឌុច នៅលើចម្លើយសារភាព ហើយលោកបានលើកឡើងថា គាត់បានចូលរួមនៅក្នុងការធ្វើទារុណកម្ម និងការងារទាំងអស់នេះ តាមការសន្និដ្ឋានពីចម្លើយទាំងអស់នោះ នៅក្នុងសៀវភៅរបស់លោក ។

[១១:២០:00]

**ឆ៖** គឺគាត់បានធ្វើដូច្នេះមែន ។ គឺគាត់បានសរសេរ បានធ្វើចំណារ ប៉ុន្តែយ៉ាងណាក៏ដោយ ខ្ញុំក៏មិនបានទទួលឯកសារគ្រប់គ្រាន់ផងដែរ ។ ខ្ញុំចង់លើកឡើងចំណុចពីរ៖

ទីមួយ គឺពីអ្នក ដែលធ្វើការនៅក្នុងមន្ទីរ ឬក៏អ្នកដែលនៅរស់រានមានជីវិត ។ ហើយជាទូទៅ ខ្ញុំឃើញមាននៅក្នុងចម្លើយផ្ទាល់របស់គាត់ គឺខ្ញុំទទួលបានយល់ពីឯកសារទាំងអស់នោះ ។ គឺយើងឃើញគាត់មានសរសេរចំណារផ្សេងៗនៅក្នុងឆ្នាំ១៩៧៨ ផងដែរ ។ ប៉ុន្តែ យ៉ាងណាក៏ដោយ អ្នកទោសមានការសម្លាប់ថយចុះចាប់ពីឆ្នាំ១៩៧៨ ។ អ៊ីចឹង គឺចំណុចទាំងឡាយ គឺគាត់ចារទៅលើចម្លើយផ្សេងៗដើម្បីធ្វើការងារ ។ ជាពិតទៅ អ្នកដែលរស់រានមានជីវិត ក៏បានបញ្ជាក់ទៅលើចំណុចនេះ ។ ចំណារជាលាយលក្ខណ៍អក្សរ គឺវាទាក់ទងទៅនឹងការងាររបស់គាត់ ហើយគាត់ក៏បានបង្ហាញយ៉ាងច្បាស់លាស់ទៅតាមរយៈចំណារទាំងអស់នេះ ។

ដូច្នេះ អ្វីដែលយើងអាចពិពណ៌នាបានអំពីការងារ លក្ខណៈវិជ្ជាជីវៈ និងការពេញចិត្តរបស់គាត់នោះ គឺការងារទាំងឡាយដែលគេចាត់តាំងឲ្យគាត់ធ្វើពីថ្នាក់លើ ។ ដូចដែលខ្ញុំបានជម្រាបក្នុងចម្លើយរបស់ខ្ញុំពីមុនហើយ ។ គាត់ចង់ឲ្យស-២១ មើលឃើញអំពីគុណប្រយោជន៍ស-២១ ហើយ គឺថាគេមិនយល់ឃើញថារបបនោះ គឺវាមិនដួលរំលំនោះទេ ។

នៅចុងក្រោយ គឺឃើញថារបបមួយដែលមានមន្ទីរស-២១ នោះ គឺក៏វាមិនមែនជារបបមួយដែលមានប្រសិទ្ធភាព ហើយដំណើរការបានចប់រហូតនោះដែរ ។ សូមអរគុណ ។

**ស៖** ចំណារទាំងឡាយ ដែលលោកបានធ្វើការពិនិត្យមើលនោះ គឺវាហាក់ដូចជាស៊ីគ្នាទេ តាំងពីដើមដំបូងមកឆ្នាំ១៩៧៥ រហូតទៅដល់៧៩? ថាតើលោកអាចសង្កេតឃើញថា ចំណារទាំងអស់នោះ វាភាពស៊ីគ្នាទេ តាំងពីដំបូងរហូតដល់ពេលបញ្ចប់?

**ឆ៖** ប្រហែលជាខ្ញុំអាចធ្វើការ មានការស្ទាក់ស្ទើរក្នុងការចម្លើយទៅលើចំណុចទាំងអស់នេះ ដោយសារតែខ្ញុំត្រូវការពិនិត្យមើលទៅលើចំណារទាំងអស់នោះ ប្រសិនជាខ្ញុំឆ្លើយ ។ ប៉ុន្តែខ្ញុំគិតថា ការថយ ចុះនៅក្នុងឆ្នាំ១៩៧៨ នោះ គឺគាត់មានការគិតយល់អាក់អន់ចិត្តទៅលើអ្វីដែលគាត់ធ្វើចាប់ពីឆ្នាំ ១៩៧៨ ។

ដូច្នេះហើយគាត់ ការពេញចិត្ត និងការចង់បំពេញការងាររបស់គាត់ នៅក្នុងការធ្វើចំណារនោះ មានការថយចុះ ចាប់តាំងពីឆ្នាំ១៩៧៨ ។ ហើយដូចដែរ ខ្ញុំបាននិយាយអ៊ីចឹង គឺខ្ញុំគួរតែពិនិត្យមើល ចំណារចាប់តាំងពីឆ្នាំ១៩៧៨ នោះ ដែលខ្ញុំចាត់ទុកនៅ *មែលប៊ីន* ហើយខ្ញុំគួរតែមើលឡើងវិញ ។ អ៊ីចឹង គឺចំណារ ដែលគាត់ធ្វើក្នុងឆ្នាំ៧៧, ៧៨ នោះ គឺវានៅតែស្ថិតនៅមួយកម្រិត ថានៅតែមានលក្ខណៈវិជ្ជាជីវៈ និងការពេញចិត្តរបស់គាត់មួយផ្នែក ។

[១១:២៣:៤៤]

**ស៖** គឺគាត់ប្រហែលជាបដិសេធ ថាគាត់មិនពេញចិត្តទេ ចាប់ពីឆ្នាំ១៩៧៨ តើចំណុចនេះត្រឹមត្រូវដែរឬទេ នៅពេលដែលមានការបដិសេធលើកឡើងដូច្នេះ?

**ឆ៖** បន្ទាប់ពីការធ្វើវិសុទ្ធកម្ម ឬក៏កម្ទេចផ្នែកបូព៌ា ភូមិភាគបូព៌ា មានការកើតឡើងនោះ គឺយើងឃើញថាមាន វន វ៉េត វត្តមាន-- មានទាក់ទងទៅនឹងបញ្ហា វន វ៉េត ។ ប៉ុន្តែខ្ញុំមិនអាចនិយាយច្បាស់ថាតើ វន វ៉េត គាត់បានធ្វើការចោទប្រកាន់ចំពោះកម្មាភិបាលរបស់គាត់ ឬក៏យ៉ាងម៉េច? ហើយខ្ញុំមិនអាចធ្វើការសន្និដ្ឋានទៅលើចំណុចទាំងអស់នេះទេ ។ នៅចុងឆ្នាំ-- ចុងការប្រតិបត្តិការស-២១ គឺពេលដែលយើងមានចម្លើយ និងព័ត៌មានជាច្រើនពីអ្នករស់រានមានជីវិតនោះ គឺនៅពេលនោះយើងឃើញថា គឺគាត់ហាក់ដូចជាធ្វើការលែងសូវមានការពេញចិត្តទៅលើការងារក្រោយឆ្នាំ១៩៧៨ ។

[១១:២៥:00]

**ស៖** នៅពេលដែលខ្ញុំអានសៀវភៅរបស់លោក ទាក់ទងទៅនឹងការលើកឡើងភាពស៊ីគ្នា នៃខ្សែក្បត់ដែលភ្ជាប់ទៅក្នុងចម្លើយសារភាព ។ ហើយវាបានបញ្ជូនទៅថ្នាក់លើ ហើយខ្ញុំសូមលើកឡើងទំព័រ ៨១ គឺខ្សែក្បត់នោះ គឺមាននៅក្នុងគ្រប់ចម្លើយសារភាពទាំងអស់ ហើយវាមានឈ្មោះរាប់រយ ។ ដូច្នេះហើយវាហាក់ដូចជាមានការផ្សំគំនិតទូទាំងប្រទេស នេះគឺជាអ្វីដែល ឌុច និងមេរបស់គាត់គិតឃើញ ។ ហើយបន្ទាប់មកលោកបានលើកឡើងសម្តី ស្ទីវ ការយល់ឃើញទៅលើចម្លើយសារភាព គឺទាក់ទងទៅនឹងបុគ្គលដែលឆ្លើយសារភាព និងបុគ្គលដែលនៅលើអ្នកដែលឆ្លើយសារភាពឲ្យធ្វើការក្បត់បក្ស ។ អ្នក

ដែលនៅក្រោមដែលគាត់-- អ្នកដែលជាប់ទោសនោះ គាត់ព្យាយាមនឹងអូសអ្នកផ្សេងខាងក្រោមឱ្យចូលរួមធ្វើការបដិវត្តន៍ ធ្វើការក្បត់ទៅលើអង្គការ ។ ដូច្នេះហើយ គឺមានការធ្វើទៅលើការសម្រេចផ្សេងៗ ថាតើលោកយល់ស្របទៅលើចំណុចដែលលើកឡើងក្នុងចម្លើយសារភាពដែលថា ចម្លើយសារភាពត្រូវបានគេប្រើប្រាស់ជាយន្តការ ដើម្បីធ្វើការស្វែងរក ហើយប្រមូលខ្មាំងផ្សេងៗ ។ នេះជាវត្ថុបំណងដែលគេរៀបចំចម្លើយសារភាព ឬក៏យ៉ាងម៉េច?

**ឆ៖** យើងឃើញថា វាជាទិដ្ឋភាពធំមួយ យើងយល់យ៉ាងច្បាស់ថា យើងមិនអាចផ្សំគំនិតដោយខ្លួនឯងទេ ទាល់តែមានអ្នកផ្សេងចូលរួម ។ អ៊ីចឹងបានន័យថា បើសិនជាជនក្បត់ផ្សំគំនិត គឺទាល់តែធ្វើការជាមួយគ្នានៅក្នុងក្រុម ។ ដូច្នេះហើយ វាជាចំណុចមួយដែលគេគ្រប់គ្រងគេដំណើរការ និងគេគិតឃើញនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ បានន័យថា បុគ្គលនៅពីលើ និងនៅពីក្រោមអ្នកដែលឆ្លើយសារភាពនោះ គឺវាជាប់ពាក់ព័ន្ធគ្នា ហើយវាបង្កើតទៅជាខ្សែបក្ស ហើយវាបង្កើតទៅគំនិតទស្សនទាន និងគំនិតមួយអំពីការពាក់ព័ន្ធនឹងស-២១ ។ នៅពេលដែលគេបានមើលទៅលើខ្សែក្បត់ ដែលដាក់ដោយអ្នកទោសនោះ គឺគេនឹងយល់ ។

អ្នកទោសភាគច្រើន គឺគាត់បានសរសេរបញ្ជីឈ្មោះដែលឈ្មោះពួកគេស្គាល់ ដោយគេមិនគិតអំពីភាពគ្រោះថ្នាក់ទៅលើអ្នកទាំងអស់នោះទេ ។ ហើយអ្នកក្បត់នោះ ចួនកាលទៅគាត់មិនដឹងអំពីការផ្សំគំនិតនោះទេ គាត់បង្កើតបញ្ជីៗអ្នកដែលគាត់ស្គាល់ ដែលគេប្រាប់ឱ្យគាត់ធ្វើដូច្នោះ ។ ដូច្នេះហើយ ខ្ញុំយល់ឃើញថា បញ្ជីទាំងអស់នោះ គឺទាញផលប្រយោជន៍ដោយបុគ្គលមួយចំនួនហើយជំរុញឱ្យបុគ្គលិកទាំងឡាយចូលទៅដល់តាមជនបទ ដើម្បីស្វែងរកបុគ្គលផ្សេងៗនាំចូលមក ។

ហើយការបង្កើតបញ្ជីនោះត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះ គឺទាល់តែខ្ញុំធ្វើការពិនិត្យ និងដូចអ្វីដែលខ្ញុំនិយាយពីមុនអ៊ីចឹង ថាតើខ្ញុំត្រូវពិនិត្យឯកសារ ថាតើវាការងារហ្នឹងវាទាក់ទងគ្នាយ៉ាងម៉េច? ហើយបញ្ហាទាក់ទងទៅនឹងការសង្ស័យថាតើបញ្ជីនោះ ត្រឹមត្រូវ ឬមិនត្រឹមត្រូវនោះ គឺវាទាក់ទងទៅនឹងជួរដឹកនាំ ។ ហើយប្រទេសទាំងមូលនោះ គឺរងគ្រោះដោយសារការចោទប្រកាន់អំពីខ្មាំងផ្ទៃក្នុង និងខ្មាំងខាងក្រៅ ។

**ស៖** ថាតើលោកបានធ្វើការវិភាគឆ្លងគ្នាទៅវិញទៅមកទេ ទៅលើឯកសារផ្សេងៗ ដែលថាអ្នកទាំងអស់នោះត្រូវបានគេចាប់ខ្លួននៅស-២១ និងនៅកន្លែងផ្សេង ។ ថាតើការចាប់ខ្លួននោះវាមានលក្ខណៈចំនួនច្រើនដែរឬទេ?

**ឆ៖** នេះជាសំណួរល្អ ។ ខ្ញុំមិនបានធ្វើការវិភាគបែបនោះទេ នេះជាចំណុចគួរឲ្យចាប់អារម្មណ៍ ប៉ុន្តែមនុស្សមួយចំនួនបានធ្វើការវិភាគបែបនេះ ជាប្រាកដនោះគេក៏បានប្រាប់ផងដែរថា នៅក្នុងឱកាសមួយចំនួន ចំពោះមនុស្សមួយចំនួនដែលគេបានចាប់ខ្លួនហើយនោះ ដើម្បីធ្វើឲ្យ-- ដើម្បីឲ្យអ្នកទាំងអស់នោះចាប់ខ្លួនហើយគេត្រូវតែកម្ទេចនោះ ។ ប៉ុន្តែ មិនបានបញ្ជាក់ពីចំនួនសរុបនោះទេ ក្នុងរយៈពេលដែលអ្នកទោសម្នាក់បានឆ្លើយដាក់មនុស្សម្នាក់ ឬពីរនាក់ ដែលថាគេជាអ្នកបង្រៀននៅសាលាដូចជា ប្រពន្ធ ប៉ុល ពត, ខៀវ ប៉ុណ្ណារី ហើយគឺថា គេឆ្លើយដាក់គាត់ថាជា *ស៊ីអាយអេ* ប៉ុន្តែនៅពេលនោះគឺថាម្នាក់ៗមិនទាន់មិនយល់ច្បាស់ថា *ស៊ីអាយអេ* ជាអ្វី? ហើយ ឌុច បានសរសេរនៅរឹមទំព័រថា តើជាប្រពន្ធរបស់អ្នកណាឈ្មោះនេះ? នេះជាការឆ្លើយដាក់មិនត្រឹមត្រូវ គាត់បានសរសេរអ៊ីចឹង ។ ហើយមិនបន្តទៅទៀតទេ កាលណាមានចំណាត់ការបែបនេះហើយ ។

**លោក វីលៀម ស្មីត៖**

លោកប្រធាន ខ្ញុំមានប្រាំមីនុត ឬក៏ប្រាំពីរមីនុត ខ្ញុំគិតថា ការពិនិត្យនេះគប្បីបន្តដោយអង្គជំនុំជម្រះ ហើយសុំអនុញ្ញាតថាតើសហព្រះរាជអាជ្ញា អាចមានដប់ប្រាំមីនុតទៀតដែរឬទេ ដើម្បីឲ្យសហព្រះរាជអាជ្ញាសួរបានគ្រប់ ហើយអាចនឹងប្រើពេលមួយថ្ងៃ?

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រមតាមសំណើនេះ ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** សូមអរគុណលោកប្រធាន ។ លោកសាស្ត្រាចារ្យ តើលោកអាចនិយាយបានដូចម្តេចដែលថា ឌុច ជាជនជាប់ចោទ ជាអ្នកជំរុញនូវការបោសសម្អាត ហើយនិងសកម្មភាពនៃការចាប់ខ្លួន ទោះបីជាលោកមិនបានធ្វើការសិក្សាពិនិត្យផ្ទៀតផ្ទាត់ តាមមើលរបៀបដែលគាត់ធ្វើការ ដែលថាចម្លើយសារ-ភាពនោះវាមានឆ្លើយឆ្លងគ្នា ស៊ីសង្វាក់គ្នា ដែលថាគេឆ្លើយដាក់ខ្សាំងជនក្បត់បានតាមដំណើរនោះ ។ តើលោកអាចគិតថា វាឆ្លើយតបទៅនឹងសំណើរបស់មេដឹកនាំ ឬក៏គ្រាន់តែជាការជំរុញឲ្យមានការបោសសម្អាត ហើយឲ្យមានអំពើភ័យខ្លាច ព្រួយខ្លាចនៅកម្ពុជាតាមអំពើនោះការងារនោះ?

**ឆ៖** ចម្លើយនេះជាសំណួរល្អណាស់ ដែលខ្ញុំមិនអាចឆ្លើយបាន ដោយមិនបានសិក្សាលម្អិតដោយខ្លួនឯងនោះទេ ។ ប៉ុន្តែ ខ្ញុំមិនច្បាស់ថាតើមនុស្សប៉ុន្មាននាក់ដែលថា ដើម្បីបញ្ជូនចេញពីស-២១ ដើម្បីកំណត់មនុស្សដែលគេឆ្លើយដាក់ក្នុងចម្លើយសារភាពនោះទេ ។ ខ្ញុំមិនគិតថា ដោយសារឈ្មោះហើយនិង

ចំនួនចម្លើយសារភាព ហើយយើងអាច វាពិបាកនឹងកំណត់ថា ភាគច្រើនត្រូវបានគេយកមកតាមការឆ្លើយដាក់នោះទេ ប៉ុន្តែខ្ញុំនឹងឆ្លើយសំណួរមួយចំនួន ។ ហើយយើងមិនអាចថាតើចំណុចណាមួយដែលថាត្រឹមត្រូវ ហើយអាចនឹងជនជាប់ចោទ ហើយនិងអ្នករួមការងារអាចដឹងថាបញ្ជីដែលគេឆ្លើយដាក់ហ្នឹង វាមានតម្លៃ ឬមិនមានតម្លៃក្នុងការបន្តអនុវត្តតាមចម្លើយសារភាពនោះ ។ ប៉ុន្តែ យើងពិនិត្យមើលថា យើងការបញ្ជូនចម្លើយសារភាពទៅថ្នាក់លើនោះ ជាពិសេសចេញពីកម្មាភិបាលមួយ ដូចជាកម្មាភិបាលនៅពាយព្យអីក្រោយពីគេចាប់ខ្លួនហ្នឹង យន្តការខ្សែសង្វាក់នៃការបញ្ជូន និងការឆ្លើយដាក់នោះគេពិនិត្យយកចិត្តទុកដាក់ណាស់ ។ ដូច្នេះហើយ នៅក្នុងបន្ទាប់មានការបោសសម្អាតយ៉ាងខ្លាំង នៅក្នុងភូមិភាគទាំងពីរនោះ ។

**ស៖** សំណួរមួយនេះគឺបានសួរដោយអង្គជំនុំជម្រះរួចហើយ ថាតើយើងអាចនិយាយទេថាស-២១ ជាស្ថាប័នមួយដែលសកម្មក្នុងការចូលរួមនៅក្នុងការកំណត់នូវខ្មាំង ជាជាងស្ថាប័នមួយដែលធ្វើតែការងារ ផ្ទាល់របស់ខ្លួន ដូចជាទទួលអ្នកទោស ហើយនិងសួរចម្លើយ ហើយនិងសម្លាប់នោះ?

**ឆ៖** ពិតហើយ នេះគឺជាការពិពណ៌នាត្រឹមត្រូវហើយ ។ គេបន្តការងាររបស់គេនៅស-២១ និងនៅពេលដែលការសួរចម្លើយ ជាការងារសំខាន់នៃកន្លែងហ្នឹង ។ ជាថ្មីម្តងទៀតដែលខ្ញុំសំណួរនេះបានសួរពីមុនហើយ ហើយហេតុអ្វីបានយើងទទួលបានឯកសារដ៏ច្រើនបែបនេះ។ ការសួរចម្លើយ គឺគេប្រើនៅកន្លែងនោះ ជនជាប់ចោទ ហើយនិងអ្នករួមការងាររបស់គាត់ គឺថាដឹងថាគាត់គេធ្វើអ្វី ត្រូវធ្វើអ្វីនៅពេលនោះ ដោយសារមានការបណ្តុះបណ្តាល ឬក៏អប់រំឱ្យអ្នកសួរចម្លើយនោះល្អធ្វើការល្អ ។ ឯកសារដែលបានបញ្ជាក់ថា ការសួរចម្លើយនោះក៏ អ្នកសួរចម្លើយក៏មានជំនាញនិងបទពិសោធន៍ ហើយក៏គេបានកាន់តែល្អឡើងពីពេលមួយទៅពេលមួយ ។ ហើយការសួរចម្លើយនោះ គឺគេមើលថាតើត្រូវធ្វើដូចម្តេច? តើគេចង់បានអ្វី? ហើយជាពិសេស ជនជាប់ចោទបានដឹង ហើយលះបង់ជាមនុស្សលះបង់ក្នុងការងារហ្នឹង ដើម្បីផលិតនូវលទ្ធផលការងារ ដែលត្រូវការ ដែលថ្នាក់លើរបស់គាត់ចង់បាន ហើយជាមនុស្សដែលគាត់គោរពបំផុតនោះដែរ ។

[១១:៣៥:២៣]

**ស៖** ហើយយើងអាចនឹងចុចនូវចំណុចនេះ ពីមុននោះចម្លើយទៅចៅក្រម ខាតវ៉ាយថ៍ នោះបញ្ជាក់ ឬក៏លោកសរសេរក្នុងសៀវភៅរបស់លោក ឬក៏ផ្អែកលើការសិក្សារកឃើញថា ជនជាប់ចោទជាមនុស្សធ្វើការងារខ្លាំង មនុស្សមានប្រសិទ្ធភាពណាស់ក្នុងការងារ ហើយអ្នកផ្សេង-- ហើយនិងស-

២១ ចង់បង្ហាញទៅថ្នាក់លើថា តើស-២១ធ្វើការខ្លាំងពូកែ ហើយល្អប៉ុនណានោះ? ដូច្នេះ លោកដឹងថា គាត់ហើយនិងអ្នករួមការងាររបស់គាត់ ចង់ប្រាប់ទៅបងថ្នាក់លើ ដូចសរសេរក្នុងសៀវភៅនូវព័ត៌មានទាំងអស់ រាល់ការសង្ស័យទាំងអស់ដែលថ្នាក់លើចង់បាននោះ គឺត្រូវរកឲ្យឃើញទាំងអស់ ។

សំណួររបស់ខ្ញុំ ថាតើលោកគិតថាកម្រិតការងារម៉ឺងម៉ាត់ហ្នឹងខ្លាំងប៉ុនណា គឺដែលនិយាយពីចំនួនជនក្បត់ ឬក៏ខ្មាំងដែលគេបានឆ្លើយដាក់ នៅក្នុងចម្លើយសារភាពក្រោយពីសួរចម្លើយ តើឆន្ទៈរបស់អ្នកដឹកនាំជាន់ខ្ពស់ ឬក៏ជាគំនិតរបស់មេដឹកនាំស-២១ ដើម្បីសម្តែងថា ខ្លួនពូកែការងារ ធ្វើការងារល្អដើម្បីបំពេញបំណងរបស់ថ្នាក់លើ ។ តើលោកច្បាស់ទេសំណួរនេះ?

**ឆ៖** ដោយជាក់ស្តែងនោះ គឺថាជាសំណួរល្អណាស់ គឺថាវាមានចំណុចផ្លូវពីរកន្លែងហ្នឹង ។ ជនជាប់ចោទ ហើយនិងអ្នករួមការងារ គេអាចប្តូរនីតិវិធីការងាររបស់ខ្លួន បើសិនជាយល់ថា មិនពេញចិត្តក្នុងការងារនោះ ។ អ៊ីចឹង គឺថាគេអាចនឹងប្តូរតម្រូវទៅតាមការចង់បានរបស់ថ្នាក់លើ ប៉ុន្តែគេបានផលិតឯកសារ ដើម្បីឆ្លើយតបទៅអ្វីដែលសេចក្តីត្រូវការរបស់ថ្នាក់លើរបស់គេ ។ ប៉ុន្តែចំណុចមួយទៀត ខ្ញុំមិនចង់និយាយច្រើនទេ ខ្ញុំបានបញ្ជាក់ក្នុងសៀវភៅ ប៉ុន្តែយើងបាននិយាយត្រឡប់ទៅសេចក្តីសម្រេច ឬក៏មតិយោបល់របស់ ប៉ុល ពត លើស-២១ នោះ ខ្ញុំពិនិត្យឃើញថា នេះខ្ញុំទទួលបានគំនិតនេះ ប្រហែលជាស-២១ ជារូបភាពធំនៃមេដឹកនាំនោះ គឺមិនសំខាន់ដូចថា អ្នកដែលស្វែងរកភស្តុតាងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនោះទេ ។ ប្រសិនបើយើងមានការប្រជុំគណៈមជ្ឈិមពេលនោះ វាមានឯកសារបួន ឬប្រាំ ពេលនោះខ្ញុំនឹងចម្លែក ប្រសិនជាបញ្ជាក់ស-២១ ជាញឹកញាប់នោះ ។

[១១:៣៨:២៨]

ដែលគេនិយាយថា មានវៀតណាម ហើយនិងចិន ហើយនិងមានជម្លោះតាម-- ជម្លោះវៀតណាម ។ អ៊ីចឹងហើយ នៅក្នុងឯកសារនោះ គឺមាននិយាយច្រើនពីរឿងហ្នឹង ។ ដូចជាព្រឹកមិញនេះហើយខ្ញុំពិនិត្យឃើញថា ជនជាប់ចោទ ហើយនិងអ្នករួមការងាររបស់គាត់ គឺគាត់ប្រឹងធ្វើការងារឲ្យល្អផលិតការងារឲ្យល្អ ដើម្បីកុំឲ្យមានការទិតៀន មានការរិះគន់ នេះហើយជាវិធីដែលដំណើរការដែលខ្ញុំគិតថា-- អ៊ីចឹងកុំឲ្យមានការរិះគន់ ពីថ្នាក់លើ ឬពីកន្លែងណានោះ ។

**ស៖** តើលោកចង់និយាយថាស-២១ ស្ថិតនៅក្នុងរបៀបវារៈរបស់ថ្នាក់លើ ប៉ុន្តែមិនខ្ពស់ដូចប្រធានបទផ្សេងៗទៀតនៅក្នុងពេល ដែលកម្ពុជាប្រជាធិបតេយ្យកាន់អំណាច ។ តើអ៊ីចឹងឬ?

**ឆ៖** បាទ, ខ្ញុំនិយាយអ៊ីចឹង ប៉ុន្តែដោយប្រាកដមេដឹកកំពូល គឺចាប់អារម្មណ៍ខ្លាំងទៅលើចម្លើយសារភាពរបស់កម្មាភិបាលថ្នាក់ខ្ពស់ ដូចជា កុយ ធួន, វន វ៉េត ហើយនិងមនុស្សផ្សេងៗទៀត ដែលឆ្លងនៅក្នុងបណ្តាញនៅក្នុងឆ្នាំ១៩៧៦ និង៧៧ ។ ហើយចម្លើយសារភាពទាំងអស់នោះ ខ្ញុំមិនមានឯកសារទេខ្ញុំគិតថា គឺអានដោយ សុន សេន ឬក៏អានដោយអ្នកផ្សេងទៀតគឺ ដោយថ្នាក់លើ ។ ប៉ុន្តែ ការងារប្រចាំថ្ងៃរបស់ស-២១ ដែលថាទាក់ទងទៅនឹងអ្នកទោសរាប់រយនោះ ។ ប៉ុន្តែ មនុស្សដែលមិនស្ថិតនៅក្នុងលំដាប់ថ្នាក់ខ្ពស់របស់កម្ពុជាប្រជាធិបតេយ្យដូចជា កម្មកររោងចក្រ យោធា គេមិនចាប់អារម្មណ៍នឹងចម្លើយសារភាពរបស់អ្នកទាំងអស់នោះទេ ។ គេយកតែចំណុចណាដែលថាជាអ្នកទោសសំខាន់ដែលគេចង់បានទេ ។ ដែលគេគិតថាប្រហែលជាករណីភាគច្រើនដែលថា ជាគំនិតរបស់ថ្នាក់លើ ដើម្បីថាដល់ពេលដើម្បីយកចំណុចនេះៗដែលត្រូវសួរចម្លើយ ។ ហើយចម្លើយសារភាពវាផ្តល់ទៅលើ ហើយបញ្ជូនមកវិញ ហើយដោយមានសំណួរត្រលប់មកវិញមកសួរអ្នកហ្នឹង ។ អ៊ីចឹងហើយគឺ ចួនកាលគឺការត្រូវវាមានថ្នាក់លើ ចួនកាលវាអត់មាន ។

**ស៖** តើត្រូវទេគឺថាចំពោះមនុស្ស មួយម៉ឺនបួនពាន់នាក់ជាង ដែលលោកប្រមាណថាគេសម្លាប់នៅស-២១ នោះគឺ សុន សេន ឬ នួន ជា គឺជាថ្នាក់ដឹកនាំផ្ទាល់របស់ជនជាប់ចោទ មិនបានផ្តល់ការណែនាំឱ្យមានការសម្លាប់អ្នកទោសម្នាក់ៗ ឬក៏ទាំងអស់នោះ ដោយផ្អែកទៅលើការងារប្រចាំថ្ងៃរបស់ស-២១ ឬក៏អាចជាការព្រួយបារម្ភថាប្រជាជនភាគច្រើន ហ្នឹងគេគិតថាជាអ្នកទោសនោះជាមនុស្សមួយចំនួនតូចដែលថាប្រឆាំងនឹងរបប ។ តើលោកអាចនិយាយបានដូចម្តេច?

**ឆ៖** ខ្ញុំអាចនិយាយបែបនេះ ដោយប្រាកដទៅគេដឹងថា ស-២១ ចាប់ពីខណៈពេលដែលគេបើកប្រតិបត្តិការមកនោះ រហូតដល់ចុងឆ្នាំ១៩៧៨ គេបានប្រគល់ការងារចាត់តាំងឱ្យធ្វើការហ្នឹង គឺថាអ្នកហ្នឹង-- អ្នកខ្លះនៅរស់ ។ អ៊ីចឹងហើយគឺថា អ្នកទោសដែលគេបញ្ជូនមក គេថាត្រូវតែសម្លាប់ ។ ហើយសុន សេន, នួន ជា មិនអាចជាអ្នកសម្រេចទៅលើការសម្លាប់នីមួយៗបាននោះទេ ។

អ៊ីចឹងចៅក្រម ខាតវ៉ាយថ៍ បានសួរមកខ្ញុំ គឺថាស្ថានភាពអមនុស្សធម៌ត្រូវបានបង្កើតឡើងនៅកន្លែងហ្នឹង ប៉ុន្តែគេគិតថាមិនចាំបាច់អ្នកថ្នាក់លើហ្នឹងបញ្ជាជាប្រចាំថ្ងៃ លោកថាក្រៅពីការដឹកនាំបដិវត្តន៍ហើយនិងសង្គមខ្មែរ គឺថាអ្វីដែលគេចាត់ថាខ្លាំងនៅពេលនោះ គឺគេអនុវត្តទៅតាមនោះ ។

**ស៖** អ៊ីចឹងខ្ញុំ-- នៅក្នុង១៥៤ ក្នុងសៀវភៅរបស់លោកគឺវា ទាក់ទងទៅនឹងគំនិតរបស់លោកនៅក្នុងសៀវភៅនោះថា មានមនុស្សពីរក្រុមនៅស-២១ គឺក្រុមធំ គឺជាក្រុមយុវជនក្មេងៗដែលមិនមាន

ការអប់រំខ្ពស់ ហើយមានក្រុមតូចដែលជាក្រុមអតីតគ្រូបង្រៀនមានការអប់រំ ដែលថាមានអាយុចាប់ពី ៣០ឡើងទៅ ហើយមានក្រុមតូចមួយដែលថាលោកនិយាយថា ជនជាប់ចោទ ឌុច មាន ប៉ុន មាន ចាន់ ដែលថាឈ្មោះ ម៉ម ណៃ នោះ ដែលថាមិនអាចទទួលខុសត្រូវក្នុងការទទួលការគោរព ។ ហើយក្រុមការងារ ដោយសារអាយុគេក្មេង គឺគេងាយនឹងគោរពការបញ្ជា ជាពិសេសបញ្ជាបែបឧក្រិដ្ឋនោះ ។ នេះគឺជាគំនិតដែលមានកំណត់នៅក្នុងសៀវភៅរបស់លោក ក្រោយពីបានពិភាក្សា ឬផ្អែកទៅតាមសង្គមវិទ្យា ឬទស្សនវិជ្ជានោះ ។

អ៊ីចឹងហើយ នៅក្នុងចំណុចមួយលោកនិយាយអំពីមេដឹកនាំជាន់ខ្ពស់ ខ្ញុំដកស្រង់សៀវភៅនេះ ។ ហើយនិងខ្ញុំសួរសំណួរពីរបីបន្ទាប់ពីនោះលោកនិយាយថា ជនជាប់ចោទដែលគេចោទឡើង អៀង សារី , នួន ជា, ខៀវ សំផន គឺគេងាយយល់ទេ ប្រហែលថា-- ប៉ុន្តែវាមានកម្រិតទៅក្នុងបរិបទនៅក្នុងការសម្លាប់រង្គាល ហើយនិងអំពើរន្ធត់ ។

[១១:៤៤:៥៤]

ហើយមិនមានអ្វីដែលគ្រប់គ្រាន់ ដើម្បីបញ្ជាក់ថា សុន សេន ហើយនិង ឌុច ហើយនិង បងថ្នាក់លើមិនមានសេចក្តីពន្យល់អ្វីដើម្បីឲ្យពន្យល់បានពីការសម្លាប់មនុស្សមួយម៉ឺនបួនពាន់ជាងនោះទេ។ មនុស្សមួយចំនួន គឺធ្វើឡើងក្នុងនាមមជ្ឈិមបក្សសម្រេចធ្វើការសម្លាប់អ្នកទោស ហើយដែលគ្រប់គ្រងដោយសន្តិបាល ដោយមិនគិតថាអ្នកនោះបានប្រព្រឹត្តអ្វីទេ ហើយធ្វើប្រឆាំងដើម្បីការពារនូវការសម្លាប់ប្រតិបត្តិការ ហើយបង្ហាញពីលទ្ធភាពតាមមាគ៌ាបក្ស ។

របៀបដែលកម្ពុជាប្រជាធិបតេយ្យធ្វើនោះគឺថា សេចក្តីសម្រេច ហើយសុទ្ធតែចេញមកពី ប៉ុល ពត ហើយបានធ្វើឡើងតាមឯកភាព បើទោះណាជាមិនមានការសម្រេច ជាលាយលក្ខណ៍អក្សរជាភស្តុតាងក៏ដោយ ។ បងថ្នាក់លើដែលតាមដានស-២១ គឺ សុន សេន ហើយនិង ឌុច គឺជាអ្នកទទួលខុសត្រូវចំពោះពួកថ្នាក់លើនោះ ហើយគេបានដឹងពីអ្វីដែលខ្លួនធ្វើ ហើយគេសម្រេចបន្តធ្វើ ។ ហើយគេអាចមានលទ្ធភាពថានឹងធ្វើឲ្យមានស្ថានភាពធូរស្រាល ចំពោះអ្នកទោស ហើយនិងអាចនឹងដោះកុមាររាប់រយឲ្យរួចខ្លួន ។ ហើយបើសិនជាខ្លួនសម្រេចធ្វើដូច្នោះ គេអាចធ្វើដូច្នោះមានខណៈពេលមួយនៅក្នុងពេល ស-២១ ដែលថា ពិតជាមានជម្រើសធ្វើទៅបាន ។ ហើយយុត្តិធម៌បដិវត្តន៍ ក៏អាចធ្វើដោយសេចក្តីមេត្តាបានដែរ ។ មិនតែប៉ុណ្ណោះអ្នកដែលនៅរស់រានមានជីវិត ផុតពីរបបកម្ពុជាប្រជាធិបតេយ្យបានលើកឡើងនូវឈ្មោះ កម្មាភិបាលខ្មែរក្រហមមួយចំនួនដែលមានចិត្តល្អ ឬកម្មាភិបាលមិនសូវចិត្តល្អ តឹងតែង ។

ហើយ ឌុច និង សុន សេន ដែលអ្នកធ្វើការនៅក្រោមបង្គាប់ខ្លួននោះ បានបង្កការឈឺចាប់ហួសប្រមាណមកលើអ្នកទោស ហើយមិនមានវិប្បដិសារីអ្វីទេ ។

សំណួររបស់ខ្ញុំចំពោះលោកគឺថា តើលោកនៅប្រកាន់ជំហរផ្អែកទៅលើឯកសារដែលលោកបានពិនិត្យនៅក្នុងបទសម្ភាសន៍ដែលលោកបានអានថា ជនជាប់ចោទមានជម្រើស ថាតើត្រូវអនុវត្តអំពើនោះ ឬមិនអនុវត្តនោះ? ហើយចំណុចទីពីរ តើលោកនៅប្រកាន់ពាក្យថា អ្វីដែលលោកនិយាយក្នុងសៀវភៅថា ជនជាប់ចោទអាចនឹងបន្ថយការឈឺចាប់ ឬក៏ការសម្លាប់នៅស-២១ បាន ។ តាមរបៀបមួយដែលលោករៀបចំ តើអាចទទួលយកបានទេក្នុងគំនិតហ្នឹង ក្នុងបរិយាកាសដែលគេអនុវត្តក្នុងកម្ពុជាប្រជាធិបតេយ្យនៅក្នុងកាលនោះ?

[១១:៤៧:៥០]

**ឆះ** តាមពិតខ្ញុំប្រកាន់យកគំនិតនៅក្នុងកថាខណ្ឌនោះ ។ ខ្ញុំមិនអាចជឿថា អំពើនេះអាចធ្វើទៅដោយមិនមានការកត់សម្គាល់អ្វីនោះទេ ពីព្រោះថា វាការទាក់ទងដែលយើងអាចពន្យល់បាន ។ ប៉ុន្តែម៉្យាងទៀត គំនិតដែលថាមានមនុស្សថាមានជម្រើសក្នុងការគោរព ឬមិនគោរពអ្វីដែលបានគេយល់ថាជាការសម្រេចរបស់កម្ពុជាប្រជាធិបតេយ្យ ដែលរួមទាំងការកំណត់ស្ថានភាពអមនុស្សធម៌ជាទូទៅរបស់របបនោះដែលថាមនុស្ស ដែលចូលមកដល់កន្លែងហ្នឹងហើយ ទោះជាអ្នកគ្មានទោសក៏ដោយ គឺត្រូវតែសម្លាប់ទាំងអស់នោះ ។

បរិបទនោះ គឺចាប់ផ្តើមអនុវត្តតទៅ ប្រហែលជាធានាថា មិនមានជម្រើសនោះទេ គឺជម្រើសគេបានធ្វើពីដំបូង ។ ហើយក្នុងចំណុចនោះ គឺយើងមានការលំបាកក្នុងការបញ្ជាក់ យើងមិនមានឯកសារអ្វីដែលខ្ញុំដឹងពីកម្ពុជាប្រជាធិបតេយ្យនោះ វាមិនទំនងថាសេចក្តីសម្រេចនេះបានធ្វើនៅថ្នាក់កំពូលទេដែលថា គឺថាប៉ុន្តែសេចក្តីសម្រេច គឺថាអាចនឹងធ្វើនៅកម្មាភិបាលថ្នាក់កណ្តាល ។

ខ្ញុំនៅតែគិតថា នេះគឺជាចំណុចសំខាន់ណាស់ ។ ខ្ញុំសូមមិនហ៊ាននិយាយទេ ក្នុងស្ថានភាពបែបនេះ ខ្ញុំពិបាកនឹងបញ្ជាក់ ខ្ញុំអាចនឹងមានកំហុស ដើម្បីនឹងបដិសេធមិនធ្វើអ្វី ។ ប៉ុន្តែខ្ញុំអាច-- មនុស្សដែលអ្នកបង្កនូវភាពឈឺចាប់ធ្ងន់ធ្ងរទៅលើអ្នកផ្សេងទៀតនោះ ដឹងពីអ្វីដែលខ្លួនបានដឹងថា វាស្ថានភាពហ្នឹងអាក្រក់ណាស់ ហើយក៏មិនទំនងជានឹងគិតថាមានការឈឺចាប់ទេ អ្វីដែលខ្លួនបង្កទៅលើគេនោះ ។ ដូចដែលខ្ញុំនិយាយនៅក្នុងសៀវភៅរបស់ខ្ញុំ មិននាំឲ្យគេសម្រាន្តមិនលក់ ហើយបើនឹកទៅគឺថាចំណារផ្ទាល់ដៃនោះ គឺវាមានលក្ខណៈស្ថិរភាព ដូចថាមានការពេញចិត្តក្នុងការងារពីមួយទៅមួយថ្ងៃនោះ ។

[១១:៥០:២២]

ប៉ុន្តែ នៅក្នុងកថាខណ្ឌដែលខ្ញុំសរសេរមួយនៅក្នុងជំពូកចុងក្រោយហ្នឹង ខ្ញុំប្រើពេលចុងច្រើនខែដើម្បីសរសេរ ខ្ញុំនឹងប្រកាន់នូវជំហរទាំងអស់ហ្នឹង ដែលមានសរសេរនៅក្នុងសៀវភៅហ្នឹង ។

**ស៖** សូមអរគុណ ។ ខ្ញុំមានសំណួរពីរចុងក្រោយ ក្នុងចំណោមចំណារផ្ទាល់ដៃដែលជាងមួយរយ ដែលលោកបានសិក្សា នៅលើរបាយការណ៍ចម្លើយសារភាព ហើយលោកបានអានជាច្រើននៅក្នុងបណ្ណសារ តើលោកបានឃើញឯកសារមួយដែលបានបង្ហាញថា ជនជាប់ចោទជំទាស់ ឬក៏ប្រឆាំងថាមិនព្រមធ្វើការងារហ្នឹង? ឬក៏មានឯកសារមួយ ឬចំណារមួយដែលថាគាត់មិនមានការពេញចិត្ត ឬក៏ស្អប់ការងារនៅក្នុងការងាររបស់គាត់ហ្នឹងដែរឬទេ?

**ឆ៖** គឺជាការសម្លាប់ខ្លួនឯង បើសិនជាសរសេរផ្ទាល់ដៃបែបនោះ ។ ប៉ុន្តែ នៅក្នុងកន្លែងខ្លះគាត់បញ្ជាក់ថាប្រហែលជាកុំឲ្យប្រើទារុណកម្មពេក ឲ្យប្រើនយោបាយឲ្យច្រើនជាង ។ ហើយនៅមានព័ត៌មានស្រដៀងគ្នានេះ នៅក្នុងឯកសារដែលខ្ញុំបានអាននៅក្នុងស-២១ហ្នឹង គឺថាគាត់ពេញចិត្តនឹងចម្លើយសារភាពដែលទទួលបានមិនមានទារុណកម្មនោះ ។ អ៊ីចឹងហើយគាត់អះអាងថាគាត់នឹងសប្បាយក្នុងការគ្រប់គ្រងអ្នកទោស បើសិនជាបានចម្លើយសារភាពដោយមិនមានទារុណកម្ម ។ ប៉ុន្តែ ខ្ញុំមិនបានឃើញនៅក្នុងឯកសារជាភស្តុតាងនោះទេ ដែលបញ្ជាក់ថាគាត់មានវិប្បដិសារីខ្លាំង សោកស្ដាយខ្លាំងដោយគាត់ដឹងពីអំពើកំហុសរៀងរាល់ថ្ងៃ ពីមួយថ្ងៃទៅមួយថ្ងៃក្នុងកាលនោះៗ ។ អ៊ីចឹងហើយយើងមើលឃើញថា គឺជាភាពលើសលប់ដែលបានធ្វើចំណារគ្រប់ចម្លើយសារភាពមួយចំនួននោះ ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ទាក់ទងទៅនឹងការបង្កឲ្យមាន អំពើព្រឺខ្លាចនៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះ ។ ក្នុងសៀវភៅរបស់លោក មួយចំនួនលោកបាននិយាយដល់អ្នកទោសម្នាក់រត់ចេញពីស-២១នៅក្នុងទំព័រ១៦ ។ គឺថាមានមនុស្ស៨០នាក់ ទំព័រ៣១ និយាយថា ៨០នាក់រត់ចេញពីព្រៃស អំពី ហ៊ុយ ស្រែ ថ្ងៃទី២៧ ខែ១១ ឆ្នាំ៧៧ នៅទំព័រ៣២ ១៩៧៨ នៅដីកក្រែង សៀមរាប នៅភូមិភាគឧត្តរ ។ ហើយមានកម្មាភិបាលនិងប្រជាជនរត់ទៅប្រទេសថៃ ហើយនិងមុនពេលឆ្នាំ១៩៧៧ ដល់ ១៩៧៨ គឺថាមនុស្សរាប់ពាន់រត់វៀតណាម ហើយភាគច្រើនសុទ្ធតែជាកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពី ១៩៧៧ ហើយមានបរទេស ហើយនិងខាងកុម្មុយនីស្តនោះអាចនឹងបន្តការងារដែលថា ស្ថិតនៅក្នុងភាពខ្វះខាតដែលគេនិយាយនៅពេលនោះ ។ ហើយដែលគេនិយាយដល់ពីអំពើរបស់កម្ពុជាប្រជាធិបតេយ្យកាលណោះ ។ តាមការអានភាគច្រើនរបស់លោក តើលោកអាចឲ្យតួលេខចំនួនដែលបានរត់ចេញពី

កម្ពុជាប្រជាធិបតេយ្យទៅប្រទេសថៃ ទៅកន្លែងណាផ្សេង តើលោកអាចធ្វើការប៉ាន់ប្រមាណបានទេ?

[១១:៥៤:២៣]

**ឆ៖** សូមអភ័យទោស ការសិក្សាមិនបាននាំខ្ញុំទៅដល់កន្លែងនោះទេ ។ ជនភៀសខ្លួនដែលទៅប្រទេសថៃមកពីកម្ពុជាពីមុននោះ មុនពេលរបបហ្នឹងដួលនោះ គឺថាថៃគេមិនទទួលទេ ។ មានចំនួនតិចតួចណាស់ពួកនោះ ។ កម្មាភិបាលកម្ពុជាប្រជាធិបតេយ្យមួយចំនួន គឺមានបញ្ជាក់នៅក្នុង-- អ៊ីចឹងហើយយើងដឹងថាគេបានទប់ស្កាត់មិនឲ្យចេញពីប្រទេសទេ ។ ប៉ុន្តែ និយាយពីព្រំដែនវៀតណាមវិញ គឺមិនសូវតឹងរឹង ប៉ុន្តែបន្ទាប់ពីឆ្នាំ១៩៧៦-៧៧ គឺថាមានមនុស្សអាចរត់ចេញទៅខាងវៀតណាម ខ្ញុំបានដឹងថា គឺគោលនយោបាយរបស់វៀតណាមនោះមានការកែប្រែបន្តិចបន្តួច ។ ហើយបន្តបន្ទាប់គឺគេមិនអនុញ្ញាតឲ្យចូលទៅវៀតណាមទេ បើចូលគេនឹងបញ្ជូនមកវិញ ។ ប៉ុន្តែក្រោយមក គឺគេស្វាគមន៍ ។ ប៉ុន្តែចំនួនពិតប្រាកដដែលថាទៅវៀតណាមគឺថាក្រោមមួយពាន់ទេ ។ ខ្ញុំស្មានថាទៅថៃវិញ គឺប្រហែលប្រាំរយនាក់ អីប៉ុណ្ណឹងទេ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណ លោកសាស្ត្រាចារ្យ សូមអស់សំណួរ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ពេលត្រូវសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ។ អ៊ីចឹង អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ហើយសវនាការនឹងលើកទៅបន្តនៅរសៀលនេះចាប់ពីម៉ោងមួយកន្លះ ។ សូមជម្រាបជូនដល់សាធារណជននិងភាគីឲ្យបានជ្រាប ។ ហើយមន្ត្រីតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកឲ្យបានសមរម្យអ្នកជំនាញរូបនេះ នៅក្នុងអំឡុងពេលឈប់សម្រាក ហើយឲ្យនាំគាត់មកកាន់សាលសវនាការ ឲ្យបានមុនម៉ោងមួយកន្លះរសៀលនេះ ។

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការវិញ នៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ ។

**លោកស្រី សែកុល វុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១១:៥៦នាទី ដល់ម៉ោង ១៣:៣១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអរញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មសាក្សីអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ជាបន្ត ។ ហើយជាបន្តទៅនេះអង្គជំនុំជម្រះសូមប្រគល់វេទិការទៅមេធាវី អ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីមានឱកាសក្នុងការសួរដល់អ្នកជំនាញរូបនេះ។ ប្រសិនបើមានសំណួរសូមអញ្ជើញ ។

**ការតាំងសំណួរដោយក្រុមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី៖**

**លោកស្រី ហ្សាប៊ីយ៉ែន ទ្រូស ណាព្រូស៖**

សូមអរគុណលោកប្រធាន ដែលបានប្រគល់វេទិកាឲ្យខ្ញុំ ។  ខ្ញុំមានសំណើមួយដែលធ្វើឡើងក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលចង់ប្រើពេលល្ងាចនេះ ។ ហើយយើងខ្ញុំចង់-- ដោយយើងត្រូវធ្វើសក្ខីកម្ម លើអ្នកជំនាញដ៏ពិសេសនេះ ខ្ញុំសូមៗពេលបន្ថែមសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីយើងសួរសំណួរទាំងអស់ទៅលោក ដេវីដ ឆេនដ៍ល័រ ។ ពីព្រោះថា ចំណុចនេះនឹងមិនធ្វើឲ្យខូចពេលរបស់មេធាវីការពារទេ ពីព្រោះមេធាវីការពារបានពេលវេលាបន្ថែមហើយ នេះជាសំណើរបស់ខាងក្រុមយើងខ្ញុំ។ យើងខ្ញុំចង់បានពេលយ៉ាងតិចមួយម៉ោង ។

**ប្រធានអង្គជំនុំ៖**

ដោយសំណូមពររបស់មេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដែលលើកឡើងអំពីសារសំខាន់នៃការស្តាប់សក្ខីអ្នកជំនាញ  ហើយកាលពីព្រឹកមិញអង្គជំនុំជម្រះក៏បានពន្យារពេលដល់ទៅសហព្រះរាជអាជ្ញាផងដែរនោះ  ដូច្នេះអង្គជំនុំជម្រះសម្រេចយល់ព្រមបន្ថែមពេលវេលាដប់ប្រាំនាទី  លើពេលវេលាដែលផ្តល់ឲ្យមេធាវីអ្នកតំណាងដើមបណ្តឹងរដ្ឋប្បវេណី សែសិបនាទី ។ ដូច្នេះ គឺមេធាវីអ្នកដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាសរុប ទាំងពេលវេលាបែងចែកឲ្យ ហើយថែមទាំងពេលវេលាបន្ថែមហាសិបប្រាំនាទី ចាប់ពីពេលនេះតទៅ ។ សូមអញ្ជើញ ។

[១៣:៣៤:៣៦]

**សួរដោយលោកស្រី ហ្សាប៊ីយ៉ែន ទ្រូស ណាព្រូស៖**

សូមអរគុណលោកប្រធាន ។ លោក ឆេនដ៍ល័រ ខ្ញុំឈ្មោះ ហ្សាប៊ីយ៉ែន ទ្រូសណាព្រូស ខ្ញុំជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី ។  ហើយដូច្នេះ  ជាក្រុមរបស់ខ្ញុំជាអ្នកសួរលោកមុន  ខ្ញុំនឹងសួរសំណួរលោកទាក់ទងទៅនឹងចំណុចមួយអំពីតួនាទីរបស់ ឌុច នៅស-២១ ។ លោកបាននិយាយព្រឹកនេះថា ឌុច

បំពេញមុខងាររបស់ខ្លួន ដើម្បីបំពេញទៅតាមបំណងប្រាថ្នារបស់មេដឹកនាំ ហើយជាពិសេសដើម្បីកម្ទេចខ្មាំងនិងខ្សែក្បត់នោះ ។

ខ្ញុំមិនចង់ដាក់ ឌុច ទៅក្នុងស្ថានភាពមួយថាគាត់ជាឃាតកដែលសាមញ្ញធ្វើហ្នឹងទេ ប៉ុន្តែបើមើលសៀវភៅលោកម្តងទៀតដែលសរសេរថា "សំឡេងពីស-២១" នោះជាអត្ថបទភាសាបារាំងនោះ លោកបានរកឃើញជីវប្រវត្តិ ឬប្រវត្តិរូបរបស់ ឌុច ។ លោកនិយាយថា គាត់មានចាប់ គាត់បានចាប់ផ្តើមធ្វើការក្នុងបដិវត្តន៍តាំងពីដើមទសវត្សរ៍ឆ្នាំ៧០ ក្នុងសន្តិសុខនៅក្នុង៧តំបន់៣៣ ជិតភ្នំពេញ ។ ហើយនៅក្នុងតំបន់នេះទៀត នៅពេលគាត់ជាប្រធាននៅក្នុងតំបន់៣៣នោះ គាត់បានជួបជាមួយលោក *ប៊ីហ្សូ* ជាអ្នកជំនាញសិក្សាម្នាក់ ។ ហើយយើងដកស្រង់សម្តីរបស់ លោក *ប៊ីហ្សូ* នៅក្នុងសៀវភៅរបស់គាត់ នៅក្នុងទំព័រ៣៩ ឧបសម្ព័ន្ធ 0035725 ជាភាសាបារាំងនោះ ។ លោក *ប៊ីហ្សូ* បានជួបនឹងស្ថានភាពជាមួយ ឌុច ហើយតាមសម្តីរបស់*ប៊ីហ្សូ*នោះ ឌុច មានគំនិតមួយដែលបញ្ជាក់ថា គាត់ធ្វើការងារនោះគឺក្នុងការបម្រើចលនាបដិវត្តន៍ ។ ហើយគាត់និយាយថា ឌុច មានជំនាញក្នុងផ្នែកខាងសន្តិបាលនៅក្នុងរយៈពេលនោះរវាងឆ្នាំ១៩៧២ និង១៩៧៣ ។ គាត់បានពន្យល់ គាត់ប្រើពាក្យទស្សនទាន អំពីក្បត់ជាតិឬក៏ខ្សែខ្មាំង គឺខ្សែក្បត់ បណ្តាញក្បត់នោះ ។ ដើម្បីបោសសម្អាត ឬក៏ធ្វើវិសុទ្ធកម្មពួកខ្មែរហាណូយ ហើយលោកបានបន្ថែមបានអំពីចរិតលក្ខណៈដែលគ្មានមេត្តារបស់ជននេះ គឺឆ្លើយតបទៅនឹងការគ្រប់គ្រងក្នុងវិស័យរដ្ឋបាលក៏បានប្រើគំនិតហ្នឹងដែរ ។

**ស៖** តើលោកអាចផ្តល់គំនិតអ្វីនៅក្នុងហ្នឹង ហើយគាត់បានយកគំនិតហ្នឹងមកប្រើនៅស-២១ដែរ។ អ៊ីចឹង ឌុច មិនបានប្រកាន់-- មិនត្រូវបានជ្រើសរើសយកមកប្រើដោយចៃដន្យនោះទេ ប៉ុន្តែតាមពិត គាត់បានបង្កើនចំណេះដឹងនិងជំនាញរបស់គាត់ក្នុងរយៈពេលមួយចំនួន ផ្អែកលើជីវប្រវត្តិរបស់គាត់នោះ ។ ពាក់ព័ន្ធទៅនឹងចំណុច ដែលទើបតែខ្ញុំរៀបរាប់នេះ ហើយនិងអ្វីដែលលោកបានប្រាប់យើងពីព្រឹកមិញនេះ តើនៅទីបំផុត ឌុច បានអនុវត្ត ហើយនិងប្រព្រឹត្តទៅតាមតែអ្វីដែលគេប្រាប់ឲ្យគាត់ធ្វើ ឬក៏គាត់ជាអ្នកបង្កើតនូវប្រព័ន្ធ កែលំអនូវប្រព័ន្ធ ហើយគាត់ធ្វើឲ្យស-២១ នោះវាដំណើរការទៅតាមគោលគំនិតរបស់គាត់នុ៎ងដែរឬទេ?

[១៣:៣៩:១៩]

**ឆ៖** សូមអរគុណ គឺមានសំណួរជាច្រើននៅក្នុងសំណួរនេះ ។

ចុងក្រោយនេះ ខ្ញុំគិតថាអ្វីដែលលោកស្រីនិយាយនោះគឺថាគាត់មិនធ្វើអ្វីៗទាំងអស់តម្រូវទៅតាម

ថ្នាក់លើនោះទេ ។ ប៉ុន្តែ ខ្ញុំនិយាយថា គាត់ធ្វើអ្វីៗដើម្បីឲ្យស-២១ នោះបំពេញភារកិច្ចរបស់ខ្លួនឲ្យបានត្រឹមត្រូវ ។ ប៉ុន្តែ អ្វីដែលលោកស្រីលើកឡើងនោះគឺត្រឹមត្រូវហើយ ព្រឹកមិញនេះ ខ្ញុំបាននិយាយថាគាត់ជាមនុស្សឧស្សាហ៍ព្យាយាមក្នុងការងារ មានមោទនភាពក្នុងការគ្រប់គ្រងស-២១ ដែលធ្វើការក្នុងលក្ខណៈ បច្ចេកទេសវិធីសាស្ត្រចាប់ពីចំណុចដំបូងមក មិនមានគំរូណាមួយពីដំបូងមុននឹងទេ ។

ជាពិសេសនៅក្នុងសង្គ្រាមស៊ីវិលនោះ ហើយគាត់បានបង្កើត ហើយបានកែលំអរពីពេលមួយទៅពេលមួយនូវជំនាញនិងចំណេះដឹង ។ គឺគាត់ធ្វើយ៉ាងណាឲ្យមេ ថ្នាក់លើយល់ថា គាត់ធ្វើការងារល្អ ។ ប៉ុន្តែគាត់ខ្លួនឯង គឺមិនមែនជាការងារត្រឹមតែពេញចិត្ត គឺត្រូវធ្វើឲ្យការងារឲ្យល្អបំផុត ឲ្យពូកែបំផុត ។ ហើយគាត់ចង់-- បើសិនជាក្នុងខណៈជាសិស្សវិញ ចង់ជាសិស្សពូកែ គឺជាជនបដិវត្តន៍ដ៏ពូកែ ។ ហើយគួរឲ្យចាប់អារម្មណ៍នោះ គឺមិនគ្រាន់តែបំពេញទៅតាមចំណង់ចំណូលចិត្តថ្នាក់លើនោះ គឺមិនគ្រប់គ្រាន់ទេគឺថាវាចេញពីមនោសញ្ចេតនា ហើយនិងឲ្យអស់សមត្ថភាព អ្វីដែលខ្លួនមានមោទនភាពក្នុងការងារនោះឯង ។

**ស៖** សូមអរគុណលោក ឆេនដ៍ល័រ ។ តាមពិតដើម្បីត្រឡប់ទៅចំណុចមួយដែលលោកទើបតែបាននិយាយ មានការលំបាកមួយចំនួនក្នុងដំណើរការនីតិវិធីនោះ ទាក់ទងនឹងការកំណត់តួនាទីរបស់ ឌុច ក្នុងពេលសួរចម្លើយ ឬពាក់ព័ន្ធទៅនឹងការប្រើទារុណកម្ម ។ តាមពិតក្នុងរយៈពេលមួយចំនួននោះ គាត់បញ្ជាក់ថា គាត់មិនបានវត្តមាននៅពេលសួរចម្លើយ ហើយគាត់មិនបានដឹងរបៀបគេប្រើទារុណកម្មនោះដូចម្តេចទេ ដោយសារផ្អែកលើឯកសារ ដែលលោកប្រើដើម្បីសរសេរសៀវភៅនោះ ផ្អែកលើការវិភាគទៅលើបុគ្គលិកលក្ខណៈរបស់ ឌុច ដែលលោកបានសិក្សានោះ ។ ផ្អែកលើប្រវត្តិរូបផ្ទាល់ខ្លួន ថាតើលោកមិនបានគិតគូរដល់អ្វីដែលកើតឡើងនៅស-២១ ឬក៏អំពើទាំងអស់នោះ គាត់មិនអើពើ ឬក៏ គាត់ដឹងដែរនៅក្នុងស-២១ កាលនោះ?

[១៣:៤២:៤៣]

**ឆ៖** គឺជាសំណួរល្អណាស់ ប៉ុន្តែចំណុចពីរចុងក្រោយនោះគឺគាត់ធ្វើការងារ គាត់ដឹងឬមិនដឹងអ្វីដែលបានកើតឡើងនោះ ហើយគាត់មិនចង់បង្ហាញវត្តមានរបស់គាត់ទេ ។ ហើយជាពិសេសអ្នកសួរចម្លើយនោះគឺបានប្រព្រឹត្តមិនល្អ ។ ពេលខ្លះ គេយកអ្នកទោសមកស-២១ ដើម្បីរងនូវអំពើទាំងអស់នោះ ហើយបើសិនជាគេចាត់តាំងឲ្យមនុស្សណានៅក្រោមគាត់ ហើយឲ្យជូនដំណឹងមកគាត់វិញជារៀងរាល់ថ្ងៃអំពីអ្វីកើតឡើងនោះ ។ អ្វីដែលអ្នកទោសមកគុកច្រើនរៀងរាល់ថ្ងៃនោះ អ៊ីចឹងគឺគាត់ត្រូវតែចំណាយ

ការយកចិត្តទុកដាក់ច្រើន ប៉ុន្តែចំពោះអ្នកតូចតាចក្រោមបង្គាប់វិញ បើផ្អែកទៅលើគំនិតមួយដែលគាត់ជាមនុស្សតែម្នាក់គាត់ដែលម្នាក់គត់ដែលផ្តួចផ្តើមគំនិតនៅស-២១។ អ្វីជាចរិតលក្ខណៈរបស់ជនបដិវត្តន៍របស់ចិនឬក៏កម្ពុជានោះ គឺអាចវាអាស្រ័យទៅលើបុគ្គលម្នាក់ក្នុងការប្រព្រឹត្តតាមរបៀប ដែលជាជនបដិវត្តន៍ធ្វើនោះឯង ។

អ៊ីចឹងគាត់បានអនុវត្តនិងជួយដល់អ្នកក្រោមបង្គាប់របស់គាត់ឲ្យបានស្ទិទ្ធស្នាល ឲ្យមានលក្ខណៈសកម្មក្នុងនាមជាជនបដិវត្តន៍ដូចដែលគេរំពឹងឲ្យប្រព្រឹត្តទៅតាមគោលការណ៍មាគ៌ាបដិវត្តន៍របស់គេនោះឯង ។ អ៊ីចឹងគាត់គឺ ជាអ្នកផ្តួចផ្តើមតែមួយគត់ ហើយជាអ្នកតាមដានមើលម្នាក់គាត់ទៅលើអ្វីៗដែលកូនចៅរបស់គាត់បានធ្វើនៅកន្លែងនោះ ។ អ៊ីចឹងហើយ គឺមិនអាចនឹងនិយាយថា គាត់ចៀសចេញបានពីការតាមដានពិនិត្យមើលនោះបានទេ អ៊ីចឹងហើយអ្វីដែលខ្ញុំចាប់អារម្មណ៍ផ្អែកទៅលើការសិក្សារបស់ខ្ញុំ គាត់គឺជាមនុស្សមានលទ្ធភាព ហើយមានសម្តភាពគុណភាពល្អនៅក្នុងការងាររដ្ឋបាល អ្វីល្អដែលគេចាត់តាំងឲ្យគាត់ធ្វើនោះឯង ។

[១៣:៤៥:១៥]

**ស៖** សូមអរគុណលោក ឆេនដ័ល័រ លោកបានលើកឡើងនូវគំនិតមួយដែលចៅក្រម ឡាវ៉ែន៍បានសួរ ហើយលោកបញ្ជាក់ថា លោកបញ្ជាក់អំពីការបង្កើតលក្ខខណ្ឌអមនុស្សធម៌នៅស-២១ ជាពិសេសប្រឆាំងទៅលើអ្នកទោសក្នុងកាលនោះ ប៉ុន្តែខ្ញុំចង់តត្រលប់ទៅនឹងអំពើអមនុស្សធម៌ដែលទាក់ទងទៅនឹងបុគ្គលិក ឬក៏អ្នកយាម ឬក៏អ្នកសួរចម្លើយ ពីព្រោះតាមពិតនោះ យើងអាចនឹងឆ្ងល់ថា តើយើងអាចប្រព្រឹត្តអំពើបែបនោះបានដោយមិនមានមនោសញ្ចេតនាវិប្បដិសារីហ្នឹងដូចម្តេចនឹងកើត? ថាតើលោកអាចពន្យល់យើងបន្ថែមទៀតទេពីបាតុភូតបែបនេះ? ដោយហេតុថា នៅក្នុងសៀវភៅរបស់គាត់ លោកបានលើកឡើងនូវសេចក្តីសន្និដ្ឋានដ៏ល្អទាក់ទងទៅនឹងចំណុចនេះ ហើយខ្ញុំនឹងអានឡើងវិញនូវទំព័រ១៦៦ ០០៧៤ ជាERN 32 ការពន្យល់ពីបាតុភាពនោះ ដូចជា ស-២១នេះ គឺស្ថិតនៅក្នុងលទ្ធភាពអាចនឹងលើកលែងបាន ហើយនិងអ្នកកាន់កាប់នោះក៏អាចនឹងធ្វើឲ្យល្អបំផុតបាន ដោយផ្អែកទៅលើអំពើស្អប់ខ្ពើម ឬក៏អ្នកធ្វើទុក្ខទៅលើអ្នកដែលគ្មានការពារខ្លួនបាននោះ ។ តើលោកអាចពន្យល់អ្វីបានបន្ថែមបានទេ ថាតើលោកយល់ស្ថានការណ៍បាតុភាពនេះបានដូចម្តេចចំពោះអ្នកទាំងអស់ដែលធ្វើការនៅស-២១ នោះ?

**ឆ៖** លោកដកស្រង់ចំណុចចុងក្រោយមួយក្នុងសៀវភៅរបស់ខ្ញុំ ដែលខ្ញុំសង្ខេបឲ្យបានខ្លីតាមដែលអាចធ្វើទៅបាននូវអ្វីដែលខ្ញុំយល់ គឺថាមិនតែនៅស-២១ទេ នៅក្នុងខណៈពេលផ្សេងៗ ទីកន្លែង

ផ្សេងនៃប្រវត្តិសាស្ត្រដែលមានហេតុការណ៍ហ្នឹងកើតឡើងទាក់ឡើងការមនុស្សឃាតនៅឥណ្ឌូនេស៊ីសម័យហាយនភាពរបស់អាល្លឺម៉ង់ ហើយនិងនៅក្នុងទសវត្សរ៍ឆ្នាំ៧០ ដោយជនជាតិក្រិច គឺថាជាបាតុភូតសាកលមិនមែនពិសេសតែស-២១ នោះទេ ។ ដែលធ្វើឡើងដោយមនុស្សដែលធ្វើការងារដោយមានការអនុញ្ញាតដែលគេបានប្រកាន់នូវអកប្បកិរិយាបំបាត់លក្ខណៈជាមនុស្សធម៌ទៅលើអ្នកដទៃនោះរួចជាស្រេច គឺថាមនុស្សជាអ្នកសម្លាប់មនុស្ស ដោយមិនបានគិតគូដល់ការបំផ្លិចបំផ្លាញទៅលើមនុស្សដទៃដូចជាការកម្ទេចខ្មាំងជាដើមនោះ គឺជាគោលនយោបាយមួយរបស់គេ ។ ហើយខ្ញុំបានអានចំណុចមួយអំពីការពិសោធន៍ ។ ខ្ញុំបានសរសេរដោយសង្ខេបទេចំណុចនោះ របៀបដើម្បីស្វែងយល់នូវបាតុភូតនៃស-២១ ដើម្បីឲ្យច្បាស់ ដើម្បីឲ្យ-- ហើយខ្ញុំទៅធ្វើការហ្នឹងបួនឆ្នាំដើម្បីបញ្ចប់សៀវភៅនោះ ។ អ្វីដែលកើតឡើងនៅស-២១ គឺត្រូវបានធ្វើឡើងដោយមនុស្សមួយក្រុមដែលបញ្ជាពីចំងាយដែលធ្វើពីចម្ងាយ ប៉ុន្តែខ្ញុំចង់បញ្ជាក់ថា ទៅតាមលក្ខខណ្ឌមួយចំនួន ខ្ញុំមិនជួបប្រទេះនៅក្នុងជីវិតរបស់ខ្ញុំទេ ដែលថាស-២១ ដែលអាចនឹងគេដឹកនាំពីចម្ងាយឲ្យធ្វើការ ហើយសកម្មក្នុងលក្ខណៈបែបហ្នឹងបាននោះ ។

[១៣:៤៩:៥៣]

បុគ្គលិកនៃស-២១ គឺដូចជាអ្នកសិក្សានៅក្នុងរបបហាយនភាព ដូចជាលោក គ្រីស្តូហ្វ័រ ប្រោននីង កាលណាអកប្បកិរិយាហ្នឹងត្រូវបានប្រព្រឹត្តឡើងហើយមិនទទួលទណ្ឌកម្មទេ គេចេះតែអនុញ្ញាតឲ្យបន្តទៅទៀតកាត់តែធ្ងន់ទៅៗទាក់ទងទៅនឹងមហាបដិវត្តន៍វប្បធម៌នោះដែរ គឺថាគេចេះតែដំណើរការដោយមានការពេញចិត្ត ថាតើពិតឬមិនពិតនោះ ខ្ញុំមិនច្បាស់ទេ គឺជារង្វង់ងងឹតមួយចំពោះយើងទាំងអស់គ្នា ដែលខ្ញុំបញ្ជាក់នៅក្នុងវគ្គចុងក្រោយនៃសៀវភៅរបស់ខ្ញុំ មិនមែនចេញមកពីការសិក្សាពិសោធន៍ដែលប្រៀបធៀបទៅនឹងស-២១ទេ ប៉ុន្តែវាកើតឡើងពីបាតុភូតច្រើនឆ្នាំទាក់ទងទៅនឹងហេតុការណ៍នេះ។

**លោកស្រី ហ្វាប៊ីយ៉ែន ទ្រូស្សណាព្រូសៈ**

សូមអរគុណលោក ឆេនដ័ល័រ ខ្ញុំមិនមានសំណួរអ្វីទៀតទេ ។ ខ្ញុំអនុញ្ញាតឲ្យសហមេធាវីរបស់ខ្ញុំក្នុងក្រុមទីបី នឹងសួរសំណួរលោកជាបន្ត ។

**សួរដោយលោក គីម ម៉េងឃី៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម សូមគោរពអង្គសវនាការទាំងមូល ។

**ស៖** ខ្ញុំបាទមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមបីមានសំណួរមួយចំនួនតាំងសួរទៅលោកដេវីដ ឆេនដ័ល័រ ។ ឆ្លើយតបទៅនឹងសំណួររបស់លោកស្រី ហ្វាប៊ីយ៉ែន មុននេះ លោកបានលើកឡើងថា

ជនជាប់ចោទគឺមានមោទភាពចំពោះការងាររបស់ខ្លួន ហើយជនជាប់ចោទបានបំពេញការងារយ៉ាងហ្មត់ចត់នៅក្នុងបេសកកម្ម នៅក្នុងទាំងមន្ទីរ ម-១៣ និងមន្ទីរ ស-២១ នេះ ។

ដូច្នេះ សំណួររបស់ខ្ញុំសួរថាតើការកម្ទេចខ្មាំង និងការជ្រើសរើសខ្មាំងដែលលោកបានរៀបរាប់តាមរយៈការស្រាវជ្រាវឯកសារ និងសម្ភាសន៍កន្លងមកនេះនៅក្នុងសៀវភៅរបស់លោក តើលោកអាចបញ្ជាក់បានទេថា សម្រាប់មេដឹកនាំខ្មែរក្រហមដែលទទួលខុសត្រូវខ្ពស់បំផុត និងជនជាប់ចោទដែល ជាអ្នកដឹកនាំមន្ទីរស-២១ នោះ គិតថាការកម្ទេច និងការបោសសម្អាតនេះ គឺជាជោគជ័យនៃការធ្វើបដិវត្តន៍របស់គេ ឬក៏ដូចដែលពាក្យស្លោកដែលគេនិយាយថា “មហាបដិវត្តន៍ មហោលោតផ្លោះ” អ៊ីចឹង មែនដែរឬទេ?

[១៣:៥២:៤៥]

**ឆ៖** ខ្ញុំមិនប្រាកដថាខ្ញុំអាចឆ្លើយទៅនឹងចំណុចចុងក្រោយនៃសំណួររបស់លោកបានទេ ដូចដែលខ្ញុំនិយាយពីខាងដើមអ៊ីចឹង ដែលថាមនុស្សភាគច្រើនលើកឡើងហើយ គឺថាការសម្លាប់គឺជាបញ្ហាស្នូលនៃកម្ពុជាប្រជាធិបតេយ្យ ។ អ៊ីចឹងហើយយើងមានការលំបាកកាន់តែខ្លាំង ឬក៏កាន់តែស្មុគស្មាញ ។ នៅក្នុងឆ្នាំ១៩៧៨ ចរិតលក្ខណៈនៃបដិវត្តន៍នោះ គឺជាចំណុចមួយបន្តវែងឆ្ងាយ ហើយវាមានការពេញចិត្តពេញថ្លើមខ្លួនឯង គឺកាយវិការបដិវត្តន៍នោះ គឺធ្វើយ៉ាងម៉េចកុំឲ្យមានបញ្ហានោះកើតឡើងជាថ្មី គឺបំបាត់ គឺគេមានទំនុកចិត្តដាច់ខាត គឺគេធ្វើហ្នឹងក្នុងផ្លូវត្រូវ ប៉ុន្តែវាជាការគ្រោះថ្នាក់មួយដែលថាមិនមានអ្នកណាម្នាក់ត្រូវបានមិនឲ្យអ្នកណាចោទសួរតទល់ មិនឲ្យមានការសង្ស័យ មិនឲ្យមានឱកាស ហើយនិងតទល់បាន។ អ៊ីចឹងយើងដឹងច្បាស់ហើយ គឺមិនមានអ្នកណាម្នាក់អាចជំទាស់នឹងការដឹកនាំគេបានទេ ។ អ៊ីចឹងគេអាច-របបនោះក្លាយទៅជាដូចជាទំនប់ទឹកបាក់ទំនប់នោះឯង មិនអាចទប់បានទេ ។

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ ។ សំណួរបន្តទៀតពាក់ព័ន្ធទៅនឹងឧក្រិដ្ឋកម្មនៅក្នុងមន្ទីរ ស-២១ គឺលោកបានរៀបរាប់អំពីការវិវឌ្ឍន៍នៃការកម្ទេចខ្មាំង គឺចាប់ផ្តើមពីការកម្ទេចមន្ត្រីរាជការ ទាហាន លន់ នល់ រហូតដល់ការកម្ទេចនៃសមាជិកបក្សជននៅក្នុងបក្សកុម្មុយនីស្តកម្ពុជាទាំងមូល ។ តើលោកអាចពន្យល់ដោយសង្ខេបបានទេថា មូលហេតុចម្បងនៃការវិវឌ្ឍន៍នៃការកម្ទេចបែបនេះ ជាផែនការជាក់លាក់របស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏ជាការអនុវត្តដោយការសង្ស័យ ឬក៏ការបន្តភ័យខ្លាចនៃការផ្តួលរំលំអំណាចរបស់មេដឹកនាំបក្សកុម្មុយនីស្តកម្ពុជានោះ?

**ឆ៖** យើងបាន លោកដូចបានចូលទៅដល់បញ្ហាចំណុចសំខាន់ ប៉ុន្តែខ្ញុំលើកពីចំណុចសំខាន់ដែលទាក់ទងប្រវត្តិសាស្ត្រនៃកម្ពុជា ហើយនៅក្នុងសវនាការនេះបានពិនិត្យលើបញ្ហានេះ ។ អ្វីដែលកើតឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ថាតើគេចាត់ទុកថាជាប្រល័យពូជសាសន៍នោះ គឺតាមអនុសញ្ញារបស់អង្គការសហប្រជាជាតិ គឺគេកំណត់ធាតុផ្សំនោះ វាជាក់លាក់នៅក្នុងនុ៎ង គឺវាមាន ហើយលោកបានសួរអំពីចេតនា យើងត្រូវរកភស្តុតាង ឬក៏តឹកតាងដែលថាមេដឹកនាំ ឬក៏របបនោះមានចេតនាជាក់លាក់ដើម្បីកម្ទេចជាពិសេសក្រុមជាតិពន្ធុណាមួយ ពិសេសក្រៅពីប្រជាជនខ្លួនឯងនោះ ។

អ៊ីចឹងយើងនិយាយ-- ខ្ញុំបាននិយាយក្នុងចម្លើយពីមុននោះ ខ្ញុំបានបញ្ជាក់អំពីទំនុកចិត្តដែលគេទុកចិត្តឲ្យមនុស្សមួយក្រុម ហើយការគាំទ្រទៅដល់ក្រុមនោះដើម្បីឲ្យគេប្រព្រឹត្តទៅតាមគំនិតមួយដែលគេគិតថា គេប្រព្រឹត្តទៅតាមបែបផែនបដិវត្តន៍គេនោះ ។ គឺបើយើងប្រៀបធៀបទៅនឹងបដិវត្តន៍វប្បធម៌បារាំងនោះ គេហៅថា ឆ្វេងនិយម មិនត្រូវបានទណ្ឌកម្ម ប៉ុន្តែបើសិនទៅជ្រុលហួសពេក គេថាអាចនឹងជាការមិនត្រឹមត្រូវ ។ គំនិតនៃការកម្ទេចខ្មាំងមិនមែនតែការសម្លាប់ដែលកើតឡើងក្នុងឆ្នាំ១៩៧៥ នៅអតីតទាហានសាធារណរដ្ឋដែលត្រូវបានទម្លាក់អាវុធ ហើយនិងត្រូវបានគេសម្លាប់ ។

[១៣:៥៧:១៣]

ខ្ញុំនឹងជម្រាបលោកអំពីការកម្ទេចខ្មាំងផ្ទៃក្នុង ក្នុងបក្ស ឬក៏ក្នុងជួរបក្សនោះ ភាសានោះ គឺថាមិនច្បាស់លាស់សោះមកពីថ្នាក់លើនោះដែលគេ-- ដូចដែលខ្ញុំបញ្ជាក់ខាងដើមអ៊ីចឹង គឺថាឯកសារមួយចំនួននោះគឺមិនបញ្ជាក់ឲ្យបានច្បាស់ ។ ប៉ុន្តែ តាមពិតយើងមិនដែល-- ខ្ញុំមិនបានដឹងថាវាមានមេដឹកនាំដែលប្រកាសថាមាន ថាខ្លួនបានសម្លាប់ខ្មាំងច្រើនហើយនោះទេ គឺថាមិនដែលបញ្ជាក់ថាបានសម្លាប់គ្រប់លើសលុបហើយនោះទេ ។ អ៊ីចឹងហើយមានការលំបាកក្នុងការកំណត់អំពីចេតនាក្នុងចំណុចនេះ ។

**លោក គីម ម៉េងឃី៖**

សូមអរគុណ លោកសាស្ត្រាចារ្យ សូមថ្លែងអំណរគុណ ហើយខ្ញុំមិនមានសំណួរអ្វីទៀតទេ ។ ដោយសារតែពេលវេលាមានកំណត់ ដូច្នេះ ខ្ញុំសូមឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតតាំងសំណួរទៅលោក ។ សូមអរគុណ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី៖**

**ស៖** សូមអរគុណ ជម្រាបសួរលោក ដេវីដ ឆេនដ៍ល័រ ។ ខ្ញុំមេធាវី ស្ទួត ហ្សីនស្គី ។ ខ្ញុំមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំនឹងសួរសំណួរទៅលោកពីលក្ខណៈទូទៅ ដូចតទៅនេះ ។ តើតាមការ

ស្រាវជ្រាវរបស់លោក តើលោកអាចប្រាប់យើងបានទេ តើរយៈពេលអ្នកទោសដែលគេឃុំនៅទួលស្លែងហ្នឹងរយៈពេលប៉ុន្មានដែរ? តើរយៈពេលហ្នឹងវាមានក្របខ័ណ្ឌដូចម្ដេចដែរ ផ្អែកតាមការសិក្សារបស់លោក?

**ឆ៖** ខ្ញុំមិនច្បាស់ប្រាកដទេ អំពីកម្រិតពេលនោះទេ ប៉ុន្តែ ចំពោះអ្នកទោសសំខាន់ហ្នឹងគឺថាអាចច្រើនខែ ពីរបីខែ ប៉ុន្តែខ្លីជាងគេបំផុតនោះ គឺចំពោះមនុស្សដែលដឹកនាំមកតាមឡានធំៗ ហើយមកក្នុងគុករយៈពេលខ្លី ហើយក៏មួយរយៈពេលខ្លីក៏បានដឹកចេញទៅវិញតាមរថយន្តធំនោះដែរ ។ អ៊ីចឹងហើយអ្នកដែលដឹកតាមរថយន្តធំនោះ គឺមិនមែនជាអ្នកទោសសំខាន់ទេ ។ អ៊ីចឹងគឺថា វាអាចច្រើនខែ បីបួនខែប៉ុន្តែក្នុងសៀវភៅខ្ញុំមានបញ្ជាក់ ។ ខ្ញុំនឹងព្យាយាមនឹកឃើញថា តើរយៈពេលពីពេលដែលអ្នកទោសចូលរហូតដល់ពេលចេញ ឬក៏ពេលដែលចប់នោះសួរចម្លើយនោះ ។ គឺថាកាលណាសួរចម្លើយចប់ហើយជិតដល់ពេលពិឃាដហើយ ។ អ៊ីចឹងបើសិនជានិយាយពេលដែលខ្ញុំចាំនោះ គឺពីរ ឬក៏បីសប្ដាហ៍ ។

**ស៖** ជនជាប់ចោទបានប្រាប់យើងថា លោក ភឹង តុន ជាជនរងគ្រោះម្នាក់ត្រូវដាក់ឃុំនៅកន្លែងនោះម្ភៃខែ ។ តើលោកអាចបញ្ជាក់អ្វីបាន ទាក់ទងទៅនឹងចំណុចនេះផ្អែកលើការសិក្សាស្រាវជ្រាវរបស់លោក? បើសិនជាអ្នកទោសណាមិនត្រូវសួរចម្លើយជាលម្អិត ឬក៏លម្អិតនៅទួលស្លែងនោះ ។

**ឆ៖** សូមអត់ទោស។ ខ្ញុំមិនអាចផ្ដល់ចម្លើយពីព្រោះព័ត៌មានជាក់លាក់បែបនេះខ្ញុំអាចនឹងឃើញច្បាស់បានភ្លាមទេ ។ ខ្ញុំបានវត្តមាននៅអង្គជំនុំជម្រះនេះ គឺដើម្បីថាតើចម្លើយផ្សេងទៀតរបស់ជនជាប់ចោទវាឆ្លើយឆ្លងគ្នានឹងខ្ញុំដែរអត់ទេ? ប៉ុន្តែ វាជារឿងចំឡែកណាស់ប្រសិនជាអ្នកទោសត្រូវបានគេឃុំក្នុងរយៈពេលវែងបែបនោះ ថាតើអ្វីជាមូលហេតុដែលត្រូវដាក់គុកវែង? ហើយតើមានព័ត៌មានអ្វី ឬភស្តុតាងអ្វីដែលថា មានរយៈពេលវែងដូច្នេះ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមចូលទៅដល់អំពីចម្លើយសារភាពដែលធ្វើឡើងដោយអ្នកសួរចម្លើយដែលលោកបានអាន ហើយបានវិភាគ ។ ហើយខ្ញុំសូមទាញការចាប់អារម្មណ៍លោកទៅលើចម្លើយសារ-ភាពទៅដល់លោក ប៊ុត ហេង, លោក សំ ម៉ាត់ ហើយនិងលោក ជុំ ម៉ី ហើយនិងលោក សុខ វ៉ា ។ ហើយចម្លើយសារភាពនេះស្ថិតនៅក្នុង-- លោកបានប្រើជាបង្អែកនៅក្នុងសៀវភៅ ជាពិសេសនៅទំព័រ ១៣១ សំណួររបស់ខ្ញុំ គឺថាអ្នកសួរចម្លើយទាំងអស់នេះដែលបាននិយាយអំពីការបំពារបំពានផ្លូវភេទដែលគេបានប្រព្រឹត្ត ហើយដែលគេបានទទួលសារភាពក្នុងចម្លើយសារភាពរបស់គេ ។ តើលោកបានអាន ឬក៏យល់ដូចម្ដេចចំពោះខ្លឹមសារនេះ?

[១៤:០៣:២៥]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំជំទាស់ចំពោះសំណួរនេះ ។ ខ្ញុំពិនិត្យឃើញថា អង្គជំនុំជម្រះបាន បានបញ្ជាក់ទៅនឹងអនុសញ្ញាប្រឆាំងនឹងអំពើទារុណកម្មដែលកម្ពុជាជាហត្ថលេខីដែលមិនអនុញ្ញាតឲ្យ ប្រើសេចក្តីសារភាពដែលទទួលបានពីអំពើទារុណកម្ម ។ ហើយអ៊ីចឹងហើយ សូមឲ្យសាក្សីប្រើសិទ្ធិរបស់ គាត់ក្នុងការឆ្លើយសំណួរនេះ ។

**លោកស្រី ស៊ីលឃីស្វូត ហ្សីនស្គី៖**

តាមពិតខ្ញុំចាំថា មានអនុញ្ញាណអំពីទារុណកម្មនោះនៅក្នុងគំនិតរបស់ខ្ញុំហើយ ។

**ប្រធានអង្គជំនុំ៖**

ជំទាស់ជាការត្រឹមត្រូវ ហើយលោកមេធាវីមានការរៀបចំនៅសំណួរឲ្យបានត្រឹមត្រូវចៀសវាង មានកំហុសនៅក្នុងការបង្កើតសំណួរដែលផ្អែកលើចម្លើយសារភាព ដែលបានមកពីទារុណកម្មនោះ ។ យើងបានសម្រេចជាក់លាក់ហើយបញ្ហានេះ ។

**សួរដោយលោកស្រី ស៊ីលឃី ស្វូតហ្សីនស្គី៖**

ប៉ុន្តែទោះបីយ៉ាងណាក៏ដោយ ខ្ញុំសូមនិយាយថា តាំងពីចាប់ផ្តើមសវនាការរបស់យើងភាគីគ្រប់ ទាំងអស់រួមទាំងអង្គជំនុំជម្រះបានយោងទៅលើចម្លើយសារភាព ។ ប៉ុន្តែ ខ្ញុំព្យាយាមរៀបចំសំណួរឡើង វិញដែលបានសួរទៅកាន់លោក ដេវីដ ឆេនដ៍ល័រ ។

**ស៖** លោកបានលើកឡើងអំពីចម្លើយសារភាព ដែលខ្ញុំបានរៀបរាប់ដាក់ឈ្មោះអ្នកសួរចម្លើយ មួយចំនួន ។ ដូច្នេះ ខ្ញុំចង់ដឹងថា តើលោកយល់ឃើញថាចម្លើយសារភាពនេះ ឬក៏រកឃើញថាចម្លើយ សារភាពនោះបានទទួលស្គាល់ថា មានការលោភ ការបៀតបៀនកេរ្តិ៍ខ្មាស់អីផ្សេងៗទៅលើចំណុចហ្នឹង ដែរឬទេ?

[១៤:០៥:៣៩]

**ឆ៖** តាមអ្វីដែលខ្ញុំចាំ គឺយើងអត់មានចំណារទាំងអស់នេះ ។ ហើយចំពោះសំណួរទាក់ទងទៅ នឹងអ្នកសួរចម្លើយនៅស-២១ គឺវាជាប្រភេទមួយៗចំពោះអ្នកទាំងអស់នោះ គឺជាបុគ្គលទាំងឡាយជាអ្នក សួរចម្លើយនោះ គាត់សួរ ហើយអ្នកទាំងអស់នោះ ប្រហែលជាបានដឹងអំពីអំពើទាំងឡាយដែលអ្នកទាំង នោះបានធ្វើឡើង ។ វាមិនមែនថា អ្នកដែលមកពីម៉ាល ពីឆ្ងាយមកថាគាត់ជា *ស៊ីអាយអេ* ឬ *ខេជីប៊ី*

(KGB) ហើយទារុណកម្មនោះបានប្រព្រឹត្តចំពោះគាត់នោះទេ ។ អ៊ីចឹងសហសេវិក ឬក៏បុគ្គលិកនោះ គឺបានធ្វើអ្វីដែលបានធ្វើ ។

ដូច្នេះ ចម្លើយសារភាពនោះ គឺជាចំណុចមួយខ្ញុំបង្ហាញច្បាស់លាស់ចំពោះអ្វីដែលខ្ញុំបានចាំ ។ ជាការពិត យើងមានភស្តុតាងពី គក ស្រស់ ដែលគាត់លើកឡើងថា វាមានការបៀតបៀនកេរ្តិ៍ខ្មាស់ផ្សេងៗនៅក្នុងមន្ទីរសន្តិសុខ ។ ដូច្នេះ ចំណុចទាំងអស់នេះ គឺជាការលើកឡើងនៅក្នុងចម្លើយសារភាពផងដែរ ។ ហើយវាមិនត្រឹមតែអ្នកទាំងនោះទទួលការរងទារុណកម្មដោយបញ្ជូនទៅព្រៃស ធ្វើការអប់រំវិញឡើងវិញនោះទេ អ្នកទាំងអស់ក៏ទទួលការស្លាប់ផងដែរ ។ ហើយខ្ញុំយល់ស្របជាក់ស្ដែងតែម្ដងមេធាវី ការពារក្ដីថា ខ្ញុំយល់ឃើញថា ចម្លើយសារភាពទាំងអស់នោះ គឺមិនចាំបាច់ប្រើទារុណកម្មដើម្បីទាញយកទារុណកម្មនោះទេ ។

[១៤:០៧:២៥]

ហើយដោយសារតែគេដឹងហើយថា មានអ្វីកើតឡើង ហើយគេប្រាប់គ្នាទៅវិញទៅមកថា មានអំពើនឹងមានព្រឹត្តិការណ៍អ្វីកើតឡើងខ្លះ ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំបន្ទាប់ គឺខ្ញុំនិយាយអំពីចម្លើយរបស់ជនជាប់ចោទដែលគាត់បានប្រាប់ថា អតីតសាស្ត្រាចារ្យរបស់គាត់ត្រូវបានគេរំលោភ ហើយមានការបៀតបៀនទៅលើផ្លូវភេទរបស់គាត់ ។ ហើយជនជាប់ចោទគាត់បានដឹងនៅពេលនោះ ថាមានការរំលោភកើតឡើងមែន ប៉ុន្តែគាត់មិនបានដាក់ទារុណកម្មទៅលើអ្នកដែលបានប្រព្រឹត្តអំពើបៀតបៀន ឬរំលោភទាំងនេះ បន្ទាប់ពីគាត់បានប្រឹក្សាជាមួយ សុន សេន ។ នេះជាអ្វីដែលជនជាប់ចោទបានប្រាប់យើងខ្ញុំ ។ តាមការចេះដឹងរបស់អ្នកជំនាញ ថាតើការអនុវត្តបែបនេះ វាស៊ីគ្នាទៅនឹងការយល់ឃើញទូទៅដែរឬទេ ថាការរំលោភផ្លូវភេទផ្សេងៗនោះត្រូវតែដាក់ទារុណកម្មឲ្យបានធ្ងន់ធ្ងរ?

**ឆ៖** ខ្ញុំបានអានទៅលើចម្លើយរបស់ជនជាប់ចោទហើយ វាហាក់ដូចជាបង្ហាញជូនខ្ញុំថា អ្នកធ្វើការនៅស-២១ នោះ ហើយគាត់មិនបានត្រឹមតែប្រព្រឹត្តទេ គឺអ្នកទាំងអស់នោះពេលខ្លះអាចប្រព្រឹត្ត ហើយគេបានធ្វើបាប ។ ហើយអ្នកដែលនៅខាងលើ ឬក៏អ្នកផ្សេងអាចដឹង ដូច្នេះហើយទើបជនជាប់ចោទគាត់បានទៅពិភាក្សាជាមួយនឹង សុន សេន ។ ចំណុចនេះ វាជាការប្រព្រឹត្តអំពើនេះ ហើយជា-- ខ្ញុំអាចធ្វើការលើកឡើងអំពីចម្លើយសារភាពមួយចំនួនទៀតដែលចំពោះខ្ញុំ គឺវាឃើញាមានករណីមួយចំនួនដែលអ្នកទាំងឡាយគាត់ធ្វើការសារភាពថា បានប្រព្រឹត្តអំពើមួយចំនួន គឺធ្វើការបៀតបៀនទៅលើ

អតីតប្រពន្ធសាស្ត្រាចារ្យ ។ ដូច្នេះហើយ យើងឃើញមានចម្លើយដែលបានបង្ហាញទៅលើចំណុចទាំងអស់នោះ ។

**ស៖** ខ្ញុំចង់សូមសួរសំណួរចុងក្រោយជូនលោក ។ តើលោកសន្និដ្ឋានយ៉ាងម៉េចអំពីគ្រោះថ្នាក់ចំពោះស្ត្រីដែលបានជាប់ឃុំនៅទួលស្លែង? ដែលថាគ្រោះថ្នាក់របស់គាត់នោះ គាត់ក្លាយជាជនរងគ្រោះខាងការបំពារបំពានផ្លូវភេទអីផ្សេងៗ ថាតើលោកសន្និដ្ឋានយ៉ាងម៉េច? បានន័យថា គឺក្រុមស្ត្រីនោះ គឺជាក្រុមដែលងាយរងគ្រោះឬក៏យ៉ាងម៉េច?

[១៤:១០:៤៧]

**ឆ៖** ខ្ញុំគិតថា ខ្ញុំមិនអាចរៀបរាប់ថា ក្រុមណាងាយរងគ្រោះនោះទេ ។ ហើយវាកើតឡើងយ៉ាងម៉េចនោះទេ ។ អ្វីដែលខ្ញុំយល់អំពីកន្លែងមន្ទីរសន្តិសុខនោះ គឺថា វាមិនមែនកន្លែងចំហ បើកចំហឲ្យយើងដឹងនោះទេ ។ ហើយវាមិនបើកឲ្យមានការរំលោភបែបនោះចំពោះក្រុមណាមួយនោះទេ ។ ហើយយើងមិនមានភស្តុតាងបង្ហាញទៅលើចំណុចនេះទេ ។ ម្យ៉ាងវិញទៀត ខ្ញុំយល់ឃើញថាស្ថានភាពនៅក្នុងមន្ទីរឃុំឃាំងនោះ គឺវាមានហាក់ដូចជាត្រពឹកត្រពាស បានន័យថា ខ្ញុំមិនមែនចោទប្រកាន់ទៅលើបុគ្គលណាមួយនោះទេ ។ វាជាកន្លែងមួយដែលបិទជិត ដែលមានសុទ្ធតែបុរសក្មេង ហើយមនុស្សក្មេងៗ ។ ហើយនៅពេលខ្លះទៅអាចប្រព្រឹត្តអំពើមិនគប្បី គឺទាក់ទងទៅនឹងបញ្ហាផ្លូវភេទ ប៉ុន្តែខ្ញុំមិនហាក់ដូចជាមិនយល់ឃើញថា បទល្មើសឬក៏កំហុសទាំងអស់នោះ យើងសន្និដ្ឋានជាទូទៅថា ជាកន្លែងមួយដែលវាធ្វើដើម្បីគោលបំណងនោះទេ ។ ហើយគឺថា ប្រហែលជាថា ប្រសិនជាជនជាប់ចោទ ឬក៏អ្នកណាដឹងនោះគាត់ត្រូវតែធ្វើការបញ្ឈប់ទៅលើបញ្ហាទាំងអស់នោះ ។ ដូច្នេះខ្ញុំមិនអាចជម្រាបថា ក្រុមណាជាក្រុមងាយរងគ្រោះ ក្រុមស្ត្រី ឬក៏ក្រុមណានោះទេ ។ ប៉ុន្តែ ខ្ញុំសង្ស័យថា ស្ត្រីដែលគាត់មានទំនាក់ទំនងរបស់កម្មាភិបាលជាន់ខ្ពស់នោះ ប្រហែលជាគាត់មិនងាយរងគ្រោះនោះទេ ។

**ស៖** សូមអរគុណច្រើន ។ ខ្ញុំសូមបន្ថែមនិងចង់សួរចុងក្រោយ ។ ខ្ញុំឃើញនៅក្នុងសៀវភៅរបស់លោកទំព័រ៣៨ ដែលលោកបាននិយាយអំពីវៀតណាម ។ អ្នកទោសវៀតណាម ដែលគាត់ងាយរងគ្រោះ?

**ឆ៖** ខ្ញុំសូមដកចេញអ្វីដែលខ្ញុំបានលើកឡើង គឺអ៊ីចឹងមែន វៀតណាមក៏អាចជាអ្នកដែលទទួលងាយរងគ្រោះ ហើយប្រសិនបើគេពិចារណាទៅលើអង្គហេតុផ្សេងៗ និងស្ថានភាពផ្សេងៗទាក់ទងទៅនឹងបញ្ហាវៀតណាម និងសង្គ្រាមវៀតណាម ។ ដូច្នេះហើយ ប្រហែលជាលោកស្រីអាចកំណត់បាន

ហើយចង់បានថា ក្រុមណាដែលងាយរងគ្រោះនោះ គឺប្រហែលជាក្រុមនោះហើយ ។

**លោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្តី៖**

សូមអរគុណច្រើន ។ ខ្ញុំអស់ពេលវេលាហើយ ដូច្នេះខ្ញុំសូមផ្តល់វេទិកានេះ បញ្ជូនបន្តទៅឲ្យសហសេវីករបស់ខ្ញុំ ។

សូមអរគុណលោកច្រើន ។

[១៤:១៣:៣៣]

**សួរដោយលោក អាឡាំង វ៉ែនណឺ៖**

សូមសួស្តីលោក ។ ខ្ញុំជា អាឡាំង វ៉ែនណឺ តំណាងក្រុមទីមួយ ។ ខ្ញុំឈ្មោះ អាឡាំង វ៉ែនណឺ ហើយខ្ញុំមានសហសេវីករបស់ខ្ញុំឈ្មោះ ទ្រី ស្រ៊ីនណា ។ ខ្ញុំមានប្រហែលជាដប់ជាងនាទី ហើយខ្ញុំនឹងសួរសំណួរលោកមួយចំនួន ហើយខ្ញុំសូមថ្លែងអំណរគុណប្រសិនបើលោកអាចឆ្លើយបតនឹងសំណួរដោយខ្លីៗចំពោះអ្វីដែលខ្ញុំបានសួរនោះ ។

**ស៖** ខ្ញុំសូមចាប់ផ្តើមនៅលើត្រង់ចំណុចមួយ ចៅក្រម ខាតវ៉ាយធ៍ បានសួរលោកនៅព្រឹកមិញនេះអំពីផែនការរួមចុងក្រោយ ហើយគាត់បានសួរថា ហេតុអ្វីបានជាលោកនិយាយថា ឌុច ជាអ្នកសរសេរផែនការរួមចុងក្រោយនោះ? នៅក្នុងទំព័រទី២២ នៅក្នុងសៀវភៅរបស់លោកផែនការរួម គឺខ្ញុំហាក់ដូចជាមិនចេះអានភាសាអង់គ្លេសនូវពាក្យនុ៎ងជាស្រមោល បានន័យថា តើហេតុអីបានជាលោកនិយាយដូច្នោះ?

[១៤:១៤:៣៨]

**ឆ៖** ចំពោះខ្ញុំ វាជាចំណុចមួយដែល ពាក្យយើងប្រើពង្រីកចំពោះ ឌុច ដែលទាក់ទងទៅនឹងចម្លើយសារភាព ហើយគាត់បានព្យាយាមសន្និដ្ឋានរួមគ្នានូវអ្វីដែលគាត់បានឃើញ និងបានបកស្រាយថាចម្លើយទាំងអស់នោះជាភស្តុតាង ។ ដូច្នេះ ចំណុចនេះវាហាក់ដូចជាការទាញរូបមន្តចេញពីគណិតវិទ្យាអ៊ីចឹង នៅលើក្តារខៀន ចំពោះគាត់ ។ ដូច្នេះ ខ្ញុំមិនអាចនិយាយជំនួសគាត់នោះទេ ។ ប៉ុន្តែ អាចធ្វើតាមរបៀបនេះ ។ ហើយចំណុចទាំងឡាយ គឺវាអាចធ្វើការទៅលើការងារទាំងអស់នេះ ។ ដូច្នេះវាជាចំណុចមួយជាក់ស្តែង ហើយជាការបកស្រាយចេញពីព័ត៌មានទាំងឡាយដែលគាត់បានទទួលប្រចាំថ្ងៃ ។

**ស៖** សូមអរគុណ ព្រឹកមិញលោកនិយាយអំពីបញ្ជីថា អ្នកទោសត្រូវបានស្នើសុំឲ្យផ្តល់នៅក្នុងសៀវភៅរបស់លោកទំព័រ៣៨ លោកនិយាយអំពីចំណុចមួយផ្សេងទៅវិញ ។ លោកនិយាយអំពីសេចក្តីសង្ខេបដែលបានធ្វើឡើងដោយបុគ្គលិកខ្លួនឯងនៅក្នុងទំព័រ១០៥ ។ ខ្ញុំសូមអាននូវអ្វីដែលលោកបាន

និយាយ “ឈ្មោះនៅក្នុងខ្សែបដិវត្តន៍គេប្រើជាការចាប់ខ្លួនបន្ថែម ហើយលោកបាននិយាយថា គឺយើងឃើញមានការរៀបចំ ឲ្យមានសេចក្ដីសង្ខេបទៅលើឈ្មោះដែលបុគ្គលជាប់ពាក់ព័ន្ធទៅនឹងអង្គភាព តំបន់ រោងចក្រ ឬក៏កន្លែង ផ្សេងៗ” តើលោកនៅតែប្រកាន់ជំហរដូច្នេះដែរឬទេ?

**ឆ៖** ខ្ញុំត្រូវតែប្រកាន់ជំហរនូវអ្វីដែលខ្ញុំបានលើកឡើង ។

**ស៖** ខ្ញុំសូមសួរបន្ត ។ ពិចារណាទៅលើអ្វីដែលលោកបានឆ្លើយព្រឹកមិញ ទាក់ទងទៅនឹងបញ្ជីឈ្មោះខ្មាំង និងខ្សែក្បត់ អ្នកទោសនោះត្រូវតែផ្ដល់ឈ្មោះទាំងអស់នោះ ហើយយើងឃើញថា បុគ្គលិកនោះបានបង្កើតរៀបចំឯកសារទាំងអស់នោះ ។ មុននោះគឺលោក អេតធេសាន់ គាត់បានសក្ខីកម្មនៅក្នុងខែឧសភា ហើយខ្ញុំបានសួរគាត់ ហើយគាត់ក៏បាននិយាយអំពីបញ្ជីអ្នកទោស និងឈ្មោះផ្សេងៗ ហើយនិងការងារដែលបុគ្គលិកបានធ្វើឡើង ។ ហើយខ្ញុំបានសួរគាត់ លោក អេតធេសាន់ថា យោងតាមលោក អេតធេសាន់ នោះថាតើនរណាគេជាអ្នកបញ្ជាស-២១ ឲ្យបង្កើតបញ្ជី និងធ្វើការងារដូច្នោះ ។ ហើយគាត់បាននិយាយថា នៅក្នុងទំព័រ១៨ ជាជំហររបស់លោក អេតធេសាន់ នៅថ្ងៃទី២៨ ឧសភា ឆ្នាំ២០០៩ គាត់បាននិយាយថា ខ្ញុំមិនអាចចងចាំទេ ថាបានឃើញបញ្ជាដែលឲ្យធ្វើការបង្កើតបញ្ជីបែបនោះ នោះទេ ។ ហើយគេបានបញ្ជាផ្ទាល់ទៅដល់អ្នកបុគ្គលិកនោះទេ ប៉ុន្តែការយល់របស់ខ្ញុំគឺជាការអនុវត្តដែលធ្វើឡើង ហើយរៀបចំដោយជនជាប់ចោទខ្លួនឯង ។ ហើយជនជាប់ចោទនោះ-- មេរបស់ជនជាប់ចោទនោះគាត់យល់ឃើញថា ការអនុវត្តដូច្នោះវាមានផលប្រយោជន៍ ហើយវាមានហេតុផលដែលទើបឲ្យគាត់ទទួលបានការដំឡើងថ្នាក់ជាប្រធានស-២១ ។ តើលោកជាអ្នកជំនាញយល់ស្របជាមួយជំហររបស់លោក អេតធេសាន់ ដែរទេ?

[១៤:១៨:១០]

**ឆ៖** វាហាក់ដូចជាសមហេតុផលទៅលើការលើកឡើងដូច្នោះ ប៉ុន្តែ ខ្ញុំមិនមានឯកសារបង្ហាញតម្កល់ទៅលើចំណុចនោះទេ ។ ប៉ុន្តែ ប្រសិនបើយើងមើលទៅយើងអាចយល់ស្របទៅតាមហ្នឹង ។

**ស៖** លោកបានលើកឡើងនៅក្នុងសៀវភៅរបស់លោកទំព័រ៣៨ ទាក់ទងនឹងលក្ខខណ្ឌនៃការឃុំខ្លួននេះជាអ្វីដែលលោកបាននិយាយនៅក្នុងទំព័រ៣៨ ភាពឯកោ កង្វះអាហារ និងភាពស្ងប់ស្ងាត់ គឺជាលក្ខណៈសំខាន់ក្នុងការបំបាក់អ្នកទោស ដើម្បីសួរចម្លើយដូចដែលលោក ហ្វូលខ បាននិយាយថា “ភាពឯកោ គឺជាលក្ខណៈចម្បងសម្រាប់អ្នកទោសសារភាព” ។ សាក្សីនៅក្នុងតុលាការនេះក៏បាននិយាយអំពីអនាម័យ ហើយអ្នកទោសត្រូវបានដាក់ខ្នោះនៅក្នុងបន្ទប់ឃុំឃាំង ហើយមិនមានលទ្ធភាពទៅបត់ជែបត់

ជើង ហើយត្រូវបានគេវាយ តើលោកយល់ស្របទេ ដែលថាលក្ខណៈទាំងអស់នោះ គឺមានការរៀបចំដើម្បីឲ្យធ្វើការអនុវត្ត រៀបចំការសួរចម្លើយ ទាញយកចម្លើយនៅពេលចុងក្រោយនោះដែរឬទេ? តើលោកយល់ស្របទៅនឹងចំណុចនេះដែរឬទេ?

**ឆ៖** គឺខ្ញុំយល់ស្របទៅចំណុចដែលបានលើកឡើងដូច្នោះ ។

**ស៖** ខ្ញុំសូមអរគុណដែលលោកបានឆ្លើយមិនចាំបាច់ឲ្យខ្ញុំសួរឡើងវិញ ។ តើលោកយល់ស្របដែរឬទេ? ថាតើលក្ខខណ្ឌមិនសមរម្យទាំងអស់នោះដែលថាធ្វើឲ្យអ្នកទោសនោះគាត់បាត់បង់នូវអារម្មណ៍គ្រប់គ្រងរបស់គាត់ ហើយទាញយកចម្លើយសារភាពពីគេដោយប្រើប្រាស់លក្ខខណ្ឌទាំងអស់នោះ តើលោកយល់ស្របទៅលើចំណុចនេះដែរឬទេ?

**ឆ៖** គឺបានន័យថា វាចាប់ផ្តើមតាំងពីពេលដែលឡានមកដល់ ។ បានន័យថា អ្នកទាំងអស់នោះដែលដឹកតាមឡាន គឺជាសំរាមទាំងអស់ អ្នកនោះមិនមែនជាមនុស្សទេ ។ ហើយវត្ថុបំណងនោះគឺដើម្បីធ្វើយ៉ាងណាទុកឲ្យពួកគេនៅក្នុងស្ថានភាពអាក្រក់ ហើយធ្វើឲ្យពួកគេបាក់ស្មារតី ។ ហើយអ៊ីចឹងមែនគឺថាពួកគេត្រូវបានដឹកតាមឡាន ហើយយកមកដាក់ក្នុងស្ថានភាពហ្នឹង ។ ហើយបន្ទាប់មកត្រូវបានគេយកទៅសម្លាប់ចោល ។

**ស៖** សូមអរគុណលោក ។ នៅក្នុងទំព័រ៨៥ ប៉ុន្តែ ខ្ញុំក៏ចង់ដឹងដែរថាតើហេតុអ្វីបានជាលោកនិយាយដូច្នេះ ។ លោកនិយាយថាអ្នកទោសធំៗនៅក្នុងពេលឆ្លើយនោះ គឺគេផ្តល់ចម្លើយសារភាពឲ្យអាន ។ លោកបាននិយាយហ្នឹងប្រហែលជាអ្នកទាំងអស់នោះ កម្មាភិបាលជាន់ខ្ពស់ជាអ្នកទោសនោះ គឺគេផ្តល់ចម្លើយសារភាពឲ្យពួកគាត់អាន ប៉ុន្តែ អត់មានចំណុចយោងនៅក្នុងឯកសាររបស់លោក។ ហើយតើលោកចាំទេ ហេតុអីបានជាលោកនិយាយដូច្នោះហើយមិនមានដាក់លេខយោងហ្នឹង?

[១៤:២១:២៤]

**ឆ៖** ខ្ញុំគួរតែបានសរសេរបន្ថែមសម្គាល់លេខជើងទំព័រ ប៉ុន្តែយ៉ាងណាក៏ដោយគឺថាវានៅតែពិតទេ ចម្លើយទាំងអស់ហ្នឹងគ្រាន់តែអត់ *ហ្វូតណូត* លេខជើងទំព័រ ។

**ស៖** នៅក្នុងទំព័រ៨៨ លោកនិយាយអំពីចម្លើយសារភាព ។ លោកនិយាយថា មានប្រាំបីច្បាប់ ហើយលោកបានពន្យល់ពិស្តារថាតើឯកសារណាខ្លះដែលបានចែកជូនតាម-- ហើយចែកតាមរបៀបណា? ហើយថាតើនរណាគេជាអ្នករៀបចំផែនការបង្កើតឲ្យមានឯកសារថតចម្លងច្រើនច្បាប់អ៊ីចឹង? ថាតើមកពីខាងណា? ហើយអ្នកណាគេជាអ្នកសម្រេចឲ្យធ្វើការរក្សាមានឯកសារហ្នឹងច្រើនច្បាប់អ៊ីចឹង?

**ឆ៖** ខ្ញុំហាក់ដូចជា ប្រហែលជាអាចកើតចេញពីជនជាប់ចោទ ទៅលើការរៀបចំការងារទាំងអស់នោះ ឬក៏វាកើតចេញពីមន្ទីរ និងស្ថាប័នផ្សេងៗ ។

**ស៖** ទំព័រសៀវភៅទំព័រ១២២ គាត់-- ឌុច ពុំមានត្រាប្រណីទេចំពោះអ្នកទោសដែលចចេសមិនព្រមសម្របខ្លួន មុនពេលមួយខ្លួនបានទៅសួរអ្នកចម្លើយថា វ៉ៃអ្នកទោសរហូតទាល់តែឆ្លើយអស់ឲ្យវានិយាយកាន់តែស៊ីជម្រៅ ហើយមានលេខជើងទំព័រនៅក្នុងហ្នឹង ។ តើលោកយល់ស្របទៅលើអ្វីដែលលោកបានលើកឡើងនៅក្នុងទំព័ររបស់លោក ១៣២ ដែរឬទេ?

**ឆ៖** ខ្ញុំយល់ស្របទៅលើចំណុចហ្នឹង ។ គ្មាននរណានៅក្នុងមន្ទីរនោះអាចមានអំណាចធំទេ ហើយភាពគ្មានត្រាប្រណីនោះប្រហែលជាមិនធ្ងន់ធ្ងរដូចស្ថានភាពផ្សេងទៀតនោះទេ ។ ហើយចំពោះខ្ញុំនោះ គឺថាបុគ្គលដែលគាត់ពុំមានត្រាប្រណីនោះគឺវាជាលក្ខណៈមួយសាហាវណាស់ ។

**ស៖** ហ៊ីម ហ៊ុយ បានមកទីនេះផ្តល់ចម្លើយសារភាពនៅថ្ងៃទី២០ ខែកក្កដា ខ្ញុំបានសួរគាត់ចម្លើយរបស់គាត់ គាត់បានលើកឡើងនៅក្នុងប្រតិចារឹកថា "នៅស-២១ ខ្ញុំឮឌុច ហើយនិង ហ៊ី បាននិយាយថាសម្លាប់ទាំងអស់ ហើយទុកតែប្អូនលាន" ហើយខ្ញុំបានសួរគាត់អំពីចំណុចនេះនៅក្នុងតុលាការគាត់បានឆ្លើយថា "ដូចដែលខ្ញុំបាននិយាយហើយនៅពេលដែលវគ្គអប់រំនោះ ហើយ ឌុច បាននិយាយដោយផ្ទាល់ថា សម្លាប់បុគ្គលទាំងអស់មិនត្រឹមតែបុគ្គលដែលជាប់នៅស-២១ ទេ" ខ្ញុំជឿដូច្នោះ ។ ដោយសារតែគាត់និយាយថា ត្រូវតែសម្លាប់ទាំងអស់ ។ មានមន្ទីរសន្តិសុខនៅគ្រប់កន្លែងទាំងអស់នៅក្នុងប្រទេសហើយខ្ញុំយល់ថា ត្រូវតែសម្លាប់ចោល ។ ហើយលោក ហុង គឹមសួន បានសួរបន្តទៅលើចំណុចហ្នឹង ។ ឌុច បាននិយាយថា បុគ្គលទាំងអស់ត្រូវតែសម្លាប់ទុកតែប្អូនលាន ហើយបន្ទាប់មកគាត់ក៏បានលើកឡើង ថាសម្លាប់ឲ្យអស់ឲ្យខ្ទេច ។ ហើយចម្លើយទាំងអស់នោះ គឺខ្ញុំចាំរហូតមកដល់ពេលនេះ តាមរយៈចម្លើយសាក្សី ។ នៅក្នុងការស្រាវជ្រាវរបស់លោក ថាតើវាអាចទេ ឌុច អាចទំនងនិយាយដូច្នោះនៅក្នុងវគ្គរៀនសូត្ររបស់គាត់?

[១៤:២៤:៥២]

**ឆ៖** ខ្ញុំមិនបានឃើញចំណុចលើកឡើងដូច្នោះ ហើយខ្ញុំក៏មិនប្រាកដដែរដែលថាឯកសារទាក់ទងទៅនឹងវគ្គរៀនសូត្រនោះវាមាននៅសល់ដើម្បីបង្ហាញទៅលើចំណុចនេះ ។ ហើយវាជាការចងចាំរបស់លោក ហ៊ីម ហ៊ុយ តែប៉ុណ្ណោះ ។ ដូច្នេះហើយ ចំពោះខ្ញុំនោះវាមិនមែនថា យើងមិនអាចគិតឃើញថាគាត់និយាយ ឬក៏មិននិយាយនោះទេ ។ ដូច្នេះវាជា-- គ្រាន់តែការនិយាយថា វាមានការសម្លាប់ប្រជាជន

ពាក់កណ្តាលតែប៉ុណ្ណោះ ។ ដូច្នេះ ខ្ញុំមិនធ្វើការជឿជាក់ទៅលើការចងចាំទាំងអស់នោះទេ ប៉ុន្តែគ្រាន់តែវាអត់មានឯកសារ ហើយគឺខ្ញុំមិនដឹងទៅលើចំណុចនេះ ហើយក៏ជនជាប់ចោទក៏គាត់មិនបានដឹងដែរ ។ ប្រហែលជាថា ប្រជាជនពាក់កណ្តាលប្រហែលជាគ្មានប្រយោជន៍សម្រាប់បដិវត្តន៍ ។ ហើយខ្ញុំបានអាននៅក្នុងការស្រាវជ្រាវឯកសាររបស់ខ្ញុំ ខ្ញុំក៏បានពិនិត្យច្រើនប៉ុន្តែខ្ញុំមិនទាន់បានស្រាវជ្រាវឃើញ ។

**ស៖** ជនជាប់ចោទបានពន្យល់នៅក្នុងតុលាការច្រើនដងថា សុន សេន គាត់ធ្វើការចាប់អារម្មណ៍ក្បៀកណាស់ទៅនឹងការងាររបស់គាត់ ។ ប៉ុន្តែនៅក្នុងឆ្នាំ១៩៧៧ គាត់បានចេញទៅសមរភូមិ ។ ប៉ុន្តែ សុន សេន នោះគឺជាសមាជិករបស់គណៈមជ្ឈិម ។

ខ្ញុំសូមអានទៅលើចំណុចមួយដែលលោក អេតឆេសាន់ បាននិយាយ ហើយខ្ញុំចង់សួរលោកថា តើលោកយល់ស្របដែរឬទេនៅថ្ងៃទី២៧ ខែឧសភា ទំព័រទី៩០ នៅក្នុងប្រតិចារឹក ។ គាត់បានផ្តល់ឧទាហរណ៍អំពីប្រធានបទទាក់ទងទៅនឹង សុន សេន ។ ឧទាហរណ៍ថា មន្ទីរក្រសួងសង្គមកិច្ចអ្នកទាំងអស់នោះ គឺផ្តល់ការអប់រំដើម្បីចាក់ថ្នាំ ហើយបន្ទាប់មកគេប្រកាសថា អ្នកទាំងអស់នោះជាពេទ្យ ។ ហើយបន្ទាប់មកធ្វើជាពេទ្យ ហើយទៅព្យាបាល ។ ហើយ យើងដឹងថាមានការសម្លាប់ផ្សេងៗដែលកើតឡើងនៅស-២១ ទាក់ទងទៅនឹង *សេអ៊ីអា* និង *ខេជីប៊ី* ។ ហើយអ្នកដែលមានតែការទទួលខុសត្រូវនោះគឺសុន សេន គាត់ក៏ធ្វើការងារយកចិត្តទុកដាក់ទៅលើការសម្លាប់ និងការសួរចម្លើយផ្សេងដែរ ដែលគាត់បានមើលចម្លើយទាំងអស់នោះ ។ តើលោកយល់ស្រប ទៅលើការលើកឡើងរបស់លោក អេតឆេសាន់ បានដែរឬទេ?

[១៤:២៧:២៨]

**ឆ៖** ចំពោះខ្ញុំនោះ គឺវាជាអញ្ញត្រកម្ម ឬការលើកលែងមួយនៅក្នុងក្រឹត្យក្រមរបស់គេ។ អ្វីដែលកើតឡើងវាកើតឡើងហើយ ។ ហើយខ្ញុំក៏មិនដឹងដែរ ថាតើហេតុអីបានជាការបោសសម្អាតនោះវាកើតឡើងទៅដល់រហូតដល់ពេទ្យ ឬក៏បុគ្គលិកពេទ្យអីផ្សេងៗ ។ ហើយប្រហែលជា សុន សេន ហ្នឹងចង់ដឹងចង់ឲ្យចម្លើយសារភាពទាំងអស់នោះដើរស្របទៅនឹងការសម្លាប់កម្មាភិបាលមួយចំនួនជាក់លាក់។ ប៉ុន្តែខ្ញុំក៏ មិនអាចចាំទាំងអស់ដែរ ថាតើអ្នកណាខ្លះពាក់ព័ន្ធទៅលើចំណុចទាំងអស់នេះ ។

**ស៖** សូមអនុញ្ញាតពីលោក ប្រធានឲ្យគាត់ធ្វើការបន្ថយដើម្បីកត់ប្រតិចារឹកឲ្យបានសមស្រប ហើយឲ្យគាត់សូមបង្អាក់នៅពេលដែលនិយាយ ។ នេះគឺជាអ្វីដែលខ្ញុំបានអានជូនលោក ។

លោកអាចនិយាយឡើងវិញ ។

**ឆ៖** វាជាបញ្ហាដូចតែគ្នាទេ ហើយប្រហែលជាជនជាប់ចោទគាត់បានចាំទៅលើចំណុចនេះច្បាស់លាស់ជាងអ្វីដែលខ្ញុំស្រាវជ្រាវ ។ វាមានហេតុផលមួយចំនួនដែលថា វាផ្ដោតទៅលើក្រុមជាក់លាក់ណាមួយ ដោយសារតែវាមានភាពពាក់ព័ន្ធគ្នាចំពោះកម្មាភិបាលជាន់ខ្ពស់ ដូច្នេះហើយចម្លើយទាំងអស់នោះគឺធ្វើយ៉ាងណាឲ្យវាសមស្របទៅតាមអ្វីដែលគេត្រូវការ ។ ប៉ុន្តែ ខ្ញុំក៏មិនដឹងច្បាស់លាស់ទៅលើចំណុចទាំងអស់នេះដែរ ។

**ស៖** សូមអនុញ្ញាតពីលោកប្រធាន សូមសួរសំណួរមួយទៀត ។ ខ្ញុំចង់សួរលោកនូវសំណួរមួយចុងក្រោយ អ្វីដែលលោកនិយាយចុងក្រោយ ទាក់ទងទៅនឹងការជ្រើសរើស ឬជំរើសដែលត្រូវធ្វើឡើងថាតើជនជាប់ចោទនោះគាត់មានជម្រើសដែរឬទេ? ខ្ញុំចង់សួរសំណួរលោកមួយចំនួនទាក់ទងទៅនឹង ម៉ម ណៃ បាននិយាយក្នុងតុលាការហើយសុំយោបល់របស់លោក បន្ទាប់មកខ្ញុំនឹងបញ្ចប់សំណួររបស់ខ្ញុំ ។

"លោក ម៉ម ណៃ និយាយនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៩ ទំព័រ៤៧ នេះវាអ្វីដែលគាត់បានលើកឡើង គឺលោក ម៉ម ណៃ៖ ក្រៅពីអ្នកដែលនៅអង្គភាព អ្នកដែលចូលបដិវត្តន៍ជាមួយខ្ញុំនៅពេលដែល ឌុច ឲ្យ ខ្ញុំដឹងនោះគឺខ្ញុំអាចការពារពួកគេបាន ដោយសារ ឌុច គាត់ស្ដាប់យោបល់របស់ខ្ញុំ ។ ហើយអ្នកណាដែលខ្ញុំមិនស្គាល់ច្បាស់ ឬខ្ញុំមិនដឹងទេ ខ្ញុំមិនអាចការពារបាននោះទេ ។ សំណួរ៖ នៅពេលដែលលោកនិយាយ អំពីសិស្សរបស់លោកមានបញ្ហាហើយលោកមិនអាចជួយបាន ថាតើលោកធ្វើយ៉ាងម៉េចនៅពេលនុ៎ង? ម៉ម ណៃ និយាយថា សិស្សរបស់ខ្ញុំដែលខ្ញុំមិនប៊ានជួយដោយមូលដ្ឋានគេចាប់នោះ ខ្ញុំមិនប៊ានជួយទេ ដោយសារតែគេចាប់សិស្សនោះហើយ ។ ប្រសិនបើខ្ញុំដឹងតាំងពីមុនពេលចាប់ខ្លួនហើយគេប្រាប់ខ្ញុំថាសិស្សរបស់ខ្ញុំនឹងមានបញ្ហានោះ គឺខ្ញុំអាចធានាថា គាត់ជាសិស្សខ្ញុំតែប៉ុណ្ណោះ ហើយមិនមានការចាប់ខ្លួននោះទេ ។ នេះគឺជាចម្លើយ ។ ហើយបន្ទាប់មកខ្ញុំសួរថាតើសាក្សីអាចបញ្ជាក់ទេ វាជាការពិតទេអ្វីដែលគាត់និយាយ? គាត់និយាយថា ពិត។"

តើលោកអាចបញ្ជាក់ទៅលើចំណុចនេះដែរឬទេ ដែលថាកម្មាភិបាលជាន់ខ្ពស់នោះ គឺមានលទ្ធភាពក្នុងការការពារបុគ្គល ឬមនុស្សរបស់គេក្នុងស្ថានភាពជាក់លាក់មួយចំនួននោះ?

**ឆ៖** ខ្ញុំគិតថាវាកើតឡើង គឺវាបានបង្ហាញនិងឆ្លុះបញ្ចាំងនៅក្នុងចម្លើយសារភាព ។ នៅពេលដែលមាននរណាគេចាប់ហើយនោះ គឺវាដូចទឹកធ្លាក់អ៊ីចឹងគឺគេនឹងចាប់តៗគ្នា ។ អ៊ីចឹង វាជាដំណើរការដំណើរទៅមុខនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ យ៉ាងណាក៏ដោយគឺគេមានការចរចាគ្នាដើម្បីកុំឲ្យមានការកើតឡើងទៅលើករណីមួយចំនួន ។ វាទាក់ទងទៅនឹងខ្សែស្រឡាយនិងខ្សែរបស់គេ ។

ឧទាហរណ៍នៅក្នុងសង្គមយើងនៅបច្ចុប្បន្នហ្នឹងក៏មានមនុស្សជួយគ្នា ហើយការពារគ្នាទៅវិញទៅមក អ្នកធំការពារអ្នកតូចអ៊ីចឹងដូចគ្នា ។ ទោះបីជាគោលនយោបាយនោះវាមានការញែកនៅក្នុងសង្គមខ្មែរក៏ដោយ ប៉ុន្តែវាក៏ទាក់ទងទៅនឹងឥរិយាបថឋានានុក្រមដែលគេបានអនុវត្ត ដែលថាអ្នកដែលគាត់ជាមេនោះ គាត់នឹងធ្វើការការពារកូនចៅរបស់គាត់ ។ ហើយវាក៏កើតនៅក្នុងសង្គមខ្មែររបស់យើង ។

**លោក អាឡាំង វែនណឺ៖**

សូមអរគុណខ្ញុំមិនមានសំណួរទៀតទេ។ អ៊ីចឹងសូមអរគុណដែលលោកបានព្យាយាមឆ្លើយ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងបីខ្វះដប់នាទីសូមអញ្ជើញចូលវិញដើម្បីបន្តនូវកិច្ចពិភាក្សាដេញដោលតទៅទៀត ។

មន្ត្រីតុលាការ សម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យដល់អ្នកជំនាញនេះក្នុងអំឡុងពេលឈប់សម្រាក ហើយនិងឲ្យនាំគាត់មកកាន់បន្ទប់ សវនាការឲ្យបានមុនម៉ោងកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៤:៣៣នាទី ដល់ម៉ោង ១៤:៥៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការស្តាប់សក្ខីកម្មអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ជាបន្ត ។ ហើយជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឱកាសក្នុងការសាកសួរដល់អ្នកជំនាញរូបនេះ ។ ប្រសិនបើមានសំណួរសូមអញ្ជើញ។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី៖**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន ។ សូមគោរពលោកចៅក្រមជាតិ និងអន្តរជាតិ និងសូមគោរពអង្គសវនាការទាំងមូល ។

**សៈ** ខ្ញុំបាទសូមអនុញ្ញាតឲ្យលោកសាស្ត្រាចារ្យជួយបញ្ជាក់សាជាថ្មី ព្រោះព្រឹកមិញលោកសាស្ត្រាចារ្យបានបញ្ជាក់ហើយ តែខ្ញុំមិនបានក្តាប់វាមិនបាន មិនបានយល់អាបញ្ហាហ្នឹងឲ្យអស់ ។ អ៊ីចឹងខ្ញុំសូមឲ្យលោកសាស្ត្រាចារ្យជួយបញ្ជាក់អំពីស-២១ស្ថាប័នស្វយ័ត ។ ដោយលោកសាស្ត្រាចារ្យព្រឹកមិញនេះ បានបញ្ជាក់ថា វាស្វយ័តវាមានធាតុផ្សំជាច្រើន ធាតុរបស់វាច្រើន ក៏ប៉ុន្តែក្នុងធាតុច្រើនហ្នឹងខ្ញុំបានយល់មួយចំនួនហើយ ប៉ុន្តែនៅបីធាតុដែលខ្ញុំមិនច្បាស់ ។

ឧទាហរណ៍ទីមួយ លោកសាស្ត្រាចារ្យបានបញ្ជាក់ថា ក្រដាសស្នាម ។ បានសេចក្តីថា របាយ-ការណ៍អីៗទាំងអស់ហ្នឹង ត្រូវបញ្ជូនទៅថ្នាក់លើ ។ នែវាស្វយ័តត្រង់ថាអាហ្នឹង វាបញ្ជូនទៅថ្នាក់លើអ៊ីចឹងមានតែគុកដទៃទៀត វាបញ្ជូនទៅថ្នាក់ក្រោម ព្រោះអាហ្នឹងវាខុសគេបានវាស្វយ័តកើត ។ នេះគឺជាចំណុចទីមួយដែលខ្ញុំមិនសូវយល់ ។

ចំណុចទីពីរថា គុកដទៃទៀត មិនដឹកនាំជាអ្នកកំពូលដូច សុន សេន ។ អ៊ីចឹង នាំឲ្យខ្ញុំឆ្ងល់ថាតំបន់និរតី តាម៉ុក គាត់ដឹកនាំ ហើយតាម៉ុក គាត់ក្តាប់គុកតំបន់និរតី ហើយ តាម៉ុក ជាបុគ្គលទីបួន ក្នុងមជ្ឈិមបក្ស ។ ចំណែក សុន សេន តូចជាងតាម៉ុក ទេ គឺជាបុគ្គលទីប្រាំពីរ ។ នេះជាចំណុចមួយទៀត។ ហើយមួយទៀត ដូចជានៅបូព៌ា សោ យ៉ាន់ ហៅ ភឹម ជាបុគ្គលក្នុងមជ្ឈិមបក្ស គាត់ក្តាប់គុកនៅបូព៌ា ។ ហើយជាពិសេសមួយទៀតនោះ ឯកសារដែលថា មានសិទ្ធិសម្រេចកម្ទេចក្នុងជួរនិងក្រៅជួរ ក្នុងនោះខ្ញុំឃើញថា នៅតំបន់ឯករាជ្យៗ គឺត្រូវអចិន្ត្រៃយ៍សម្រេច ។ អ៊ីចឹងគឺអចិន្ត្រៃយ៍ហ្នឹង អចិន្ត្រៃយ៍អ្នកណា? គឺអចិន្ត្រៃយ៍មជ្ឈិមបក្សហ្នឹង គឺ ប៉ុល ពត ។ អ៊ីចឹង តើតំបន់ឯករាជ្យនោះ មជ្ឈិមបក្សហ្នឹង ក្តាប់គុកទាំងនុំងឬទេ? អចិន្ត្រៃយ៍ហ្នឹងក្តាប់ឬទេ? ដែលនាំឲ្យខ្ញុំឆ្ងល់ ។

[១៤:៥៨:១៥]

នៅចំណុចមួយទៀត ធាតុមួយទៀតថាស-២១ វាជាស្ថាប័នស្វយ័តត្រង់ថា ស-២១ មានទូរស័ព្ទមានអង្គលីលេខ ឯគុកដទៃទៀតគ្មាន ។ ចុះតំបន់ស្វយ័ត--អុំ! តំបន់ឯករាជ្យ ដូច ប៉ុល ពត ក្តាប់ ។ តំបន់ឯករាជ្យហ្នឹង គុកធំណាស់ តើតំបន់ឯករាជ្យហ្នឹង មានអង្គលីលេខទេ? តំបន់ឯករាជ្យហ្នឹង មានទូរស័ព្ទទេ? ខ្ញុំវាអត់បានដឹង ។ ដូច្នេះ សូមឲ្យលោកសាស្ត្រាចារ្យមេត្តាជួយបញ្ជាក់ចំណុចទាំងអស់នេះសូមអរគុណ ។

**ឆៈ** ខ្ញុំឆ្លើយចម្លើយដែលងាយមុនគេ ។ ខ្ញុំមិនបានសិក្សាពីតំបន់ឯករាជ្យទេ ខ្ញុំសិក្សាពីស-២១ មិនដឹងថា តើគុកទាំងអស់នោះមានអ្វីខ្លះនោះទេ? ខ្ញុំមិនអាចឃើញថា មនុស្សផ្សេងៗទៀតបានដឹងរឿង

ច្រើននោះទេ ។ ប៉ុន្តែ នៅភូមិភាគនិរតី តាម៉ុក មានស្វ័យភាពច្រើនជាងតំបន់ផ្សេងៗ គាត់ជាមនុស្សមានឥទ្ធិពលនៅទីបីនៅក្នុងលំដាប់នោះ ។ គាត់មិនទទួលបញ្ជាពីអ្នកណាទេ លើកលែងតែ ប៉ុល ពត ដែលក្រោយមកដែលថាគាត់ៗបានចេញជា ធ្វើការកម្ទេចដោយខ្លួនគាត់ ។

ប៉ុន្តែ ពាក្យដែលថា ស្វយ័ត ពាក្យរបស់ខ្ញុំប្រើនេះ តាមព័ត៌មានដែលខ្ញុំប្រមូលដើម្បីសរសេរសៀវភៅខ្ញុំនេះ ។ ជនជាប់ចោទបានផ្តល់ បានទទួលនូវសិទ្ធិ នូវការអនុវត្តការងាររបស់គាត់ គាត់បានទទួលគោលនយោបាយ ហើយនិងការកំណត់នូវខ្សែក្បត់ ឬបណ្តាញរបស់ខ្មាំងជាការណែនាំហ្នឹង ។ អ៊ីចឹងហើយការគ្រប់គ្រងប្រចាំថ្ងៃហ្នឹងគឺ សុន សេន ជាអ្នកមេផ្ទាល់របស់គាត់នោះ គឺពិគ្រោះយោបល់ជាមួយគាត់ ស្ទើរតែរាល់ថ្ងៃ ឬក៏រៀងរាល់សប្តាហ៍នោះ ។ ហើយខ្ញុំមិនគិតថា ខ្ញុំមិនចាំពីចម្លើយ សំណួរផ្សេងទៀតទេ ខ្ញុំមិនអាចនិយាយបានពីគុកនៅកន្លែងតំបន់ឯករាជ្យ ដែលគ្រប់គ្រងដោយគណៈមជ្ឈិមដែលខ្ញុំមិនបានដឹងពីមុន ហើយខ្ញុំដឹងតិចតួចណាស់ គឺគុកទាំងអស់នេះ ។ ហើយខ្ញុំមិនគិតថា យើងមានឯកសារដែលអាចឲ្យយើងដឹងថា វាដំណើរការម៉េច? ហើយតាមពិតទៅវាមិនមែនជាគំនិត ដែលខ្ញុំបានសិក្សាស្រាវជ្រាវនោះទេ ។

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ ខ្ញុំបាទសូមសួរមួយទៀត ដែលខ្ញុំឆ្ងល់ ។ លោកតាមរយៈការឆ្លើយរបស់លោកសាស្ត្រាចារ្យព្រឹកមិញថា មានការប៉ះទង្គិចផ្លូវយោធារវាងកងទ័ពវៀតណាម និងកងទ័ពកម្ពុជា ហើយការប៉ះទង្គិចនេះមិនមានការផ្សព្វផ្សាយទេ ។ ខ្ញុំបាទកន្លែងនេះសួរថា តើលោកសាស្ត្រាចារ្យផ្អែកលើឯកសារអី ដែលថាមិនមានការផ្សព្វផ្សាយ?

[១៥:០២:០១០]

**ឆ៖** ប្រសិនបើមិនផ្សព្វផ្សាយនោះ ខ្ញុំផ្អែកទៅលើអ្វីដែលខ្ញុំឃើញនៅក្នុងឯកសារ គឺមិនមានឯកសារថាមានការផ្សព្វផ្សាយ គឺនៅក្នុងឆ្នាំ១៩៧៧ ទើបដែលយើងមានវិទ្យុភ្នំពេញដែលផ្សព្វផ្សាយអំពី-ការផ្សព្វផ្សាយត្រូវបានតាមដាន ហើយរៀបចំឡើង ហើយកត់ត្រាដោយ *ប៊ីប៊ីស៊ី* ឬក៏សហរដ្ឋអាមេរិក។ នេះហើយដែលជាភស្តុតាងដែលខ្ញុំបញ្ជាក់ដែលឃើញថា មិនមានការផ្សព្វផ្សាយនោះ ។ នៅក្នុងឆ្នាំ១៩៧៨ បន្ទាប់ពីការបំបែកទូត ផ្តាច់ការទូតជាមួយវៀតណាម ក្រោយពីវៀតណាមវាយប្រហារចូលកម្ពុជាក្នុងចុងឆ្នាំ១៩៧៧នោះ រហូតទាល់តែគេដកនៅខែមករា ឆ្នាំ១៩៧៨ ។ ពេលនោះ ទើបបានខ្មែរប្រកាសជោគជ័យលើវៀតណាមនៅពេលនោះ ។

នេះហើយគឺថា ការប្រកាសនោះ គឺប្រកាសក្រោយពេលដែលសង្គ្រាមហ្នឹងកើតឡើង ពេលដែល

សង្គ្រាមកើតនោះអត់មានបានប្រកាសបានផ្សាយទេ ។

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ ។ ខ្ញុំបាទសូមសួរមួយទៀត លោកសាស្ត្រាចារ្យបានមានប្រសាសន៍ថា បណ្ណសារនៅស-២១ វាជាបណ្ណសារពិសេសជាងបណ្ណសារនៅមន្ទីរសន្តិសុខដទៃទៀត ។ អ៊ីចឹង ខ្ញុំអាចសុំអនុញ្ញាតសួរលោកសាស្ត្រាចារ្យថា តើលោកសាស្ត្រាចារ្យមានបណ្ណសារគ្រប់មន្ទីរសន្តិ-សុខទាំងអស់ដែរឬទេ? ពីព្រោះខ្ញុំនៅឆ្ងល់ថា វាទាល់តែមានគ្រប់ទាំងអស់ ហើយយកមកប្រៀបធៀបគ្នាទៅបានឃើញថាស-២១ ហ្នឹងវាពិស្តារជាង-- ពិសេសជាងគេ ពិស្តារជាងគេទៅកើត ។ ដូច្នេះ ខ្ញុំសូមសួរលោកសាស្ត្រាចារ្យថា តើលោកសាស្ត្រាចារ្យមានបណ្ណសារគ្រប់មន្ទីរសន្តិសុខទាំងអស់ដែរឬទេ?

សូមអរគុណ ។

**ឆ៖** គឺបណ្ណសារដែលខ្ញុំបានដឹងនោះ គឺពេលដែលខ្ញុំសរសេរសៀវភៅ គឺយកមកពីគុកនៅនិរតីដែលមានទំហំច្រើនគួរសម តែមិនអាច ទំហំនោះ គឺមិនអាចប្រៀបបានទៅនឹងបណ្ណសារនៅស-២១ បានទេ ។ នេះគឺជាឯកសារដែលនៅសេសសល់ ដែលថាមានទំហំធំ កាន់តែច្រើនឡើងៗ ដែលបានប្រមូលនៅសល់ទៅតាមដែលខ្ញុំដឹង ។ អ៊ីចឹង គឺបណ្ណសារឯកសារនោះ ខ្ញុំអាចហ្នឹងខុស ប៉ុន្តែខ្ញុំមិនគិតថាគុកតាមខេត្ត តាមតំបន់ គឺវាមានលក្ខណៈទូលំទូលាយច្រើន ដូចបណ្ណសារឯកសារនៅក្នុងស-២១ នោះទេ ។ ដែលថាវាមានលើសពីបួនពាន់ ចម្លើយសារភាពបួនពាន់ជាងនោះ ។ អ៊ីចឹង គឺមានបញ្ជីអ្នកទោសហើយនិងបញ្ជីសម្លាប់ បញ្ជីកម្ទេច ។ ឯកសារដែលនិយាយពីវគ្គសិក្សា ហើយនិងឯកសារនិយាយអំពីទិតៀន ស្វ័យទិតៀន គឺជាបណ្ណសារឯកសារ ដែលទូលំទូលាយច្រើន ហើយមជ្ឈមណ្ឌលឯកសារកម្ពុជាមានមួយចំនួន ។ ហើយខ្ញុំអាចហ្នឹងដកពាក្យនោះវិញ ប្រសិនបើមានឃើញមានបណ្ណសារណាមួយក្នុងតំបន់ណាមួយច្រើនជាងហ្នឹង ។ ប្រសិនជាបុគ្គលណានៅកម្ពុជាអាចបង្ហាញខ្ញុំ បើមានឯកសារច្រើនជាងនេះ ឬប្រហែលនេះ ត្រូវបានបាត់បង់ ខ្ញុំអាចហ្នឹងដកពាក្យពិសេសហ្នឹងវិញបាន ។

[១៥:០៦:០៤]

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ ។ តាមការស្រាវជ្រាវរបស់លោកសាស្ត្រាចារ្យ តាមការសិក្សារបស់លោកសាស្ត្រាចារ្យលើស-២១ តើលោកសាស្ត្រាចារ្យ មានដឹងទេថាតើ ឌុច មានសិទ្ធិដើរចាប់មនុស្សចូលស-២១ ឬទេ?

**ឆ៖** ខ្ញុំមិនគិតថាគាត់មានអំណាចនោះទេ ។ ការចាប់ខ្លួននោះ គឺគេគាត់មិនមានអំណាចធ្វើការចាប់ចងនៅតាមជនបទ។ គាត់អាចហ្នឹងមានលទ្ធភាពត្រឹមតែបញ្ជូនឈ្មោះមនុស្សទៅតាមតំបន់ភូមិភាគ។

អ៊ីចឹងសិទ្ធិនៃការចាប់ខ្លួននោះ គឺខ្ញុំមិនប្រាកដ ហើយខ្ញុំមិនអាចបញ្ជាក់បានទេ ។ ខ្ញុំមិនគិតថា គាត់មានអំណាចក្នុងចាប់ទេ ហើយក៏ខ្ញុំមិនគិតថា គាត់គិតថា គាត់មានអំណាចហ្នឹងដែរឬទេនោះដែរ ។

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ ជួយបញ្ជាក់ថែមទៀត តាមការស្រាវជ្រាវរបស់លោកសាស្ត្រាចារ្យ តើជនជាប់ចោទអាចបញ្ជាឲ្យយកអ្នកទោសទៅកម្ទេចដោយគ្មានការបញ្ជាពីថ្នាក់លើដែរឬទេ?

**ឆ៖** ចំណុចមួយ ចម្លើយទៅនឹងសំណួររបស់លោកនោះ គឺថាយើងមិនមានបញ្ជាពីថ្នាក់លើមកនោះទេ គឺឯកសារនោះមិនមានដែលធ្វើ បើសិនជាមានឯកសារនោះ ធ្វើឲ្យការងារសាលាក្ដីហ្នឹង គិតតែស្រួលដូចជាមិនមានចំណារ ឬក៏ឯកសារបញ្ជាក់ថាកម្ទេចចំនួនប៉ុណ្ណេះ ប៉ុណ្ណោះនោះ? ប៉ុន្តែ ខ្ញុំគិតថាអាណត្តិការងារដែលជនជាប់ចោទ ការងាររបស់គាត់នៅស-២១ នោះ គឺពិនិត្យមើល ។ គាត់យល់ថាម្នាក់ៗដែលគេបញ្ជូនមកស-២១ គឺត្រូវតែសម្លាប់ ។ នេះគឺជាអាណត្តិការងារ គឺមិនអាចដកវិញបានដោយថ្នាក់លើនោះទេ ។ ដូច្នេះ ហើយគាត់មិនចាំបាច់ស្វែងរកអំណាចពីខាងលើ ដើម្បីគ្រប់គ្រងលើប្រព័ន្ធហ្នឹង ដែលគាត់មិនមានជម្រើសថា តើអ្នកណាត្រូវសម្លាប់? អ្នកណាត្រូវទុកនោះទេ? ពីព្រោះគាត់យល់ថាម្នាក់ៗត្រូវតែសម្លាប់ ។ អ៊ីចឹង ហើយមិនចាំបាច់អីសួរទៅថ្នាក់លើនៅក្នុងករណីមួយៗនោះទេ។

ជាថ្មីម្ដងទៀត ខ្ញុំអាចខុសប្រសិនបើចំណុចនេះ គាត់គិតថា ថ្នាក់លើគាត់តាមដានគ្រប់ដំណាក់កាលទាំងអស់ គេចាំបាច់ ជាពិសេសនៅក្នុងចំពោះអ្នកទោសណាមួយនោះ គាត់អាចនឹងដឹងពី សុន សេន ថាតើអ្នកទោសមួយនេះ គប្បីចាត់ការយ៉ាងម៉េច? តើត្រូវសួរយ៉ាងម៉េច? ។ល។

អ៊ីចឹងហើយការសន្ទនាបែបនេះ យើងមិនអាចមានកំណត់ត្រានៅសល់ទេ ដែលបញ្ជាក់ពីអំណាចនោះ ។ ប៉ុន្តែ វាមិនដែលមានអំណាចដើម្បីសម្លាប់អ្នកណាម្នាក់ ដែលថាចំពោះកុមារតូច ហើយនិងអ្នកដែលបញ្ជូនមកទាំងអស់នោះ គឺត្រូវមានជោគវាសនាតែមួយដូចគ្នានោះឯង ។

[១៥:០៩:៥០]

**ស៖** អរគុណលោកសាស្ត្រាចារ្យ ខ្ញុំសូមសួរមួយសំណួរទៀត ។ ព្រឹកមិញលោកសាស្ត្រាចារ្យបានមានប្រសាសន៍ថា ពេលនោះ គឺពេលដែលជនជាប់ចោទនៅជាប្រធានស-២១ គឺពេលនោះ ជនជាប់ចោទមិនបានសរសេរ ឬក៏មិនបាននិយាយថា ខ្លួនមិនពេញចិត្តនឹងការងាររបស់គាត់ទេ ។ ជនជាប់ចោទអត់មានឯកសារអីមួយថា គាត់បានសរសេរទេ គាត់មិនពេញចិត្តនឹងការងាររបស់គាត់គឺអត់មានទេព្រោះបើជនជាប់ចោទបានសរសេរ ឬនិយាយបែបនេះ នោះគឺជាការសម្លាប់ខ្លួនឯង ។ លោកសាស្ត្រា-

ចារ្យ មានប្រសាសន៍ព្រឹកមិញថា នោះគឺជាការសម្លាប់ខ្លួនឯង ។ អ៊ីចឹង ខ្ញុំសូមសួរលោកសាស្ត្រាចារ្យថា តើលោកសាស្ត្រាចារ្យនៅតែប្រកាន់គំនិត ឬជំហរនេះដដែល ឬយ៉ាងណា? សូមអរគុណ ។

**ឆ៖** តាមពិតខ្ញុំមិនបានឃើញអ្វីក្នុង-- បញ្ជាក់ព្រឹកមិញនេះ ដែលថាធ្វើឱ្យខ្ញុំប្តូរគំនិតអ្វីដែលខ្ញុំបញ្ជាក់នោះទេ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណលោកសាស្ត្រាចារ្យដែលបានជួយបញ្ជាក់ក្នុងរឿងនេះ ហើយសូមអរគុណលោកប្រធាន ខ្ញុំអស់សំណួរហើយ ។ សូមផ្ទេរសំណួរទៅលោកមេធាវី ហ្វ្រង់ស្វ័រ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ ។

**សួរដោយលោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោក ដេវីដ ឆេនដ៍ល័រ ។ សូមអរគុណដែលលោកមានសេចក្តីអំណត់ ដែលប្រឈមមុខនឹងសំណួរជាច្រើន ប៉ុន្តែ ខ្ញុំមានសំណួរមួយចំនួនទៀតត្រូវសួរលោក ។

ជាដំបូង ខ្ញុំសូមថ្លែងអំណរគុណអស់ពីដួងចិត្តចំពោះលោក ចំពោះការធ្វើដំណើរពីចម្ងាយមកតុលាការនេះ ។ សក្ខីកម្មរបស់លោកនេះ គឺមានតម្លៃណាស់សម្រាប់បញ្ជាក់ស្វែងរកការពិត ។ សំណួរទីមួយរបស់ខ្ញុំគឺទាក់ទងទៅនឹងសំណួរទូទៅ ហើយខ្ញុំផ្អែកទៅលើអត្ថបទជាភាសាបារាំង ដែលមានចំណងជើងថា“ស-២១គឺជាបទឧក្រិដ្ឋដែលមិនទាន់ដាក់ទោសទៅលើខ្មែរក្រហម” ហ្នឹងជាការបកប្រែ ។ អ៊ីចឹងហើយថ្ងៃនេះលោកក្លាយជាសាក្សីជំនាញចំពោះមុខសាលាក្តីអន្តរជាតិមួយនេះ ។ នេះគឺជាតុលាការដែលធ្វើការជំនុំជម្រះលើកដំបូងទៅលើខ្មែរក្រហម ។

**ស៖** លោក ឆេនដ៍ល័រ តើលោកគិតថា អង្គជំនុំជម្រះនេះជាសាលាក្តីដែលឆ្លើយទៅនឹងប្រវត្តិ-សាស្ត្រដែរឬទេ?

**ឆ៖** សូមអរគុណចំពោះសំណួររបស់លោក ។ គឺជាសំណួរដ៏ធំមួយក្នុងថ្ងៃនេះ បើប្រៀបធៀបសំណួរមុនៗនោះ ។ ចម្លើយល្ងចនោះ គឺថាមិនអាចនឹងបញ្ជាក់លម្អិតនោះបានទេ ប៉ុន្តែខ្ញុំគិតថាការជំនុំជម្រះដែលមានការវិវឌ្ឍន៍ជាច្រើនមកហើយនោះ ដូចខ្ញុំបានអាន បានដឹង ។ ដែលបានប្រើជាការប្រឈមទៅលើជនជាប់ចោទ ហើយនិងរឿងក្តីរបស់គាត់នោះ មានភស្តុតាងខ្លះដែលយើងប្រកាន់យក ដែលថា

ត្រូវទទួល ឬក៏ត្រូវបដិសេធនោះដែរ ។ នៅក្នុងតទល់ប្រឈមនឹងគ្នានេះ គឺជាពេលមួយដែលមិនដែលធ្លាប់កើតមានទេនៅក្នុងរបបខ្មែរក្រហមនូវអ្វីគេធ្វើគឺធ្វើ ហើយគេដើរចេញ ។ មិនត្រឹមតែជនជាប់ចោទពេលនេះទេ នៅក្នុងចំណោមបងដែលថា រស់រាននៅដល់ពេលសព្វថ្ងៃនេះដែរនោះ ។

អ៊ីចឹង គឺកិច្ចការជនត្រូវចោទ ជនជាប់ចោទទាំងអស់នេះ គឺត្រូវភ្ជាប់ទៅនឹងការទទួលខុសត្រូវពីរឿងការពិត អំពីអ្វីដែលបានកើតឡើងនៅពេលដែលគេកាន់អំណាចនោះ ។ ដើម្បីសួររកភស្តុតាងថា តើភស្តុតាងនោះពិត មិនពិត ទុកចិត្តបាន ឬអត់នោះ? គឺពលរដ្ឋកម្ពុជាមួយចំនួន ត្រូវតែយល់ដឹងអំពីរឿងហ្នឹង ថាតើវាមានរឿងអ្វីកើតឡើងនៅក្នុងទំហំដែលធំធេង ជាងអំពើរន្ធត់ដែលយើងធ្លាប់បានដឹងទាំងអស់គ្នានោះ ដែលធ្វើឲ្យពលរដ្ឋកម្ពុជាដែលមានអាយុជាង៤០ហ្នឹង គឺថាអាចដឹងថាអាចបានឆ្លងកាត់ក្នុងសម័យរបបខ្មែរក្រហមនោះ ។

[១៥:១៥:៥០]

**ស៖** សូមអរគុណ ខ្ញុំសួរសំណួរតនឹងមួយទៅទៀត ។ ចាប់តាំងពីព្រឹកមិញនេះ មិនមានអ្នកណាម្នាក់បានលើកឡើងអំពីអង្គហេតុថា ជនជាប់ចោទបានសារភាពទោសកំហុស ហើយប្រកាសការទទួលការទទួលខុសត្រូវរបស់គាត់នោះទេ ។ ដោយបានធ្វើការងារនេះជាយូរមកហើយនៅស-២១ តើលោកពិចារណាថា តើការទទួលស្គាល់របស់ជនជាប់ចោទ ជនជាប់ចោទអំពីការទទួលរបស់គាត់បម្រើដល់ផលប្រយោជន៍ប្រវត្តិសាស្ត្រដែរឬទេ?

**ឆ៖** តាមពិតនោះ ខ្ញុំមានអារម្មណ៍រំភើប ហើយចាប់អារម្មណ៍ដែលថា ការប្រកាសអំពីការទទួលខុសត្រូវហ្នឹង វាខិតជិតទៅដល់ មិនមែនត្រឹមតែជនរងគ្រោះដែលរួចរស់មានជីវិតទេ ប៉ុន្តែចំពោះអ្នកដែលមានសកម្មភាពក្នុងរបបនោះផងដែរ ។

[១៥:១៧:០៥]

**ស៖** សូមអរគុណ ។ ប៉ុន្តែ យើងព្យាយាម ហើយលោកបានជួយយើងដើម្បីឲ្យយល់តាមវិធីនៃការតទល់គ្នាដែលបានកើតឡើងនេះ ។ តើកម្រិតនៃការទទួលខុសត្រូវនៃបុគ្គលម្នាក់ៗ ដែលមានការពាក់ព័ន្ធនោះ ផ្អែកលើសំណួរដែលចោទឡើងដោយសហព្រះរាជអាជ្ញា និងមេធាវីដើមបណ្តឹងរដ្ឋប្បវេណីដោយមិនគិតអំពីការទទួលស្គាល់អង្គហេតុដោយជនជាប់ចោទ ។ វាមានការប៉ុនប៉ងដើម្បីបន្ថែមលើហ្នឹងទៀតដែលខ្ញុំអាចបញ្ជាក់បាន ។ គឺមានការប៉ុនប៉ងដើម្បីបង្ហាញភស្តុតាងថា គាត់មានស្វ័យភាព ច្រើនជាងអ្វីដែលគាត់បានអះអាង ។ ថាតើមេធាវីការពារហ្នឹង គឺអាចឆ្លើយតបទៅវិញ និងត្រូវពិនិត្យទៅក្នុង

សៀវភៅរបស់លោកដើម្បីរកឲ្យឃើញ ដើម្បីចង្អុលបង្ហាញថា តើអ្វីដែលចង្អុលបង្ហាញពីការពិតពីអ្វីដែលបានកើតឡើងនោះ ។

ខ្ញុំនឹងពិនិត្យមើលចំណុចមួយចំនួន ជាពិសេសអំពីខ្សែរយៈនៃការបញ្ជា។ តើ ឌុច នៅក្នុងចំណុចណានៃខ្សែបញ្ជាហ្នឹង? នៅក្នុងសៀវភៅរបស់លោកនៅកថាខណ្ឌ៣៧-- (ពាក្យរបស់លោករូ) កថាខណ្ឌទី១ យោងទៅរកឈ្មោះ សុន សេន លោកបាននិយាយថា "ការទទួលខុសត្រូវគឺរាប់បញ្ចូលទាំងមន្ទីរសន្តិបាល សុន សេន គ្រប់គ្រងការងារនេះយ៉ាងជិតស្និត ។ គាត់បានអាន ហើយធ្វើចំណារលើចម្លើយសារភាពមួយចំនួន ហើយគាត់ក៏ដឹកនាំវគ្គសិក្សាអប់រំកម្មាភិបាលស-២១ មួយចំនួន ដែលគាត់ពិភាក្សាពីគោលបំណងអំពីការសួរចម្លើយ ហើយនិងការប្រើទារុណកម្ម" ។

នៅក្នុងកថាខណ្ឌទី២ នៃទំព័រនោះលោកបានបញ្ជាក់ថែមទៀតថា ឯកសារជាច្រើនដែលផលិតឡើងដោយស-២១ ដែលបញ្ជូនពីស-២១ ទៅមជ្ឈិមបក្សគឺធ្វើឡើងតាមរយៈ សុន សេន តាមដៃផ្ទាល់របស់ សុន សេន ។ ហើយលិខិតឆ្លើយឆ្លងជាច្រើនដែល ឌុច សរសេរទៅគាត់នោះ បាននៅសេសសល់ ។ ដូច្នេះហើយ យើងមានចម្លើយជាច្រើនពីគាត់ ។ តើគំនិតទាំងនេះមានបង្ហាញ គឺជាការប៉ុនប៉ងបញ្ជាក់អំពីសេចក្តីលម្អិតមួយចំនួន ហើយដើម្បីបញ្ជាក់ពីយតិភាព ឬក៏ភាពមោះមុតពីចំពោះបដិវត្តន៍ ។ យុន យ៉ាត ជាប្រពន្ធរបស់ សុន សេន ក៏ជាអតីតគ្រូបង្រៀនដែរ ធ្វើយ៉ាងជិតស្និតជាមួយគាត់ ហើយមានលទ្ធភាពមើលចម្លើយសារភាពមួយចំនួនដែរ ។ សេចក្តីចម្លងដកស្រង់ចប់ប៉ុណ្ណោះ ។

អ៊ីចឹង តើមតិយោបល់ទាក់ទងទៅលើផ្នែកនេះដូចម្តេច? តើលោកអាចបញ្ជាក់បានទេថា ឌុច គឺជាអ្នកក្រោមបង្គាប់របស់ សុន សេន?ហើយ សុន សេន មានអំណាចផ្តាច់ព្រ័ត្រទៅលើសន្តិបាលមួយនេះ?

[១៥:២១:១៣]

**ឆ៖** ពិតហើយ នោះគឺជាការពិត ។ ខ្ញុំមិនដែលនិយាយថា ជនជាប់ចោទមានអំណាចផ្តាច់មុខទៅលើការងារទេគឺ សុន សេន ។ ចម្លើយសារភាពមួយចំនួននោះ គឺយើងពិនិត្យមើលឃើញថា ចម្លើយសារភាពមួយចំនួនតូចទេ ដែល សុន សេន មានចំណារ-- ចំណារ សុន សេន ភាគច្រើន គឺមានចំណាររបស់ជនជាប់ចោទ ។

ប៉ុន្តែ តាមពិតសំណួររបស់លោកនោះ គឺមិនមែនជាផ្លូវនៃប្រតិបត្តិការ ប៉ុន្តែប្រតិបត្តិការទៅតាមការបញ្ជារបស់រដ្ឋ ។ ប៉ុន្តែ សំណួរដំបូងនោះបង្ហាញថា មើលទៅដូចជាភាពមានច្របូកច្របល់ក្នុងការប្រព្រឹត្តទៅក្នុងកម្ពុជាប្រជាធិបតេយ្យដែលថា តាម៉ុក មានអំណាចផ្តាច់មុខនៅភូមិភាគនិរតី ប៉ុន្តែ សុន

សេន មិនមានឥទ្ធិពលទៅលើ តាម៉ុក ។ ប៉ុន្តែ សុន សេន មានឥទ្ធិពលមកលើស-២១ វិញ ។ អ៊ីចឹង ទាក់ទងទៅនឹងសំណួររបស់លោកនោះ គឺពិតហើយ ហើយយើងនឹងពិនិត្យមើលចំណុចមួយផ្សេងទៀតនោះ ។

**ស៖** បាទ, ពិតជាអ៊ីចឹងមែន ។ ចំណុចជាច្រើន ដែលសហព្រះរាជអាជ្ញា ហើយនិងមេធាវីបានលើកឡើងទៅសម្តីរបស់លោក អេតឆេសាន់ បានបញ្ជាក់ប្រាប់តុលាការ ។ ហើយគាត់បានបញ្ជាក់មួយចំនួនថា ខ្ញុំសោកស្តាយដែលគាត់ថា-- ខ្ញុំសោកស្តាយគាត់ជាអ្នកជំនាញ ប៉ុន្តែគាត់ធ្វើការឲ្យសហព្រះរាជអាជ្ញា ។ គាត់បានយោងទៅរកចំណុចនេះ គាត់ជាផ្នែកមួយនៃមាគ៌ារបស់បក្សកុម្មុយនីស្តកម្ពុជា គាត់បានយោងទៅរកលក្ខន្តិកៈបក្ស ដែលថា តម្រូវឲ្យកម្មាភិបាលឲ្យមានលក្ខណៈសកម្ម និងក្នុងការងារ។ ហើយនៅពេលដែលយោងទៅមាត្រា៤នៃលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា គឺគោលជំហរបដិវត្តន៍នោះ គឺសេចក្តីសម្រេចចិត្តធ្វើទាក់ទងនឹងកិច្ចរបស់បក្សនោះ ។ គេនិយាយថា អ្នកត្រូវតែមានអាកប្បកិរិយាគ្រប់គ្រងការងារដែលជិតស្និតទៅនឹងមហាជន សហករណ៍ ហើយនិងកងព័ទបដិវត្តន៍ ហើយឲ្យមានលក្ខណៈរស់រវើក ហើយនិងស្វ័យភាព ម្ចាស់ការ ហើយបន្តមានស្មារតីប្តេជ្ញាត្រចះត្រចង់ ។

នៅពេលដែលយោង លោកយោងទៅរកការព្យាយាមស្រឡាញ់ការងាររបស់ ឌុច នោះ ហើយការណ៍នេះគឺ មិនជាផ្នែកមួយនៃមាគ៌ារបស់បក្ស ដែលតម្រូវទេ ។

**ឆ៖** ពិតហើយ មិនមែនជាផ្នែកនៃមាគ៌ាបក្សទេ ប៉ុន្តែ អ្វីដែលជនជាប់ចោទមិនបានបញ្ជាក្នុងការទទួលស្គាល់ ហើយមិនបានបដិសេធការងារនោះទេ ។ ប៉ុន្តែ ក្នុងលទ្ធភាពរបស់គាត់ៗគឺជាមនុស្សរបស់បដិវត្តន៍នោះ ។ អ៊ីចឹងហើយគាត់អនុវត្តតាមហ្នឹង គាត់រក្សាគោលជំហរ ហើយនិងតំណែងរបស់គាត់ជាមនុស្សមួយនៅក្នុងបក្សរបស់គាត់ ។ អ៊ីចឹងហើយ យើងស្របធ្វើតាមមាគ៌ាបក្ស គឺថាជនជាប់ចោទមិនមែនជាមនុស្សដាច់ឯករាជ្យពីមាគ៌ាបក្សនោះទេ ។

[១៥:២៥:៣៥]

**ស៖** នេះមិនមានការពាក់ព័ន្ធនោះ តើលោកនិយាយថា តើគាត់ខ្លួនឯងអាចមានការព្រួយបារម្ភ ឬក៏ពោរពេញដោយសេចក្តីភ័យខ្លាច ដែលលោកនឹកឃើញ យកមកសរសេរនៅក្នុងសៀវភៅ៦៦ របស់លោក ជាភាសាបារាំងនោះសរសេរថា “ការកែប្រែនោះ គឺខ្សែសង្វាក់នេះ គឺបង្កនូវភាពភ័យរន្ធត់ ដោយសារគេមានការភ័យខ្លាចថា របបកម្ពុជាប្រជាធិបតេយ្យអាចនឹងដួលរលំ” ។ ប្រសិនបើលោកនឹកថា អ្នកដឹកនាំស-២១ មុន ឌុច ឈ្មោះ ណាត នោះ ។ ប្រសិនបើលោកនឹកឃើញ វន វ៉េត ជាអតីតជាមេ

របស់គាត់ ហើយចុងបញ្ចប់បានមកជាប់នៅស-២១ ដែរនោះ ហើយពេលនោះគេជួបជោគវាសនាដូចម្តេច? ហើយអ្នកទាំងពីរនាក់នោះ គឺជាអ្នកដើរតួដំបូង ហើយក្លាយទៅជាចំណាប់ខ្មាំងរបស់របបនោះវិញដែរ ។ ហើយគាត់និយាយថា ខ្ញុំជាអ្នកសម្តែងតួ ឬក៏អ្នកបង្កើត ហើយក្រោយមកក្លាយទៅជាចំណាប់ខ្មាំងនៃរបបនេះ ។ ដូច្នេះ ថាតើយើងអាចនិយាយបានដូចម្តេច បើគាត់ជាប់ក្នុងតំណែងបែបនេះនោះ ?

**ផ៖** សូមអរគុណ ។ ជនជាប់ចោទអាចនិយាយថា គាត់មិនមានជម្រើសអ្វី គាត់ត្រូវតែធ្វើការហ្នឹង ។ ខ្ញុំទទួលស្គាល់ការហ្នឹង ។ គាត់ថា គឺជាអ្នកដើរតួ ហើយនិងជាចំណាប់ខ្មាំងនៃរបបហ្នឹង ប៉ុន្តែឯកសារដែលខ្ញុំសិក្សានោះ គឺការយល់ដឹងថារបបនោះ គឺជារបបឧក្រិដ្ឋ ។ មិនមែនកើតឡើងនៅតែឆ្នាំ១៩៧៨ ទេ មិនមែនជាពេលវេលាដែលគាត់និយាយថា គាត់មានការខកចិត្ត មិនសប្បាយចិត្ត ហើយនិងគាត់មិនមានជម្រើសនោះ ។ នោះគឺជា-- គាត់លើកឡើងនោះត្រូវហើយ ប៉ុន្តែគាត់ក៏មានការភ័យខ្លាចដែរ ពីព្រោះនៅទីបញ្ចប់ ដូចជានៅចុងបញ្ចប់នៃយន្តការនៃការសម្លាប់នោះ ដែលថាមានភស្តុតាងជាច្រើន ។ ប្រសិនបើវៀតណាមមិនឈ្លានពានទេ សុន សេន មិនទៅច្បាំងទេ ការបង្កភ័យខ្លាចនោះ គឺវាមានចេះតែបន្តទៅទៀត ។ អ៊ីចឹងហើយចម្លើយរបស់ ប៉ុល ពត ដែលយើងបានកត់ត្រាមកដល់ពេលនេះគឺថាមិនមានន័យអ្វីទេ ។ ទោះជាយ៉ាងក៏ដោយនោះ គាត់យល់ថា គាត់រងការវាយប្រហារពីសមាជិករបស់បក្ស*វ៉ាំសារី* ជាដើមនោះ ។ អ៊ីចឹងហើយ គឺខ្ញុំគិតថា យើងមានឯកសារមួយចំនួនដែរថា មានការសោកស្តាយរបស់ជនជាប់ចោទ គាត់មិនបាន-- ខ្ញុំមិនអាចឃ្លាតឆ្ងាយពីអ្វីដែលខ្ញុំបញ្ជាក់ដូចគ្នា ។ អ៊ីចឹងហើយ មិនបានសម្តែងការខកចិត្តនៅក្នុងឆ្នាំ១៩៧៩ រហូតដល់ឆ្នាំ៨០ ហើយគាត់នៅបន្តការងារនៅក្នុងចលនារបស់គាត់ជាតទៅទៀត ។ នេះហើយក៏ជាអ្វីស្របទៅជាមួយនូវអ្វី ខ្ញុំអាចយល់បានថាតើគាត់ធ្វើបែបហ្នឹង វាយ៉ាងដូចម្តេចហើយ ។

[១៥:២៩:២៥]

**សៈ** សូមអរគុណ។ ជាការពិត អ្វីដែលលោកឆ្លើយនៅក្នុងចម្លើយរបស់លោក គឺទាក់ទងទៅនឹងទិដ្ឋភាព ដែលលោកបានលើកឡើងកាលពីព្រឹកមិញ ហើយបានលើកឡើងនៅក្នុងសៀវភៅរបស់លោកផងដែរ ។ គឺវាទាក់ទងទៅនឹងបាតុភូតនៃការភ័យខ្លាយ គឺការភ័យខ្លាចនេះវាកើតមាននៅក្នុងជួរដឹកនាំ ។ ខ្ញុំឃើញនៅក្នុងទំព័រសៀវភៅ៩៨, ៩៩ ជាភាសាបារាំងនៃសៀវភៅរបស់លោកនៅក្នុងនោះ គឺបានលើកឡើងថា បន្ទាប់ពីមានការបញ្ជាដោយផ្ទាល់មាត់ពីខាងមជ្ឈិមបក្ស ឌុច និងសហសេវិក និងបុគ្គលិករបស់គាត់ គឺបានធ្វើការឲ្យមានការបាក់បែក ហើយយើងឃើញថា មានការភ័យខ្លាចនៅក្នុងជួរដឹកនាំ

របស់កម្ពុជាប្រជាធិបតេយ្យ ។ ហើយវាការភ័យខ្លាចនោះ គឺមិនមានការកំណត់នោះទេ នៅក្នុងទំព័រទី ៣៤ គឺវាទាក់ទងនឹងចម្លើយសារភាពដែលបានចេញមកពីស-២១ ។ នៅក្នុងនោះក៏មានគោលបំណងផ្នែកចិត្តសាស្ត្រផងដែរ ដែលវាទាក់ទងទៅនឹងបញ្ហាការភ័យខ្លាច និងស្រមើលស្រមៃរបស់បុគ្គលិកស-២១ ក្នុងលក្ខណៈអត្តនោម័តិ ។ ថាតើលោកមានចំណុចលើកឡើង និងយោបល់ទាក់ទងទៅនឹងបញ្ហាការភ័យខ្លាចនោះដែរឬទេ?

**ឆ៖** គឺថាបញ្ហានេះ វាកើតមាននៅក្នុងជួរបក្ស ហើយគឺខ្ញុំព្យាយាមធ្វើការឆ្លើយនឹងសំណួររបស់លោក ។ ជាការពិត គឺខ្ញុំនៅតែរក្សាជំហរទៅលើយោបល់របស់ខ្ញុំទាក់ទងទៅនឹងម៉ាស៊ីនរបស់កម្ពុជាប្រជាធិបតេយ្យ គឺម៉ាស៊ីននេះបានបាក់បែក ។ ហើយគឺមានការបែកបាក់ជាមួយនឹងទំនាងទំនងការទូត ហើយវាការកើតឡើងចំពោះប្រជាជនផ្សេងៗ ។ នៅពេលដែលគេសម្រេចធ្វើការបន្ថយការនាំចូលអ្នកទោសចូលស-២១នោះ គឺនៅពេលនោះក៏គេជាប់ដៃជាមួយនឹងសង្គ្រាមទ្រង់ទ្រាយធំជាមួយនឹងវៀតណាមផងដែរ ហើយវាមានការភ័យខ្លាចណាស់នៅពេលនោះ ។ នេះ គឺជាអ្វីដែលគេបានអនុវត្តនៅក្នុងការងាររបស់គេ ហើយក៏មានការចូលរួមប្រជាជន ការធ្វើឲ្យមានការចូលរួមជាច្រើននៅក្នុងជួរទ័ពរបស់គេ ។

ដូច្នេះ បរិយាកាសទាំងអស់នេះ-- បរិយាកាសនៅក្នុងឆ្នាំ១៩៧៨ គឺវាការប៉ុនប៉ងមួយក្នុងបន្ថយទៅលើ-- ធ្វើការបន្ថយទៅលើភាពសាហាវយង់ឃ្នង ដែលរបបនេះ គេបានឃើញប្រើប្រាស់ និងអនុវត្តកាលពីមុន ហើយនៅពេលនោះគេព្យាយាមធ្វើឲ្យមានតុល្យភាពទៅបញ្ហានៃការគ្រោះការថ្នាក់ផ្សេងៗ ។ បញ្ហាការភ័យខ្លាចនៅក្នុងជួរដឹកនាំ គឺវាបន្តទៅតែមានរហូត ហើយគ្មានព្រំដែនទេចំពោះការភ័យខ្លាចនោះ ។ ហើយជាការពិតទៅ សត្រូវ ឬក៏ខ្មាំង ដែលគ្រោះថ្នាក់បំផុតនោះ គឺអ្នកដែលមើលមិនឃើញបានន័យថាជាអរូបិយ ។ អ៊ីចឹងគឺបានន័យថា នៅពេលមិនឃើញអ៊ីចឹង គឺយើងមិនអាចបញ្ឈប់បានទេ ។

ដូច្នេះ គឺយើងឃើញតែមករហូតខ្លាំងហ្នឹង ។ នេះគឺជាចម្លើយ ដែលខ្ញុំអាចឆ្លើយតបទៅនឹងសំណួររបស់លោកនៅពេលនេះ ។

[១៥:៣៣:៤០]

**ស៖** សូមអរគុណលោកច្រើន ។ ប្រធានបទមួយទៀតដែលលោកបានលើកឡើង នៅពេលដែលឆ្លើយតបទៅនឹងសំណួររបស់លោកស្រីចៅក្រម ខាតវ៉ាយច៍ ទាក់ទងទៅនឹងគោលនយោបាយសម្ងាត់ គោលនយោបាយរក្សាការសម្ងាត់ គឺវាកើតមាននៅក្នុងស-២១ផងដែរ ។ ជាទូទៅ នៅពេលដែលខ្ញុំមើលសៀវភៅទំព័រ២៤ នៃសៀវភៅរបស់លោក។និយាយថា អ្នកយាមមិនមានសិទ្ធិតាមដានការសួរចម្លើយ

ដែលគេធ្វើឡើងនៅក្នុងអគារ និងបន្ទប់មួយចំនួន ឬក៏អ្នកយាមក៏មិនអាចបើកបង្អួចមើលការសួរចម្លើយខ្លាំងដែរ ។ ដូច្នេះ ខ្ញុំក៏ចាំដែលនៅក្នុងផ្នែកមួយចំនួនដែលលោកបានលើកឡើង គឺថាអ្នកសួរចម្លើយ គឺមិនអនុញ្ញាតឲ្យនិយាយគ្នាទេ ហើយនិយាយជាទូទៅនៅក្នុងទំព័រ៣១ នៃសៀវភៅរបស់លោក១បានលើកឡើងដូចតទៅៈ

ប្រទេសទាំងមូលបានក្លាយទៅជាបរិយាកាស ឬក៏កន្លែងមួយបិទជិតមួយភ្លាម១តែម្តង ។ បានន័យថា វានៅដាច់ឆ្ងាយ និងឯកកោពីសង្គមទូទៅ ។ មេដឹកនាំនៅស-២១ គឺគ្រប់គ្រងដោយមជ្ឈិមបក្សហើយក៏ត្រូវរក្សាការសម្ងាត់ ហើយជាសមាជិករបស់របបឯករាជ្យមួយ គឺការងារទាំងអស់នេះធ្វើការនៅក្រោយបទបញ្ជាយោធា ។ ហើយនៅក្នុងកថាខណ្ឌបន្ទាប់មក នៅពេលដែលលោកនិយាយអំពីស្ថាប័នស្វយ័ត លោកនិយាយព្រឹកមិញ លោកបានបន្ថែមទៀតថា មន្ទីរបេសកម្មរបស់មន្ទីរស-២១ គឺដើម្បីការពារមជ្ឈិមបក្ស ។ តើលោកមានយោបល់បន្ថែមទាក់ទងទៅនឹងគោលនយោបាយរក្សាការសម្ងាត់នោះដែរឬទេ? ដែលយើងនិយាយជាទូទៅ ឬក៏លោកចង់និយាយគោលការណ៍នយោបាយ គោលនយោ-បាយរក្សាសម្ងាត់នេះ ដោយយោងមន្ទីរស-២១ ។

**ឆ៖** ហើយគឺខ្ញុំមិនមានយោបល់បន្ថែមទេ ។ វាបង្ហាញយ៉ាងច្បាស់ហើយ ចំពោះជនជាប់ចោទការរក្សាការសម្ងាត់ គឺជានិមិត្តរូប ឬក៏ជាគោលការណ៍មួយនៃរបបនោះ ។ ដូច្នេះហើយ វាគ្មានឱកាសណាមួយដែលគេលើកឡើងប្រឆាំងទៅនឹងការរក្សាការសម្ងាត់នោះទេ ។ ហើយលទ្ធផលដែលគួរឲ្យតក់ស្លុតចេញពីចំណុចនេះ មិនដឹងថាតើមនុស្សធ្វើអ្វីខ្លះ? ចាស់យ៉ាងម៉េច? ឬក៏ក្មេងយ៉ាងម៉េចនោះ? អ្នកទាំងអស់ដែលចូលទៅក្នុងមន្ទីរសន្តិសុខនោះ ត្រូវតែសម្លាប់ក្នុងកម្រិតមួយ ដើម្បីធ្វើយ៉ាងណាមិនឲ្យគេដឹងអំពីអត្ថិភាពនៃមន្ទីរនេះ ។ ហើយយើងឃើញថា អ្នកយាមអីផ្សេង១ ក៏មិនមានលទ្ធភាពចេញទៅលេងផ្ទះផងដែរ ។

ដូច្នេះហើយ ការរក្សាការសម្ងាត់នេះគឺវាមិនអាចដោះស្រាយបានទេ បានន័យថា ជាគោលការណ៍មួយសំខាន់បំផុត ។ ដោយសារតែយើងឃើញទៅ វាមានការរួមផ្សំជាមួយនឹងការភ័យខ្លាច ការរក្សាការសម្ងាត់ និងចូលមកនៃសត្រូវ ឬខ្មាំងនោះ មានការលាយឡំគ្នាទៅលើបរិយាកាសនៅក្នុងកន្លែងនោះ ។

ដូច្នេះហើយយើងឃើញថា មានអ្នកទោសច្រើនត្រូវបានហូរចូលទៅដល់នៅស-២១ ហើយយើងឃើញថា មានការកើនឡើងច្រើនទៅ១ ហើយចំនួននោះ វាចេះតែឡើងរហូត ។ ទិដ្ឋភាពនៃការរក្សាការសម្ងាត់ គឺគេត្រូវតែគោរព ហើយដូចដែលលោក នួន ជា គាត់បានលើកឡើងគាត់បានផ្តល់ជាយោបល់

គាត់នោះ ដែលខ្ញុំបានលើកឡើង ដែលគាត់បញ្ជាក់ថា ការរក្សាការសម្ងាត់គឺជាបេះដូងរបស់បក្ស ហើយជាចំណុចដែលសំខាន់ ហើយវាក៏ជាគំរូមួយរបស់បក្សកុម្មុយនីស្តទាក់ទងទៅនឹងការរក្សាការ សម្ងាត់ ។

[១៥:៣៨:០៣]

**ស៖** សូមអរគុណលោកច្រើន ។ មុនពេលដែលខ្ញុំចាប់ផ្ដើមសួរសំណួរចុងក្រោយរបស់ខ្ញុំ ។ ខ្ញុំចង់ជម្រាបលោក ឆេនដ័ល័រ ថា ខ្ញុំមានការសោកស្ដាយដែលថា សហព្រះរាជអាជ្ញា និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ពួកគាត់មិនបានជម្រាបលោកអំពីភាពលំបាក ទាក់ទងទៅនឹងបញ្ហាភស្តុតាងនៅក្នុងសំណុំរឿង ។ ទាក់ទងទៅអ្វីដែលលោកបានលើកឡើងនៅក្នុងទំព័រទី៤០ ដែលនៅក្នុងនោះនិយាយអំពី-- យើងអត់មានពេលគ្រប់គ្រាន់ទេ ។ គឺឯកសាររបស់សហព្រះរាជអាជ្ញាបានបង្ហាញ ហើយឯកសារនោះ គឺហាក់ដូចជាមិនស៊ីគ្នាទៅនឹងអ្វី ដែលលោកលើកឡើងនៅក្នុងសៀវភៅរបស់លោក ផែនការចុងក្រោយនោះ ។ ហើយសហព្រះរាជអាជ្ញា គាត់សម្រេចដកភស្តុតាងឯកសាររបស់គាត់វិញ ហើយគាត់មិនបាននិយាយថា គាត់ធ្វើខុសទេ គាត់និយាយថាឯកសារនោះ គឺជាឯកសារចេញមកពីសៀវភៅរបស់ ប៊ុន ។ ហើយ ប៊ុន គាត់បានបញ្ជាក់ហើយថា សរសេររបស់ ឌុច ហ្នឹង វាមានលក្ខណៈស្រដៀងគ្នា ។

ដូច្នេះហើយ បញ្ហានេះ វាកើតមាននៅក្នុងនីតិវិធីរបស់យើង ហើយវាជាកាតព្វកិច្ចរបស់សហព្រះរាជអាជ្ញាក្នុងការជម្រាបបញ្ហាហ្នឹង ជូនលោក មិនមែនខ្ញុំទេ ប៉ុន្តែ សោកស្ដាយគាត់មិនបានជម្រាប។ ហើយអ្វីដែលខ្ញុំចង់សួរលោកនៅពេលនេះ ការចែករំលែកជាមូលដ្ឋាន ចេញពីសៀវភៅរបស់លោកនៅក្នុងកិច្ចដំណើរការនីតិវិធីរបស់យើង ។ លោកមានការជំរុញនិងធ្វើឱ្យយើងជឿជាក់ ជាពិសេសនៅត្រង់ជំពូកចុងក្រោយនៃសៀវភៅរបស់លោក ដែលលោកបាននិយាយអំពីឧក្រិដ្ឋកម្មនៃការគោរពបទបញ្ជា ។ តាមអ្វីដែលខ្ញុំដឹងទៅលើចំណុចហ្នឹង នេះគឺជាបញ្ហាមួយដែលខ្ញុំចង់និយាយ ហើយវាចាប់អារម្មណ៍ចំពោះខ្ញុំ ។ ប្រធានបទមួយដែលខ្ញុំចង់ស្វែងយល់ ដូច្នេះហើយតើលោក ឆេនដ័ល័រ អាចជម្រាបអង្គសវនាការក្នុងលក្ខណៈសង្ខេប ថាតើចំណុចសំខាន់យ៉ាងម៉េចដែលលោកបានលើកឡើងទៅលើការងារមួយចំនួនដែលលោកបានបញ្ជាក់លើចំណុចទាំងឡាយជូនអង្គសវនាការ ។

**ឆ៖** គឺយើងឃើញថា វាមានកើតឡើងនៅក្នុងឆ្នាំ១៩៧៦ ព្រឹត្តិការណ៍ទាំងឡាយកើតមានឡើង ហើយយើងឃើញមានការសម្អាតអីផ្សេងៗខ្ញុំបានធ្វើឡើង ហើយយើងឃើញក៏មានព្រឹត្តិការណ៍មួយចំនួនបានធ្វើឡើង ។ ហើយទាក់ទងទៅនឹងការសួរសំណួរផ្សេងៗ ឬក៏សំណួរទាក់ទងនឹងបញ្ហាគណិតវិទ្យាអីផ្សេងៗនោះ គឺវាហាក់ដូចជាអ្វីដែល-- ។

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញ អត់បើកក្បាលមេក្រូទេ?

សុំៗនិយាយម្ដងទៀត ព្រោះអំមិញអត់បានបើកក្បាលមីក្រូ អ៊ីចឹងអត់មានសំឡេងចូលទៅក្នុងប្រព័ន្ធសំឡេង ហើយនិងប្រតិចារឹកទេ ។ អ៊ីចឹងមានការភ្ញាក់ផ្អើល ដោយសារអត់បានស្ដាប់សំឡេង ។

អាចសួរម្ដងទៀតជាថ្មី ហើយនិងអាចនឹងលោកសាស្ត្រាចារ្យឆ្លើយបញ្ជាក់សាជាថ្មី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន។ ដើម្បីភាពចាំបាច់នៃការកត់ទុកនោះ គឺលោកនិយាយអំពី *មីលហ្គ្រីម* (Milgrim) នៃការធ្វើការពិសោធន៍របស់ *មីលហ្គ្រីម* ។ ការពិសោធន៍របស់ *មីលហ្គ្រីម* នោះ គឺធ្វើឡើងដោយអ្នកចិត្តសាស្ត្រមួយចំនួនឈ្មោះ *មីលហ្គ្រីម* អ្នកចិត្តសាស្ត្រឈ្មោះ *មីលហ្គ្រីម* ។ អ្វីដែលកើតឡើងនោះ គឺវាមានចុះក្នុងកាសែតផ្សេងៗ ហើយឲ្យចូលរួមនៅក្នុងការពិសោធន៍ចិត្តសាស្ត្រមួយ ដែលអ្នកខ្លះទៅគាត់ទទួលបានថវិកា ។ ហើយមហាវិទ្យាល័យផ្សេងៗ គឺគេមិនអនុញ្ញាតឲ្យចូលរួមនោះទេ ហើយអ្វីដែលវាពាក់ព័ន្ធនៅក្នុងកិច្ចពិសោធន៍នោះ គឺអ្នកដែលស្ម័គ្រចិត្តនោះ គឺឲ្យអង្គុយនៅនឹងកន្លែងដែលមានឧបករណ៍មានប៊ូតុងសម្រាប់ចុច ហើយគ្រូចិត្តសាស្ត្រដែលស្លៀកពាក់សនោះ គាត់ទទួលបន្ទុកទៅលើការធ្វើពិសោធន៍នោះ ។ ហើយគឺជាអ្នកដែលគ្រប់គ្រងទៅលើការពិសោធន៍ហ្នឹង ។ គាត់បានសួរសំណួរទៅលើបុគ្គលដែលនៅក្រៅជញ្ជាំង ឧទាហរណ៍ថា ជញ្ជាំងនៅពីមុខខ្ញុំអ៊ីចឹង គឺគាត់សួរ ។ ជញ្ជាំងហ្នឹងដាក់បាំងជិត ហើយបុគ្គលដែលគាត់ឆ្លើយ គាត់ត្រូវចុចប៊ូតុង បាទ ឬក៏មិនទទួលស្គាល់ ។ ហើយប្រសិនបើបុគ្គលនៅខាងក្រោយជញ្ជាំងហ្នឹង និយាយផ្ដល់ចម្លើយខុសនោះ ហើយអ្នកដែលស្ម័គ្រចិត្តហ្នឹង គាត់នឹងចុចប៊ូតុងនៅក្នុង នៅលើតុរបស់គាត់ ហើយពេលនោះនឹងមានការឆក់ទៅលើអ្នកមួយទៀត ដែល ដែលឆ្លើយខុស ។

[១៥:៤៤:៤១]

ដូច្នេះ វាជាការរំឭកអំពីចម្លើយដែលខុស ដូច្នេះគឺគេបង្កើតទៅលើការពិសោធន៍ដូច្នោះ ។ ហើយចម្លើយរបស់បុគ្គលដែលនៅក្រោយជញ្ជាំងនោះ គឺវាមានការខុសច្រើនទៅៗ ។ ដូច្នេះហើយ អ្នកដែលចិត្តសាស្ត្រគ្រប់គ្រងទៅលើការពិសោធន៍នោះ ស្នើសុំអ្នកស្ម័គ្រចិត្តមួយរូបឲ្យធ្វើការបង្កើនវ៉ុលភ្លើងនៅក្នុងឧបករណ៍នោះ ដើម្បីធ្វើយ៉ាងណាឲ្យបុគ្គលដែលនៅម្ខាងទៀតនោះគាត់បានដឹង ។ ដូច្នេះ នៅពេលដែលគេធ្វើដោយការតម្លើយវ៉ុលភ្លើងនោះ គឺវានឹងមានសញ្ញាភ្លើងភ្លឹបភ្លែតៗ ដែលវាបង្ហាញអំពីភាពគ្រោះថ្នាក់

ដូច្នេះនៅពេលនោះ អ្នកចិត្តសាស្ត្រ គាត់ប្រាប់អ្នកទាំងពីនោះថា អត់បញ្ហាទេ វាអត់អីទេ ហើយអ្នកដែលនៅម្ខាងទៀតនោះ គាត់បានឮ ហើយគាត់-- យើងឮថា គាត់ស្រែកផ្សេងៗ ហើយគាត់វ៉ៃជញ្ជាំង ដើម្បីឲ្យឈប់បញ្ឈប់នូវការធ្វើការពិសោធន៍ ។ ដូច្នេះ យើងឃើញថា ចិតសិបភាគរយនៃអ្នកស្ម័គ្រចិត្តនោះ គឺគាត់ធ្វើការគោរពតាមការបញ្ជា ហើយតម្លើយវ៉ុលភ្លើងទៅតាមការណែនាំ ។ ហើយពេលនោះអ្នកចិត្តសាស្ត្រថាអត់បញ្ហាទេ ដំឡើងវ៉ុលភ្លើងទៅទោះបីជាមានបញ្ហាអ្វី ក៏អត់អីដែរ ។ ដូច្នេះវាជាការពិសោធន៍ទៅនឹងចំណុចហ្នឹង ។

អ្នកដែលម្នាក់ទៀតនៅម្ខាងនៃជញ្ជាំងនោះ គឺគាត់អត់មានអ្វីកើតឡើងចំពោះគាត់នោះទេ ប៉ុន្តែកម្មវិធីដែលគេធ្វើដោយ ដែលកើតចេញពីការឆ្លើយចម្លើយខុសនោះ គឺវាទាក់ទងទៅនឹងការបញ្ចេញចរន្តទៅលើអ្នកដែលឆ្លើយខុស ធ្វើឲ្យមានបញ្ហាឆក់ជាដើម ។ ដូច្នេះហើយ *មីលក្រ្កាម* នោះគាត់បានធ្វើការផ្លាស់ប្តូរទីកន្លែងរបស់អ្នកចូលរួមនោះ ហើយគាត់បានធ្វើពិសោធន៍នេះជាច្រើនឆ្នាំ ។ ហើយវាបានបង្ហាញលទ្ធផលហុកសិបភាគរយ កើតចេញពីអ្នកស្ម័គ្រចិត្តដែលគាត់បានផ្លាស់ប្តូរទៅលើទីកន្លែង ឬជំហររបស់គាត់ ។ ហើយសមាគមចិត្តសាស្ត្ររបស់អាមេរិកាំង នៅពេលគេផ្សាយលទ្ធផលពិសោធន៍នោះគឺគេធ្វើកិច្ចប្រជុំមួយ ការពិសោធន៍ គេលើកឡើងថា ការពិសោធន៍ដូច្នេះ មិនអាចធ្វើឡើងទេ ដោយអ្នកចិត្តសាស្ត្រ គឺវាមានការគ្រោះថ្នាក់ទៅដល់បញ្ហាចិត្តសាស្ត្ររបស់អ្នកស្ម័គ្រចិត្ត ។ ការរកឃើញចេញពីការពិសោធន៍របស់ *មីលក្រ្កាម* នោះគឺវាទាក់ទងទៅនឹងបញ្ហានៃភាពត្រឹមត្រូវ ហើយវាទាក់ទងទៅនឹងការគោរពទៅលើការគោរពបញ្ជារបស់បុគ្គលម្នាក់ ដែលគេបង្គាប់បញ្ជា ។

[១៥:៤៧:៥៤]

ដូច្នេះ ហើយចំពោះខ្ញុំ ចំណុចនេះគឺវាទាក់ទៅនឹងវប្បធម៌មិនមែនត្រឹមតែលើស-២១ទេ គឺលើកម្ពុជាប្រជាធិបតេយ្យតែម្តង បានន័យថា វាពាក់ព័ន្ធ ការពិសោធន៍នេះវាពាក់ព័ន្ធ បុគ្គលដែលគាត់ផ្តល់បញ្ជានោះ គឺគាត់បញ្ជាទៅឲ្យបុគ្គលដែលគាត់ទទួល ។ ដូច្នេះអ្នកបញ្ជា គឺបញ្ជា អ្នកទទួល គឺគាត់ទទួលបញ្ជា ។ ដូច្នេះហើយនៅក្នុងប្រទេសកម្ពុជាមិនមានវប្បធម៌ នៃការជជែកសួរបញ្ហានៃការចេញបញ្ជាពីខាងលើនោះទេ ។ ឧទាហរណ៍ថា បញ្ជាចេញពីយោធាទៅថ្នាក់ក្រោម ពីគ្រូទៅសិស្ស ។ ដូច្នេះហើយការពិសោធន៍នោះ គឺវាបានបញ្ជាក់អំពីស្ថានភាពដែលវាកើតមាន ដូចទៅនឹងស-២១អ៊ីចឹង ការគោរពក្រឹត្យក្រមនៃការគោរព គឺវាបានដាក់ចូល និងកើតមាននៅទីនោះ ។ ហើយវាបង្កើតឲ្យមានការភ័យខ្លាចដូច ដែលមានការកើតឡើងទៅលើព្រឹត្តិការណ៍មួយនៅប៉ូឡូញ ទាក់ទងទៅនឹងការបាញ់សម្លាប់លើបុគ្គល

មួយចំនួន តាមរយៈការចេញបញ្ហា ។ ខ្ញុំបានដាក់ចំណុចទាក់ទងការពិសោធន៍នៅក្នុងជំពូកចុងក្រោយនៃសៀវភៅរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនបានពន្យល់ច្បាស់លាស់ ។ ដូច្នេះ ដូចមនុស្សដូចយើង គឺទោះបីជាស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្តក៏ដោយ ឬក៏វាមានលក្ខណៈឧក្រិដ្ឋ ឬក៏មិនឧក្រិដ្ឋក៏ដោយ នៅពេលដែលបុគ្គលដែលគាត់ទទួលខុសត្រូវ គាត់ថាអត់អីហើយ ។ អ៊ីចឹងគាត់បញ្ជាមក យើងធ្វើតាមគាត់ប្រហែលជាអត់អីតាមគាត់។ ដូច្នេះហើយ វាជាចំណុចទាក់ទងទៅនឹងវប្បធម៌ដែលកើតមាននៅមន្ទីរស-២១ និងកម្ពុជាប្រជាធិប-តេយ្យ ប៉ុន្តែគឺខ្ញុំអាចតែពន្យល់ប៉ុណ្ណោះទេ ប្រហែលជាអាច លោក លោកស្រីចៅក្រមអាចយល់ច្បាស់។

[១៥:៤៩:៥៧]

**ស៖** លោក ឆេនដ័ល័រ សូមអរគុណលោកច្រើន ដែលលោកបានពន្យល់ទៅលើចំណុចមួយនេះ។ ហាណាអារិន គាត់ក៏ព្យាយាមយល់ទៅលើបញ្ហានេះដែរ គេរិះគន់គាត់ច្រើនដែរ ។ ដូច្នេះហើយ យើងព្យាយាមយល់ ហើយយើងព្យាយាមទៀតព្យាយាម ហើយយើងព្យាយាមម្តងហើយម្តងទៀតដើម្បីយល់ទៅលើបញ្ហាដែលកើតឡើងទាំងអស់នេះ ។ ដូច្នេះហើយ លោករំឭកយើងខ្ញុំនៅក្នុងសៀវភៅរបស់លោក ទំព័រ១៨៥នៃភាសាបារាំង នៅក្នុងនោះវាទាក់ទងទៅនឹង *ស៊ិកម៉ានដ៍ បាវម៉ាន* (Sigmund Bowman) បុគ្គលឈ្មោះ *ស៊ិកម៉ានដ៍ បាវម៉ាន* ដែលគាត់និយាយអំពីព័ត៌មានដែលគួរឲ្យភ័យខ្លាច ទាញចេញពីមហាសោកនាដកម្ម ដែលយើងបានដឹងពីអ្នកប្រព្រឹត្ត ហើយវាមិនមែនជាលទ្ធភាពដែលយើងអាចយល់បាននោះទេ ។ ដូច្នេះ គំនិតគោលគំនិតនោះ គឺយើងអាចសិក្សាស្វែងយល់ ក៏ដូចជាអ្នកផ្សេងទៀងផងដែរ ។

[១៥:៥១:១០]

លោក ដេវីដ ឆេនដ័ល័រ ចៅក្រមបានជម្រាបលោក ហើយបានអានកថាខណ្ឌចុង-- ប្រយោគចុងក្រោយនៅក្នុងសៀវភៅរបស់លោក ប៉ុន្តែមិនមែនជាប្រយោគចុងក្រោយបំផុតនោះទេ ។

ខ្ញុំចង់សួរសំណួរមួយទាក់ទងទៅនឹងចំណុចនេះ ដោយសារតែវាជាសំណួរមួយសំខាន់ ។ លោកបានធ្វើការសន្និដ្ឋាននៅក្នុងកថាខណ្ឌចុងក្រោយ ដោយលើកឡើងប្រយោគមួយចំនួនដើម្បីស្វែងរកឫសគល់នៃចំណុចអាក្រក់នៅស-២១នោះ គឺយើងមិនគួរមើលចេញក្រៅពីខ្លួនឯងនោះទេ នេះគឺជាអ្វីដែលលោកបានធ្វើការទាញសន្និដ្ឋាននៅក្នុងសៀវភៅរបស់លោកហើយជម្រាបជូនយើងខ្ញុំ ។

**ឆ៖** ខ្ញុំប្រកាន់ជំហររបស់ខ្ញុំនៅលើប្រយោគចុងក្រោយនោះ ទោះបីជាវាមិនមានការចងកាតព្វកិច្ច ឬក៏មិនពាក់ព័ន្ធទៅលើចំណុចជាក់លាក់ទាក់ទងនឹងច្បាប់ក៏ដោយ ប៉ុន្តែវាទាក់ទងទៅនឹងសមត្ថភាពរបស់យើងដែលថា យើងធ្វើត្រូវឬក៏យើងធ្វើខុស ហើយលោក *បាវម៉ាន* គាត់បានលើកឡើងអំពីបញ្ហាឥរិយាបថ

ត្រឹមត្រូវផងដែរ បានន័យថាវាពាក់ព័ន្ធគ្នា ។ ដូច្នេះ ខ្ញុំប្រកាន់ជំហររបស់ខ្ញុំទៅលើប្រយោគដែលខ្ញុំសរសេរចុងក្រោយ។ ខ្ញុំប្រើពាក្យថា *អ៊ីវូល* (evil) គឺពាក្យថា បិសាច ឬអាក្រក់ ។ មនុស្សដែលធ្វើអាក្រក់នោះមិនមែនថាអាក្រក់នោះទេ ។ ហើយយើងដឹងហើយថា ប្រសិនបើយើងសំលាប់នោះ គឺយើងនឹងជាប់ទោស ដូច្នេះហើយវាជាចំណុចមួយដែលយើងត្រូវគិត ប៉ុន្តែវាពាក់ព័ន្ធទៅលើបញ្ហាផ្សេងៗ ។ ហើយខ្ញុំមិនដូចជាមិនពេញចិត្ត មនុស្សដែលគាត់និយាយថា មើលទៅលើបិសាច ពួកបិសាចទាំងអស់នោះនៅទីនោះទៅ ។ អត់ទេ យើងមិនមែនបិសាចទេ ប៉ុន្តែអ្នកណាទៅដឹងថាលោកបានធ្វើអីខ្លះ ឬគេបានធ្វើអីខ្លះ ។ ដូច្នេះ វាមិនមានន័យថា អ្នកដែលប្រព្រឹត្តនៅពេលនោះ គាត់មានឥរិយាបទណាមួយជាក់លាក់នោះទេ ។ យើងត្រូវតែសិក្សាទៅលើបញ្ហានេះ ។ អ៊ីចឹងវាទាក់ទងទៅនឹងបញ្ហានៃបុគ្គលិកលក្ខណៈរបស់បុគ្គលម្នាក់ៗ ឬក៏មនុស្សទូទៅ ។

**ស៖** សូមអរគុណ លោក ដេវីដ ឆេនដ៏ល័រ ។ ជាការពិត ខ្ញុំសូមបញ្ជាក់ថា ឌុច គាត់បានទទួលស្គាល់ឧក្រិដ្ឋកម្មទាំងឡាយ ដែលគាត់បានចូលរួមប្រព្រឹត្តនៅស-២១ ។ សូមអរគុណលោកច្រើន។ ហើយ ជនជាប់ចោទ គាត់មានវិប្បដិសារីខ្លាំងណាស់ ។

[១៥:៥៥:០៥]

**ឆ៖** គឺមីក្រូហ្វូនរបស់ខ្ញុំ គឺខ្ញុំមិនមែនប្រើពាក្យក្នុងសៀវភៅរបស់ខ្ញុំថា ឧក្រិដ្ឋកម្មខ្មែរក្រហមដែលមិនចេះចប់ ហើយមិនបានផ្តន្ទាទោសនោះទេ ។ ប៉ុន្តែយ៉ាងណាក៏ដោយ គឺមានការដកចេញនូវឃ្លាមួយចំនួនទៅលើចំណង ជើងដើម្បីឲ្យវាមានលក្ខណៈស៊ីគ្នា ។ ហើយធ្វើយ៉ាងណាឲ្យគេយល់ថាសៀវភៅនេះអាចឲ្យសាធារណជនគាត់យល់បាន សៀវភៅនេះគឺមានកំណត់សម្គាល់ផ្សេងៗ ហើយយោបល់មួយចំនួននោះចេញមកពីកំណត់ជើងទំព័រនោះផងដែរ ។ ដូច្នេះហើយសៀវភៅនេះ គឺវាមានការដកស្រង់ចេញពីឯកសារផ្សេងៗ ហើយមានការបកប្រែជាភាសាបារាំងអីផ្សេងៗ ។

ប៉ុន្តែ យ៉ាងណាក៏ដោយ គឺខ្ញុំក៏មិនដែលរៀបចំសៀវភៅនេះជាភាសាបារាំង ដោយខ្លួនឯងនោះដែរ ប៉ុន្តែចំណុចខ្លះទៅដកស្រង់ចេញពីភាសាបារាំងមក វាមានលក្ខណៈចម្លែកបន្តិច ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន សូមអរគុណលោក ដេវីដ ឆេនដ៏ល័រ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញមេធាវីតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងលើកឡើងបញ្ហាមួយគឺថា បន្ទាប់ពីជនជាប់ចោទបានផ្តល់សេចក្តីសង្កេតប្រសិនបើយើងអាចលើកនៅពេលនេះបាន អាចគាត់នឹងមានមតិយោបល់ យើងចង់ដាក់ជូនដេញដោលនៅចំពោះមុខតុលាការ ចំពោះផែនការរួមចុងក្រោយនោះ លេខនោះ គឺE5/12.29 ជាភាសាអង់គ្លេស E00288905 ហើយនិងលេខតទៅទៀត និងលេខអក្សរខ្មែរលេខ 00285361 រហូតទៅដល់ 00285393 ភាសាបារាំង 00314947 រហូតទៅដល់ 00314973 ហើយទាក់ទង ខ្ញុំនឹងសូមដាក់ជូនឯកសារ ហៅថា ផែនការរួមចុងក្រោយនេះ ដើម្បីដេញដោលចំពោះមុខតុលាការ ។ ហើយខ្ញុំនឹងលើកឡើងទៅមតិយោបល់របស់មេធាវី ហាក់ដូចជាមានលក្ខណៈធ្ងន់ធ្ងរពេកដែលថា មិនបានបញ្ជាក់ថាឯកសារនោះ ហើយយើងមានពេលវេលាតានតឹង ហើយយើងត្រូវជ្រើសយ៉ាងប្រុងប្រយ័ត្ន ដែលយកមកប្រើចំពោះសាក្សី ។ ប៉ុន្តែ ចំណុចនេះសាក្សីអ្នកជំនាញថ្ងៃនេះ លោកសាស្ត្រាចារ្យនោះគាត់ជឿថាឯកសារដែលគាត់បានឃើញថា ផែនការរួមចុងក្រោយនោះ គឺតាមពិតបានសរសេរដោយ ឌុច ប៉ុន្តែដូចដែលលោក លោកស្រីចៅក្រមបានជ្រាបហើយ នៅក្នុងឯកសារដែលយើងបានដាក់ជូននៅថ្ងៃទី១៦ ខែមីនា យើងបញ្ជាក់ថា ក្រោយពីការវិភាគឯកសារនោះ យើងពិនិត្យមើលការសរសេរផ្ទាល់ដៃរបស់ ឌុច នៅក្នុងការិយាល័យ យើងពិនិត្យថា ការសរសេរផ្ទាល់ដៃនេះ គឺជាការសរសេរផ្ទាល់ដៃរបស់អ្នកសួរចម្លើយ ប៉ុន នោះទេ ។ អ៊ីចឹងហើយ លោកមេធាវីការពារលោកបានលើកឡើងហើយទាក់ទងនឹងបញ្ហានេះ គឺឯកសារស-២១ ដែលផលិតឡើងដោយអ្នកសួរចម្លើយស-២១ គឺវាមានការពាក់ព័ន្ធយ៉ាងសំខាន់ដែលថាអាចនឹងស្របទៅនឹងអ្វីដែលលោកសាស្ត្រាចារ្យបាននិយាយ ដែលព័ត៌មានចុងក្រោយ ពីរឆ្នាំចុងក្រោយនោះ គឺវាពាក់ព័ន្ធទៅនឹង វាមានការពាក់ព័ន្ធធ្វើឱ្យយើងយល់បានដែលថាអ្វីជាអ្នកដែលគេយល់ថាជាខ្មាំងនៅក្នុងសម័យនោះ ពីព័ត៌មានដែលយើងទទួលបាន។

អ៊ីចឹងហើយយើងសូមស្នើដាក់ឯកសារនេះជាភស្តុតាង ថាតើជនជាប់ចោទ គាត់ចង់ធ្វើសេចក្តីសង្កេតអ្វីទាក់ទងទៅរឿងហ្នឹង គឺថាយើងនឹងស្តាប់គាត់ ។ សូមអរគុណ ។

[១៥:៥៩:៤៤]

**លោក ហ្វ្រង់ស្វ័រ រូ៖**

មេធាវីការពារមិនជំទាស់ចំពោះការដាក់ឯកសារនេះដេញដោលទេ ដែលគាត់បញ្ជាក់ថាឯកសារនេះបានសរសេរឡើងដោយ ប៉ុន គឺមិនមែន ឌុច ជាអ្នកសរសេរនោះទេ។

**ប្រធានអង្គជំនុំ៖**

ជាបន្តនេះ អង្គជំនុំជម្រះផ្តល់ឱកាសទៅជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់នូវសក្ខីកម្មរបស់អ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ដែលបានធ្វើការផ្តល់សក្ខីកម្មអស់រយៈពេលមួយថ្ងៃកន្លងមកនេះ ប្រសិនបើជនជាប់ចោទមានបំណង អង្គជំនុំជម្រះអនុញ្ញាត ។

**ជនជាប់ចោទ៖**

លោកប្រធានជាទីគោរព! ដំបូងខ្ញុំសូមអនុញ្ញាតធ្វើការកត់សម្គាល់បីចំណុច ទៅលើវណ្ណកម្មរបស់លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ។

ចំណុចទីមួយ គឺខ្ញុំសូមគោរពដឹងគុណលោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ អំពីការសង្កេតរបស់ខ្ញុំ-- អំពីការសង្កេតរបស់គាត់លើកិច្ចការរបស់ខ្ញុំក្នុងការតាមដាន ការបាត់ខ្លួននៃលោក ទូ សាមុត ។ សូមជម្រាបដោយស្មោះត្រង់ថា ការបាត់ខ្លួនរបស់ តាទូ ខ្ញុំអត់ជ្រះស្រឡះទេរហូតទល់ថ្ងៃនេះ ។ លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ឃើញស្នាដៃសួរចម្លើយនៅស-២១ លោកឲ្យតម្លៃនេះដល់ខ្ញុំ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ។ នេះពិតជាគុណធម៌របស់អ្នកស្រាវជ្រាវមួយដែលខ្ញុំសូមរៀនសូត្រតាម។

[១៦:០២:២៥]

ចំណុចទីពីរ ដែលខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់លោក ដេវីដ ឆេនដ៍ល័រ ដែរគឺរូបផ្តែ រូបផ្តែទាំងពីរនេះលោក ដេវីដ ឆេនដ៍ល័រ មានប្រសាសន៍ថា មិនមែនជាទស្សនះរបស់កម្ពុជាប្រជាធិបតេយ្យទេ ។ ផ្តែមួយមានរូប ហូ ជីមិញ ជារូបក្បាល ក្បាលផ្តែហ្នឹង គឺរូប ហូ ជីមិញ ផ្តែទីពីរគឺរូប លីន ដុន និង ស៊ិន សុន ការសង្កេតនេះត្រឹមត្រូវណាស់ ។ ខ្ញុំក៏ដឹង ថាខ្ញុំធ្វើហ្នឹងខុស ពីព្រោះខ្ញុំរករូបវីឆាត នីកសុន អត់បាន ហើយខ្ញុំឲ្យគេធ្វើ ដូច្នេះមិនមែនជារបស់ អ្នកឈ្មះគឺបក្សកុម្មុយនីស្តវៀតណាមគេប្រឌិតរឿងនេះឡើងទេ គឺពិតជារបស់ខ្ញុំដែលប្រឌិតរឿងនេះឡើង ពីព្រោះខ្ញុំរករូប រីឆាត នីកសុនអត់បាន ។ ដូច្នេះ ការវិភាគដ៏វិទ្យាសាស្ត្រនេះ ធ្វើឲ្យខ្ញុំកាន់តែគោរពសរសើរ ដល់គុណធម៌របស់លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ។ ទន្ទឹមនឹងនេះ ធម្មតាទេ បញ្ហាស្អីក៏ដោយវាមិនដែលឯកោទេ លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ បានសរសេរប្រវត្តិរូបខ្ញុំទៅតាមសក្ខីកម្មរបស់មនុស្សម្នាក់ ដែលតាំងខ្លួនថាមិត្តភក្តិរបស់ខ្ញុំ តាមពិតមិនមែនជាមិត្តភក្តិទេ គ្រាន់តែឃើញគ្នាពីចម្ងាយ ។

ការសង្កេតរបស់ខ្ញុំនៅទីនេះ គឺអត់និយាយ ថាតើសក្ខីកម្មនេះត្រូវប៉ុនណា ខុសប៉ុនណាទេ សូមជម្រាបបញ្ជាក់ប៉ុណ្ណោះ ។ នៅពេលដែលខ្ញុំតាមខ្ញុំចាំ បើខ្ញុំមិនច្រឡំទេ គឺនៅពេលដែលលោកសាស្ត្រាចារ្យ

ឲ្យ នេត ថាយ៉័រ ប្រគល់សៀវភៅរបស់លោកសាស្ត្រាចារ្យមួយក្បាល ដែលមានចំណងជើងថា "បងទីមួយ" នៅក្នុងនោះខ្ញុំឃើញអ៊ីមែលមួយ ដែលលោកសាស្ត្រាចារ្យលោកបញ្ជាឲ្យ នេត ថាយ៉័រ សួរ ប្រវត្តិរូបខ្ញុំឲ្យឆាប់ផ្ញើរទៅឲ្យគាត់ ។ ដូច្នេះ នេះជាគុណធម៌ទីមួយទៀត ទីបី ដែលខ្ញុំសូមគោរព អ្នកស្រាវជ្រាវគឺអ៊ីចឹង មិនដែលពេញចិត្តនឹងសកម្មភាពដែលខ្លួនសរសេរទៅថា វាពិតទាំងស្រុងទេ ចេះតែស្រាវជ្រាវតទៅទៀត ។ ដូច្នេះ គុណធម៌ទាំងបីនេះ ខ្ញុំសូមគោរពដឹងគុណយ៉ាងជ្រាលជ្រៅបំផុត ដល់ឃើញស្នាដៃរបស់លោក អំពី ស-២១ នេះខ្ញុំសូមជម្រាបថា ខ្ញុំអរណាស់ មានមោទនភាព ។ ខ្ញុំគិតថាវាជាផ្កាមួយទង ក្នុងចំណោមផ្កាមួយរយទង ដែលរីកនៅក្នុងសួនច្បារប្រជាធិបតេយ្យ ជាមួយនឹងសាស្ត្រាចារ្យខ្ញុំ លោក មីសែល វីកយ៉័ររី ជាមួយនឹងសង្គមវិទូ អេវីង ហ្គាហ្វមែន ជាមួយនិងសាស្ត្រាចារ្យ វីហ្សប ។ល។

ដូច្នេះ ខ្ញុំអរណាស់ មានមោទនភាពណាស់ នៅពេលដែលលោកចៅក្រម លោកបញ្ជាឲ្យខ្ញុំសរសេរសេចក្តីអធិប្បាយ អំពីស្នាដៃរបស់លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ ខ្ញុំមានការពិបាក ពិបាកក្នុងចិត្ត ពីព្រោះសមត្ថភាពខ្ញុំតូចទាប ។ ដូច្នេះ ខ្ញុំសរសេរមិនកើតទេ គិតចុះគិតឡើងខ្ញុំសរសេរបានតែពីរបីម៉ាត់ អំពីអត្ថបទដែលមាននៅក្នុងវណ្ណកម្មរបស់លោកសាស្ត្រាចារ្យ ។ ក្រៅពីនោះ ខ្ញុំសរសេរអំពីប្រវត្តិឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាទៅលើប្រជាជនកម្ពុជា ដែលខ្ញុំចែកជាពីរដំណាក់កាល ។ ដំណាក់កាលទីមួយ មុនថ្ងៃ៣០ មីនា ហើយដំណាក់កាលទីពីរក្រោយថ្ងៃ៣០ មីនា ។ មុន៣០ មីនា គឺបក្សកុម្មុយនីស្តកម្ពុជា ប្រព្រឹត្តឧក្រិដ្ឋកម្មទៅលើអ្នករាជការចាស់ ទៅលើទាហានចាស់ ទៅលើប៉ូលិសចាស់ ទៅលើប្រជាជននៅក្រុង ។ រយៈកាលចុងក្រោយនៃដំណាក់កាលនេះ ណាត គេធ្វើប្រធាន ខ្ញុំជាអនុ ក៏ប៉ុន្តែចាប់តាំងពីថ្ងៃ៣០ មីនា ឆ្នាំ១៩៧៨ ខ្ញុំឃើញឯកសារនេះ ខ្ញុំតក់ស្លុតនឹងឧក្រិដ្ឋកម្មរបស់ខ្លួនទៅលើជាតិប្រជាជនខ្លួន ជាពិសេសទៅលើបក្ខជន ។ ខ្ញុំសរសេរប្រវត្តិឧក្រិដ្ឋកម្មរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងឋានៈខ្ញុំជាមនុស្សម្នាក់នៅក្នុងបក្សនេះ ដែលមានទោសធ្ងន់ចំពោះជាតិប្រជាជនខ្លួនឯង ។

[១៦:០៧:១៨]

ហើយទីពីរ មួយកំណាត់ទីពីរ ខ្ញុំចង់និយាយអំពីន័យសេចក្តីសារភាពរបស់ខ្ញុំហ្នឹង ខ្ញុំនិយាយអំពីតើទ្រឹស្តី ប៉ុល ពត ជាទ្រឹស្តីអី? បានជាខ្ញុំតែងនិយាយថា ប៉ុល ពត ទីស (PolPotism) មិនមែន *ម៉ៅអ៊ីស* (Maoist) ទ្រឹស្តីរបស់ ប៉ុល ពត គឺទ្រឹស្តីរបស់អាក្រុមបួននាក់ ហើយ ប៉ុល ពត មកបន្ថែមទៅទៀត ។

ខ្ញុំឲ្យឧទាហរណ៍នៅក្នុងនោះ គឺក្រោយ១៧មេសា បន្ថិច ឆាំង ឈុនឆៀវ វាមកនៅស្នាក់ជាសម្ងាត់នៅភ្នំពេញ ។ ដូច្នេះ សរុបមកសេចក្តីសរសេររបស់ខ្ញុំនេះ វាមិនមែនជាស្នាដៃអីធំដុំទេ គឺជាសេចក្តីសារភាពទោសកំហុសរបស់ខ្លួនជូនជាតិប្រជាជនកម្ពុជា ហើយរកប្រភពថាស្អីដែលនាំឲ្យជាតិប្រជាជនកម្ពុជាវិនាសអន្តរាយហិនហោចសព្វបែបយ៉ាងនេះ ។

ដូច្នេះ នៅចុងបញ្ចប់នេះ លោកប្រធានជាទីគោរព ខ្ញុំអត់មានអីទេ គឺមានបំណងចង់សុំដាក់ឯកសារទាំងបីរបស់ខ្ញុំដែលខ្ញុំសារភាពជូនជាតិប្រជាជនកម្ពុជានេះ ជាសាធារណៈតាមមធ្យោបាយរបស់ អ.វ.ត.ក ខ្ញុំមានសំណូមពរតែប៉ុណ្ណឹង ។ សូមគោរព សូមចប់ ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៦:១២:១៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញជនជាប់ចោទក្រោកឈរ! សូមបញ្ជាក់ឲ្យបានច្បាស់លាស់លើសំណើរបស់លោកអម្បាញ់មិញដែលស្នើសុំឲ្យដាក់ឯកសារចំនួនបីដើម្បី ដែលជាក្តីសារភាពអំពីឧក្រិដ្ឋកម្មផ្សេងៗដែលលោកមានការប៉ុនប៉ងសុំអង្គជំនុំជម្រះបង្ហាញជាសាធារណៈហ្នឹង តើឯកសារហ្នឹងលោកបានដាក់នៅក្នុងសំណុំរឿងរួចហើយ ឬក៏ជាឯកសារថ្មី?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ឯកសារនេះខ្ញុំបានជូនទៅចៅក្រមស៊ើបអង្កេត ។ ដំបូងឯកសារនេះខ្ញុំសរសេរតាមបញ្ជារបស់ចៅក្រមស៊ើបអង្កេត ហើយខ្ញុំជូនទៅសហចៅក្រមស៊ើបអង្កេតវិញ លេខឯកសារនេះ គឺA98 ។ ទាំងបីភាសានេះ ភាសាបារាំង និងភាសាខ្មែរជាអក្សររបស់ខ្ញុំ គឺលោកសាស្ត្រាចារ្យលោក ដេវីដ ឆេនដ៍ល័រ ក៏លោកបានរៀបរាប់អស់ ។ លោកមេធាវីលោករៀបរាប់អស់ហើយអំមិញ ឯកសារនេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណ សូមអង្គុយចុះ ។ ដោយសារឯកសារដែលតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះ ហើយខាងមេធាវីការពារក្តីក៏មិនមានតវ៉ាដែរនោះ គឺយើងចាត់ទុកថាឯកសារនេះបានដាក់មុខដេញដោលនៅចំពោះមុខអង្គជំនុំជម្រះហើយ ។ ដោយឡែកឯកសារអម្បាញ់មិញដែលជនជាប់ចោទបានស្នើនេះ គឺឯកសារដែលមាននៅក្នុងសំណុំរឿងស្រាប់ហើយ ហើយឯកសារ

នេះក៏បានមានការពាក់ព័ន្ធនៅក្នុងការសួរដេញដោលពីព្រឹកមិញដោយចៅក្រម ស៊ីលយ៉ា ខាត់វ៉ាយថ៍ រួចហើយដែរ ។ អ៊ីចឹងគឺ អង្គជំនុំជម្រះយល់ថា ឯកសារនេះចាត់ទុកបានដេញដោលនៅចំពោះមុខអង្គជំនុំជម្រះជាសាធារណៈរួចហើយ ។

ឥឡូវនេះ សូមអញ្ជើញលោកមេធាវី ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ មុននឹងលើកសវនាការ ខ្ញុំសូមគោរពទាញការចាប់អារម្មណ៍លើចំណុចមួយ ខ្ញុំមិនអាចមកបានទេ នៅសប្តាហ៍ក្រោយ ហើយមេធាវី កានីហ្សារ៉េស នឹងមកជំនួសខ្ញុំ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ទីបញ្ចប់ហើយ អង្គជំនុំជម្រះគិតថាសវនាការសម្រាប់ថ្ងៃនេះ គឺត្រូវផ្អាកត្រឹមនេះ ហើយសវនាការទៅបន្តនៅថ្ងៃច័ន្ទ សប្តាហ៍ក្រោយ គឺថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ ចាប់ពីម៉ោងប្រាំបួនព្រឹក ។ ហើយសក្ខីកម្មបន្តនោះ គឺនឹងធ្វើសក្ខីកម្មចំពោះសាក្សីដែលនៅសល់ ។

ហើយមុននឹងបញ្ចប់នេះ ក៏សូមថ្លែងអំណរគុណដល់លោកសាស្ត្រាចារ្យ ដេវីដ ឆេនដ័ល័រ ដែលលោកបានចំណាយពេលវេលាដ៏មានតំលៃ ហើយមកចូលរួមផ្តល់សក្ខីកម្មក្នុងនាមអ្នកជំនាញចំពោះអង្គជំនុំជម្រះសាលាដំបូងតាមការអញ្ជើញ ហើយទោះបីជាលោកត្រូវប្រឈមនឹងការតាំងសំណួរពាក់ព័ន្ធជាមួយនឹងស្នាដៃរបស់លោកក្នុងការនិពន្ធរឿងពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខស-២១ នេះយ៉ាងណាក៏ដោយ ឃើញថាលោកមានការអំណត់អត់ធ្មត់ ហើយអង្គជំនុំជម្រះមានការអរគុណ ។

ដូច្នេះ អង្គជំនុំជម្រះនឹងផ្អាកសវនាការត្រឹមនេះ ហើយលើកបន្តទៅថ្ងៃ១០ ខាងមុខ ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សវនាការនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ វេលាម៉ោងប្រាំបួន ព្រឹក ៕

*[សវនាការផ្អាកនៅម៉ោង១៦:១៨នាទី]*